# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៧-២០៣១

ក្រសួងបរិស្ថាន

ឆ្នាំ២០១៧

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត

តំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សជីវៈចម្រុះ សំដៅចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការអភិវឌ្ឍដោយចីរភាព។ វិស័យកសិកម្ម ពឹងអាស្រ័យទៅលើជីវៈចម្រុះដើម្បីជានានូវភាពសំបូរបែបនៃធនធានសេនេទិចរុក្ខជាតិ និងសត្វ ព្រមទាំងរក្សាប្រភពទឹកសម្រាប់បរិភោគ និងស្រោចស្រព។ ប្រជាជនរស់នៅតាមតំបន់ឆ្នេរ ទទួលផលប្រយោជន៍ពីផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង ដែលជាទីជម្រកសម្រាប់មច្ឆជាតិ និងជារនាំងសម្រាប់ទប់ទល់ទៅនឹងខ្យល់ព្យុះដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ចំណែកឯអ្នកដែលរស់នៅក្នុងតំបន់ជនបទវិញ ក៏អាស្រ័យផលទៅលើធនធានធម្មជាតិ រួមមាន៖ អនុផលព្រៃឈើសម្រាប់ប្រើប្រាស់ ជាអុស ធ្យូង និងសំណង់តូចតាច វាលស្មៅសម្រាប់សត្វពាហនៈ ព្រមទាំងតំបន់ដីសើមសម្រាប់ជារបាំងការពារទប់ទល់ទៅនឹងការរាំងស្ងួត និងទឹកជំនន់ ជាដើម។

ទន្ទឹមនឹងនេះ តំបន់ការពារធម្មជាតិក៏ជាប្រភពធនធាន និងផ្តល់សេវាកម្មធម្មជាតិ ដល់តម្រូវការចិញ្ចឹមជីវិត ជាពិសេសសម្រាប់ក្រុមងាយទទួលរងគ្រោះក្នុងសង្គម។ នៅប្រទេសកម្ពុជា ជនជាតិដើមភាគតិច និងសហគមន៍ជនបទ ពឹងអាស្រ័យជាចម្បងទៅលើតំបន់ការពារធម្មជាតិ ដែលបានផ្តល់ចំណីអាហារ ទឹក លំនៅដ្ឋាន ថ្នាំពេទ្យ សម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ ជាងនេះទៀត តំបន់ការពារធម្មជាតិប្រទេសកម្ពុជា មានសក្តានុពលយ៉ាងធំធេង ក្នុងការប្រែក្លាយទៅជាតំបន់ទេសចរធម្មជាតិ ដែលអាចបង្កើតប្រាក់ចំណូលជូនដល់សហគមន៍មូលដ្ឋានផង និងរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិផង។

ការការពារ និងថែរក្សាតំបន់ការពារធម្មជាតិត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ សម្រាប់ចូលរួមដោះស្រាយបញ្ហាពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ការបង្កើនទុនវិនិយោគទៅលើតំបន់ការពារធម្មជាតិ គឺជាការវិនិយោគដែលមានតម្លៃខ្ពស់ ហើយវាក៏នឹងផ្តល់នូវអត្ថផលប្រយោជន៍យ៉ាងច្រើនចំពោះប្រព័ន្ធអេកូឡូស៊ី ការអភិវឌ្ឍន៍សង្គម និងកំណើនសេដ្ឋកិច្ចជាតិក្នុងរយៈពេលវែងផងដែរ។

បច្ចុប្បន្ន ប្រព័ន្ធតំបន់ការពារធម្មជាតិប្រទេសកម្ពុជា រួមមាន៖ តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ មានចំនួនប្រមាណ ៤១% នៃផ្ទៃដីសរុបប្រទេស។ ចំនួននេះ គឺតំណាងមួយដ៏ខ្ពស់ក្នុងប្រទេសលើពិភពលោកដែលមានតំបន់ការពារធម្មជាតិ។ នៅតំបន់អាស៊ី មានតែប្រទេសប៊ូតានមួយដែរដែលមានផ្ទៃដីតំបន់ការពារធម្មជាតិប្រហាក់ប្រហែលនិងកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជានាពេលបច្ចុប្បន្ន កំពុងរងសម្ពាធ និងក្តីបារម្ភយ៉ាងខ្លាំង អំពីប្រសិទ្ធភាពនៃការការពារជីវៈ

ចម្រុះ និងការផ្តល់ឱកាសសម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានប្រកបដោយចីរភាព។ ហេតុនេះ ការវិនិយោគបន្ថែមចំពោះប្រព័ន្ធតំបន់ការពារធម្មជាតិ គឺជាតម្រូវការចាំបាច់ ដើម្បីធានាឱ្យការគ្រប់គ្រងបានល្អប្រសើរ សម្រាប់បន្តផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់នៅប្រទេសកម្ពុជា។

ក្នុងបរិបទនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយ សូមប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ នូវផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (២០១៧ - ២០៣១)។ ផែនការយុទ្ធសាស្ត្រនេះបានឆ្លុះបញ្ចាំងពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តដ៏មុតមាំ សម្រាប់កិច្ចការពារថែរក្សាតំបន់ការពារធម្មជាតិ ក្នុងន័យរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិប្រកបដោយចីរភាព រួមទាំងការកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិ វប្បធម៌ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

ផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនេះ នឹងជួយក្រសួងបរិស្ថាន ស្ថាប័នរបស់រដ្ឋាភិបាលពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា និងអង្គការសង្គមស៊ីវិល ក្នុងការចូលរួមរៀបចំ និងអនុវត្តសកម្មភាពសមស្រប ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរួមចំណែកជាមួយផែនការយុទ្ធសាស្ត្រជាតិដទៃៗទៀត រួមមាន៖ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ យុទ្ធសាស្ត្ររេដបូកជាតិ ផែនការសកម្មភាពនិងយុទ្ធសាស្ត្រជាតិបរិស្ថាន ក្នុងគោលដៅឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំក៏សូមសំដែងការកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី មកពីក្រសួងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ប្រជាសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងការរៀបចំឯកសារដ៏មានតម្លៃនេះឱ្យសម្រេចជារូបរាង។ ការពង្រឹងគ្រប់គ្រងតំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះ គឺជាទិសដៅអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលវាមានសារៈសំខាន់ដល់ការរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងពិភពលោក។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ និងសង្ឃឹមយ៉ាងមុតមាំថា ក្រសួងបរិស្ថាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន នឹងបន្តខិតខំប្រឹងប្រែងសហប្រតិបត្តិការ និងនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីជាទុនក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិដោយចីរភាពក្នុងប្រទេសកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញ **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣"** ដោយចាត់ទុកការគ្រប់គ្រងធនធានធម្មជាតិ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀតនៃមុំរបស់ចតុកោណ។ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺជំរុញការរៀបចំ និងការអនុវត្ត គោលនយោបាយ បទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាឱ្យមានប្រសិទ្ធភាពសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ មានជាអាទិ៍៖ តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់ស្នូលនៃបបនីយជីវៈមណ្ឌលបឹងទន្លេសាប តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់ឧទ្យានជាតិសមុទ្រ។ល។

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (២០១៧-២០៣១) គឺជាឯកសារលើកទីមួយរបស់ក្រសួងបរិស្ថាន សម្រាប់ប្រើជាផែនទីបង្ហាញផ្លូវក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជានាពេលអនាគត ឱ្យកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ក្រោមការដឹកនាំដ៏ឈ្លាសវៃពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ផែនការយុទ្ធសាស្ត្រនេះ ក៏ជាសមិទ្ធិផលថ្មីមួយនៃកម្មវិធីទំនើបកម្មស្ថាប័ន ដែលជាផ្នែកមួយនៃកំណែទម្រង់វិស័យបរិស្ថានរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥។ ឯកសារយុទ្ធសាស្ត្រនេះ ត្រូវបានរៀបរៀងឡើងក្នុងក្របខ័ណ្ឌក្រសួងបរិស្ថាន ដោយមានកិច្ចសហការ និងសម្របសម្រួលយ៉ាងល្អ ពីអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង មានជាអាទិ៍៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍន៍នានា ជាពិសេសអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP)។ ឯកសារនេះ ក៏ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយពីស្ថានប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល តំណាងសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធនានា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាការឯកភាពគ្នាលើលក្ខណៈគោលនយោបាយ យុទ្ធសាស្ត្រ និងបច្ចេកទេស ក្នុងគោលបំណងឱ្យផែនការយុទ្ធសាស្ត្រនេះ ប្រកបដោយភាពជាម្ចាស់ តម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផល និងបង្កើតជាចក្ខុវិស័យរួមសំដៅធានាឱ្យការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានក្នុងតំបន់ការពារធម្មជាតិប្រកបដោយចីរភាព។

តំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា គឺជាផ្នែកមួយដ៏សំខាន់នៃសម្បត្តិធម្មជាតិដ៏អស្ចារ្យរបស់ប្រទេស និងផ្តល់អត្ថប្រយោជន៍ជាច្រើនលើផ្នែក បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ តំបន់ការពារធម្មជាតិមិនត្រឹមតែផ្តល់នូវជីវៈចម្រុះដ៏សំបូរបែប និងជាទីជម្រកសត្វព្រៃប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សហគមន៍ជនបទដែលពឹងអាស្រ័យនឹងធនធានព្រៃឈើ មានដូចជា៖ អាហារ ទីជម្រក ឱសថ និងប្រាក់ចំណូលពីអនុផលព្រៃឈើ។ល។ ជាងនេះទៅទៀត តំបន់ការពារធម្មជាតិប្រទេសកម្ពុជា មានសក្តានុពលយ៉ាងធំធេងក្នុងការប្រែក្លាយទៅជាតំបន់ទេសចរធម្មជាតិ ដែលអាចបង្កើតប្រាក់ចំណូលជូនដល់សហគមន៍មូលដ្ឋានផង និងលើកស្ទួយសេដ្ឋកិច្ចជាតិផង។ ម៉្យាងវិញទៀត តំបន់

ការពារធម្មជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក ក្នុងការចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

បច្ចុប្បន្ន ដោយសារតែការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងប្រទេសកម្ពុជាមានល្បឿនលឿន ហេតុដូច្នេះការគ្រប់គ្រងតំបន់ការពារធម្មជាតិ គម្បីទាមទារឱ្យមានសន្ទុះខ្លាំងផងដែរ ក្នុងការធានាឱ្យបាននូវតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការការពារបរិស្ថាន សំដៅឆ្ពោះទៅរកការអភិវឌ្ឍជាតិដោយចីរភាព។ ក្នុងបរិបទនេះ ការវិនិយោគទៅលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ គម្បីបង្កើនឱ្យស្របទៅតាមតម្រូវការដើម្បីអភិរក្សជីវៈចម្រុះ ក្នុងគោលបំណងធានាបាននូវលំនឹងប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន ក្នុងគោលដៅរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ពិសេសផ្តោតជាសំខាន់ទៅលើក្រុមដែលងាយទទួលរងគ្រោះ។ ដើម្បីសម្រេចបាននូវគោលដៅនេះ កិច្ចសហប្រតិបត្តិការទាំងផ្នែកស្មារតី សម្ភារៈ បច្ចេកទេស និងហិរញ្ញវត្ថុ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល គឺជាកត្តាចាំបាច់មិនអាចខ្វះបាន ដើម្បីរួបរួមគ្នាគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាឱ្យមាននិរន្តរភាព សម្រាប់បន្តផ្តល់ប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

ក្រសួងបរិស្ថានប្តេជ្ញាយ៉ាងមុតមាំ ក្នុងការអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (២០១៧-២០៣១) ដោយខិតខំប្រែក្លាយយុទ្ធសាស្រ្តនេះឱ្យទៅជាផែនការសកម្មភាពជាក់ស្តែង ដែលមានចែងក្នុងគោលបំណងយុទ្ធសាស្រ្តសំខាន់ៗទាំងបួននៃផែនការយុទ្ធសាស្រ្តជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនេះ តាមរយៈការបង្កើនធនធានក្នុងស្រុក ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានា ការបង្កើនប្រសិទ្ធភាពអនុវត្តការងារផ្ទៃក្នុង និងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ សំដៅសម្រេចឱ្យបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងការគោរពដ៏ខ្ពង់ខ្ពស់ និងកត្តវេទិតាដ៏ស្មោះត្រង់ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងណែនាំ គាំទ្រ និងយកចិត្តទុកដាក់ខ្ពស់លើបញ្ហាបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា។

ខ្ញុំក៏សូមថ្លែងអំណរគុណ និងកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងក្រសួងបរិស្ថាន និងមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អ ក្នុងការរៀបចំឯកសារដ៏មានតម្លៃនេះ ឱ្យបានសម្រេចជារូបរាងឡើង។ នេះគឺជាផ្លែផ្កាដ៏ល្អប្រសើរមួយ ដែលបានបដិសន្ធិឡើងក្រោមកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការរួមគ្នា របស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ បានរៀបរៀងឡើងក្រោមមាត្រា១៥ ជំពូកទី៥ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្រោមការដឹកនាំនិងសម្របសម្រួលពីក្រសួងបរិស្ថាន តាមរយៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្ស ធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធនានា ក្នុង អំឡុងពេលដំណើរការកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើន ទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ រួមមានៈ តំណាងសហគមន៍តំបន់ការពារធម្មជាតិ ក្រុមប្រឹក្សាឃុំ ស្រុក ខេត្ត មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកិច្ចការនារី មន្ទីរអភិវឌ្ឍន៍ជនបទ ក្រសួង-ស្ថាប័ន និងវិស័យឯកជនពាក់ព័ន្ធ អង្គការមិន មែនរដ្ឋាភិបាល និងគ្រឹះស្ថានឧត្តមសិក្សាស្រាវជ្រាវ។ល។

ក្រៅពីនេះ ក៏មានការចូលរួមផ្តល់មតិយោបល់យ៉ាងទូលំទូលាយពីអ្នកជំនាញជាតិ និងអន្តរជាតិ ក្នុងដំណើរការរៀបរៀងផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ហើយក៏ទទួលបាន ការគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុផងដែរ ពីគម្រោងមូលនិធិភាពជាដៃគូកាបូនព្រៃឈើ (FCPF) ក្រោម ការសម្របសម្រួលពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។

តំណាងឱ្យក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ សូម សំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលកន្លង មកបានចំណាយពេលវេលាដ៏មានតម្លៃរបស់ខ្លួន ចូលរួមផ្តល់ជាមតិយោបល់ និងធាតុចូលល្អៗ ដែលបាន ធ្វើឱ្យឯកសារយុទ្ធសាស្ត្រនេះ ទទួលបានខ្លឹមសារល្អ និងអាចយកទៅអនុវត្តន៍បាន ហើយអាចចូលរួម សម្រេចទិសដៅគោលនយោបាយយុទ្ធសាស្ត្រស្តីពីកិច្ចគាំពារបរិស្ថាន ការពារអភិរក្សជីវៈចម្រុះ និងការរស់ នៅប្រកបដោយចីរភាពសម្រាប់កម្ពុជា។

# មាតិកា


**សារលិខិត** ........ i

**អារម្ភកថា** ........ iii

**សេចក្តីថ្លែងអំណរគុណ** ........ v

**សេចក្តីសង្ខេប** ........ x

**១. សេចក្តីផ្តើម** ........ **១**

**២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង** ........ **២**

**៣. គោលការណ៍ណែនាំ** ........ **៣**

កការការពារនិងអភិរក្សជាចម្បង ........ ៣

ខ. លើកកម្ពស់សមធម៌ ........ ៣

គ. ការរៀបចំផែនការ និងការគ្រប់គ្រងដោយចំណេះដឹងជាមូលដ្ឋាន ........ ៣

ឃ. ការរៀបចំ និងគ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលអនាគត ........ ៣

ង. កម្រិតគ្រប់គ្រងដែនទេសភាព ........ ៣

**៤. ការវិភាគយុទ្ធសាស្ត្រ** ........ **៤**

៤.១ បរិបទអភិបាលកិច្ច ........ ៤

៤.២ បញ្ហាប្រឈម ........ ៦

៤.៣ ដំណោះស្រាយ ........ ៧

៤ធានានូវតម្លៃវប្បធម៌និងប្រព័ន្ធអេកូឡូស៊ី ១.៣. ........ ៧

៤ធានាតុល្យភាពអាទិភាពរវាងអភិរក្ស និងអភិវឌ្ឍន៍ ២.៣. ........ ៩

៤លើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់គ្រង ៣.៣. ........ ៩

៤ជំរុញការគ្រប់គ្រងដោយប្រសិទ្ធភាព និងប្រសិទ្ធផល ៤.៣. ........ ១០

**៥. គោលដៅយុទ្ធសាស្ត្រ** ........ **១១**

**៥ ៖១គោលដៅយុទ្ធសាស្ត្រ ១. កំណត់អាទិភាពនិងពង្រឹងការការពារនិងអភិរក្សធនធានធម្មជាតិ** ........ ១៤

៥១.១. ធានាការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ បែងចែកតំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រង. ១៤

៥២.១. ពង្រឹងការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង ........ ១៥

៥៣.១. ជំរុញការការពារ ការអភិរក្ស និងការស្តារឡើងវិញនៃជីវៈចម្រុះ ........ ១៦

៥ ៤.១.ពង្រីកកិច្ចសហការប្រតិបត្តិការអន្តរជាតិ ........ ១៦

**៥ ៖២គោលដៅយុទ្ធសាស្ត្រ ២. បង្កើនការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយចីរភាព** ........ ១៧

៥ ១.២.ធ្វើសុខដុមកម្មនៃសកម្មភាពអភិវឌ្ឍន៍ជាមួយនឹងគោលបំណងគ្រប់គ្រងតំបន់ការពារធម្មជាតិ ........ ១៧

៥ការផ្សារភ្ជាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ២.២. ..................... ១៨
៥ ៖៣គោលដៅយុទ្ធសាស្ត្រ ៣. ពង្រីកការចូលរួមនិងបង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ..................... ១៨
៥១.៣. បង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងដំណើរការរៀបចំផែនការគ្រប់គ្រង ..................... ១៩
៥គាំទ្រយន្តការសហការក្នុងការគ្រប់គ្រង ២.៣. ..................... ១៩
៥ពង្រីកឱកាសនៃការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ៣.៣. ..................... ២០
៥ ៖៤គោលដៅយុទ្ធសាស្ត្រ ៤. ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ ..................... ២១
៥១.៤. ធានាឱ្យមានចំនួនមន្ត្រីគ្រប់គ្រាន់ មានសមត្ថភាព និងធនធានសមស្រប ..................... ២១
៥២.៤. បង្កើនកិច្ចសហការសិក្សាស្រាវជ្រាវ រៀបចំផែនការ និងអភិវឌ្ឍន៍គោលនយោបាយ ..................... ២៣
**៦. ការបញ្ជ្រាបយេនឌ័រ** ..................... **២៣**
**៧. ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ** ..................... **២៤**
**៨. ធនធានហិរញ្ញវត្ថុ** ..................... **២៥**
**៩. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ** ..................... **២៧**
**១០. សន្និដ្ឋាន** ..................... **២៨**
**ឧបសម្ព័ន្ធ១ បញ្ជីតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា** ..................... **៣០**
**ឧបសម្ព័ន្ធ២ ផែនទីតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា** ..................... **៣២**
**ឧបសម្ព័ន្ធ៣ ថវិកានិងសូចនាករលទ្ធផលនៃ NPASMP (២០១៧-២០៣១)** ..................... **៣៣**

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| AOP | Annual Operation Plan | ផែនការអនុវត្តន៍ប្រចាំឆ្នាំ |
| CBD | Convention on Biological Diversity | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| CITES | Convention on International Trade in Endangered Species of Wild Flora and Fauna | អនុសញ្ញាអន្តរជាតិស្តីពីពាណិជ្ជកម្មនៃប្រភេទ ក្រុមសត្វ និងក្រុមភូតគាមដែលរងគ្រោះថ្នាក់ |
| CPA | Community Protected Area | សហគមន៍តំបន់ការពារធម្មជាតិ |
| EIA | Environmental Impact Assessment | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ELC | Economic Land Concession | សម្បទានដីសេដ្ឋកិច្ច |
| FA | Forestry Administration | រដ្ឋបាលព្រៃឈើ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| GDEKI | General Directorate of Environmental Knowledge & Information | អគ្គនាយកដ្ឋានរដ្ឋបាល ចំណេះដឹង បរិស្ថាន និងព័ត៌មាន |
| GDLC | General Directorate of Local Community | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន |
| GDANCP | General Directorate of Administration for Nature Conservation and Protection | អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្ស ធម្មជាតិ |
| GEF | Global Environment Fund | មូលនិធិបរិស្ថានពិភពលោក |
| GIS | Geographical Information System | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GMS | Greater Mekong Subregion | មហាអនុតំបន់ទន្លេមេគង្គ |
| ha | Hectare | ហិកតា |
| IBA | Important Bird and Biodiversity Area | តំបន់សារៈសំខាន់បក្សី និងជីវៈចម្រុះ |
| IUCN | International Union for Conservation of Nature | សម្ព័ន្ធអន្តរជាតិ សម្រាប់អភិរក្សធម្មជាតិ |
| KBA | Key Biodiversity Area | តំបន់សារៈសំខាន់ជីវៈចម្រុះ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIST | Management Information System | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| MLMUPC | Ministry of Land Use Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |

| | | |
|---|---|---|
| MOE | Ministry of Environment | ក្រសួងបរិស្ថាន |
| MOT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| NBSAP | National Biodiversity Strategy and Management Plan | ផែនការគ្រប់គ្រង និងយុទ្ធសាស្ត្រជីវៈចម្រុះជាតិ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NP | National Park | ឧទ្យានជាតិ |
| NPASMP | National Protected Area Strategic Management Plan | ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ |
| NSDP | National Sustainable Development Plan | ផែនការអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព |
| NTFP | Non-timber Forest Product | អនុផលព្រៃឈើ |
| PA | Protected Area | តំបន់ការពារធម្មជាតិ |
| PES | Payments for Ecosystem Services | ការទូទាត់តម្លៃសេវាកម្មបរិស្ថាន |
| RAPPAM | Rapid Assessment and Prioritization of Protected Areas Management | ការវាយតម្លៃដោយរហ័សស្ដីពីអាទិភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| REDD+ | Reduced Emissions from Deforestation and Forest Degradation and the role of conservation sustainable management and enhancement of forest carbon stocks | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរិលព្រៃឈើ និងតួនាទីក្នុងការអភិរក្ស ការគ្រប់គ្រងដោយចីរភាព និងការបង្កើនកាបោនស្តុកព្រៃឈើ |
| RS | Rectangular Strategy | យុទ្ធសាស្ត្រចតុកោណ |
| SMART | Spatial Monitoring and Reporting Tool | ឧបករណ៍សម្រាប់ត្រួតពិនិត្យ តាមដាន និងរាយការណ៍ |
| SO( គយស ) | Strategic Objective | គោលដៅយុទ្ធសាស្ត្រ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNFCCC | UN Framework Convention on Climate Change | អនុសញ្ញាក្របខណ្ឌការងារសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ |
| WCAP | World Commission on Protected Areas | សមាគមន៍តំបន់ការពារធម្មជាតិសាកលលោក |
| WS | Wildlife Sanctuary | ដែនជម្រកសត្វព្រៃ |

# សេចក្តីសង្ខេប

បច្ចុប្បន្នប្រទេសកម្ពុជាមានតំបន់ការពារធម្មជាតិចំនួនជាង ៤៦កន្លែង និងរបៀងអភិរក្សជីវៈចម្រុះ ដែលគ្របដណ្តប់លើផ្ទៃដីជាង ៧,៤លានហិកតា (៤១%នៃផ្ទៃដីប្រទេស) ស្ថិតក្នុងដែនយុត្តាធិការរបស់ក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាសេនាធិការគ្រប់គ្រងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាក៏ជាប្រទេសមួយក្នុងចំណោមប្រទេសនានាលើពិភពលោក ដែលមានភាគរយផ្ទៃដីតំបន់ការពារធម្មជាតិខ្ពស់ជាងគេ។ សម្រាប់តំបន់អាស៊ី ប្រទេសប៊ូតានក៏ជាប្រទេសមួយដែលមានភាគរយផ្ទៃដីតំបន់ការពារធម្មជាតិខ្ពស់ប្រហាក់ប្រហែលនិងកម្ពុជាដែរ(ប្រហែល៤០%នៃផ្ទៃដីប្រទេស)។

បច្ចុប្បន្នប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា គឺស្ថិតក្រោមសំពាធយ៉ាងខ្លាំង និងមានការព្រួយបារម្ភអំពីប្រសិទ្ធភាពរបស់ខ្លួនក្នុងការការពារតម្លៃអភិរក្សជីវៈចម្រុះ និងការផ្តល់ឱកាសលើកកម្ពស់ជីវភាពរស់នៅសហគមន៍មូលដ្ឋានប្រកបដោយចីរភាព។ ដូចជាករណីសម្រាប់តំបន់ការពារធម្មជាតិភាគច្រើន នៅក្នុងតំបន់អាស៊ីដែរ ការគំរាមកំហែងជាចម្បងគឺទាក់ទងនឹងការរេចរឹលព្រៃឈើដែលជាដែនទីជម្រក និងការប្រើប្រាស់គ្មាននិរន្តរភាពនៃធនធានធម្មជាតិ ដោយសារកំណើនប្រជាជន និងតម្រូវការទីផ្សារជាលក្ខណៈសកល។ ការបំលែងដីនៅក្នុងតំបន់ការពារធម្មជាតិឱ្យទៅជាតំបន់ដំណាំកសិ-ឧស្សាហកម្ម បានរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរគម្របព្រៃឈើ និងទីជម្រកធម្មជាតិ។ ក្រៅពីនេះ សកម្មភាពអភិវឌ្ឍន៍ សំខាន់ៗផ្សេងៗទៀតនៅក្នុងតំបន់ការពារធម្មជាតិ មានជាអាទិ៍៖ ការសាងសង់ទំនប់វារីអគ្គីសនី ការធ្វើអាជីវកម្មរ៉ែ និងការសាងសង់ផ្លូវថ្នល់ ក៏ជាមូលហេតុនៃការបាត់បង់ជម្រកធម្មជាតិដោយផ្ទាល់ផងដែរ។ ការជះឥទ្ធិពលដោយប្រយោលតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គឺបានបន្ថែមសំពាធទៅលើតំបន់ការពារធម្មជាតិ រួមមាន៖ ការទន្ទ្រានយកដីខុសច្បាប់ និងការប្រើប្រាស់ផល-អនុផលព្រៃឈើ-សត្វព្រៃដោយមិនមាននិរន្តរភាព។ ការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់បង្កឱ្យមានការថយចុះ និងបាត់បង់ប្រភេទសត្វព្រៃក្នុងស្រុកគួរឱ្យកត់សម្គាល់ បណ្តាលឱ្យតំបន់ការពារធម្មជាតិបាត់បង់នូវជីវៈចម្រុះដែលជាវត្ថុបំណងដើមនៃកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ។

ការគំរាមកំហែងមកលើធនធានធម្មជាតិ និងជីវៈចម្រុះ ការប្រឈមចំពោះមុខក្នុងអភិបាលកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិ និងលទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(ឆ្នាំ២០០៨) ឱ្យមានប្រសិទ្ធភាព គឺជាបញ្ហា ដូចមានរៀបរាប់ខាងក្រោម៖

- កង្វះខាតការកំណត់ព្រំប្រទល់(ការចុះបញ្ជិការ) ផែនការគ្រប់គ្រង និងការកំណត់តំបន់គ្រប់គ្រងឱ្យបានច្បាស់លាស់ ដើម្បីកិច្ចការពារតំបន់ស្នូល តំបន់អភិរក្សក្នុងតំបន់ការពារធម្មជាតិ
- លំបាកក្នុងការធានាស្ថិរភាពនៃការកាត់បន្ថយ និងលប់បំបាត់បទល្មើស
- ការចូលរួមវិភាគទាននៃធនធានក្នុងតំបន់ការពារធម្មជាតិនៅមានកម្រិត សម្រាប់លើកកម្ពស់ជីវភាពប្រជាសហគមន៍នៅជនបទ
- មានភាពស្មុគស្មាញក្នុងការដោះស្រាយទំនាស់ការប្រើប្រាស់ដីនៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ
- កិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៅមានកម្រិត

- ការបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់បានគ្រប់គ្រាន់ដល់ឧទ្យានុរក្ស និងមន្ត្រីតំបន់ការពារធម្មជាតិ និងអភិវឌ្ឍន៍សហគមន៍
- មិនទាន់មានថវិកា និងធនធានគ្រប់គ្រាន់ពីរាជរដ្ឋាភិបាល ដើម្បីរក្សាស្ថិរភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងកំណត់យកបញ្ហាជាអាទិភាព ក្នុងការរកដំណោះស្រាយលើភាពប្រឈមនៃបញ្ហាធនធានមនុស្ស និងថវិកានៅមានកម្រិត ដើម្បីធានាសកម្មភាពនៃកិច្ចការពារ និងអភិរក្សតំបន់ការពារធម្មជាតិ ដែលកំពុងទទួលរងការគម្រាមកំហែង។ ដំណោះស្រាយជាបន្ទាន់ ក៏ដោយសារតែតំបន់ទាំងនេះ គឺតំណាងឱ្យគុណតម្លៃខ្ពស់បំផុតនៃការអភិរក្សជីវៈចម្រុះ និងរួមចំណែកក្នុងការចិញ្ចឹមជីវិតរបស់ប្រជាជននៅមូលដ្ឋានឱ្យមាននិរន្តរភាព។

ច្បាប់តំបន់ការពារធម្មជាតិ គឺតម្រូវឱ្យរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលជាត្រីវិស័យក្នុងការជំរុញការរៀបចំផែនការសកម្មភាពគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗសម្រាប់បច្ចុប្បន្ន និងអនាគត។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិមានសមាសភាគសំខាន់ៗ ដូចខាងក្រោម៖

**ចក្ខុវិស័យ៖** ប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា រួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព រួមមានទាំងការកាត់បន្ថយភាពក្រីក្រ ពិសេសតាមរយៈការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានជីវៈចម្រុះ ធនធានធម្មជាតិ និងវប្បធម៌ ព្រមទាំងសេវាប្រព័ន្ធអេកូឡូស៊ី។

**បេសកកម្ម៖** ជាដំណើរឆ្ពោះទៅកាន់ការសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបទៅដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌។

**គោលបំណង៖** ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ មានគោលបំណងដូចខាងក្រោម៖

១. ថែរក្សា និងលើកកម្ពស់ តម្លៃអេកូឡូស៊ី និងវប្បធម៌ ក្នុងតំបន់ការពារធម្មជាតិ
២. លើកកម្ពស់ការចូលរួមការងារ និងការគាំទ្រពីសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងអភិរក្សតំបន់ការពារធម្មជាតិ
៣. អភិវឌ្ឍន៍គំនិតច្នៃប្រឌិតថ្មីៗក្នុងការអភិរក្ស និងការអភិវឌ្ឍ រួមទាំងបង្កើតឱកាសសម្រាប់ចីរភាពវិស័យ អេកូទេសចរណ៍ និងយន្តការហិរញ្ញប្បទាន
៤. ផ្តល់នូវព័ត៌មានពាក់ព័ន្ធជាក់លាក់ និងទាន់ពេលវេលា សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព
៥. ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហការក្នុងភាពជាដៃគូជាមួយនឹងទីភ្នាក់ងាររាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិរក្ស (អង្គការអភិរក្ស) និងដៃគូអភិវឌ្ឍន៍។

| **គោលដៅយុទ្ធសាស្ត្រ(គយស)** | | | |
|---|---|---|---|
| **គយស១**: **កំណត់អាទិភាពនិងពង្រឹងការពារនិងអភិរក្សធម្មជាតិ** | **គយស២**: **លើកកម្ពស់ការគ្រប់គ្រងដោយចីរភាព** | **គយស៣**: **ពង្រីកការចូលរួមរបស់សហគមន៍មូលដ្ឋាន និងបង្កើនផលប្រយោជន៍** | **គយស៤**: **ពង្រឹងសមត្ថភាពស្ថាប័ន និងបង្កើនកិច្ចសហប្រតិបត្តិការ** |
| ➢ ធានាព្រំប្រទល់ ការកំណត់តំបន់គ្រប់គ្រង និងការរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ | ➢ សុខដុមកម្មរវាងការអភិវឌ្ឍ និងការអភិរក្ស | ➢ បង្កើនការចូលរួមពីមូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ | ➢ ធានានូវចំនួនមន្ត្រីគ្រប់គ្រាន់ មានសមត្ថភាព និងធនធានសមស្រប |
| ➢ ពង្រឹងការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង | ➢ ផ្សារភ្ជាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ | ➢ បង្កើត និងគាំទ្រដល់យន្តការសហការគ្រប់គ្រង | ➢ បង្កើនកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពសិក្សាស្រាវជ្រាវ រៀបចំផែនការ និងគោលនយោបាយ |
| ➢ លើកកម្ពស់ការអភិរក្សជីវចម្រុះ និងការស្តារឡើងវិញ | | ➢ ពង្រីកឱកាសសម្រាប់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន | |
| ➢ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ | | | |

គោលដៅយុទ្ធសាស្ត្រទាំងនេះ ក៏ត្រូវបានរៀបចំឡើងដោយអនុលោមតាមបញ្ញត្តិដែលបានស្នើឡើងក្នុងក្រមធនធានធម្មជាតិ និងបរិស្ថានថ្មីផងដែរ។

## គោលដៅយុទ្ធសាស្ត្រ១៖ កំណត់អាទិភាព និងពង្រឹងការការពារនិងអភិរក្សធម្មជាតិ

ក្នុងអំឡុង៥ឆ្នាំខាងមុខ(២០១៧-២០២១)យ៉ាងហោចណាស់ តំបន់ការពារធម្មជាតិ ចំនួន២៥កន្លែង និងការកំណត់របៀងអភិរក្សជីវៈចម្រុះប្រមាណ៥០% នឹងត្រូវបានបោះបង្គោលព្រំ ចុះបញ្ជិការ និងរៀបចំបញ្ចូលនិយាមការ។ ហើយយ៉ាងហោចណាស់ក៏មានតំបន់ការពារធម្មជាតិចំនួន២០កន្លែង ដែលមានតម្លៃអភិរក្សខ្ពស់ត្រូវបានអនុម័តលើការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង ដូចមានចែងក្នុងជំពូកទី៤នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដើម្បីធានាការថែរក្សាតំបន់ស្នូល និងតំបន់អភិរក្សឱ្យជៀសផុតពីការខូចខាតនាពេលអនាគត។ ក្រៅពីនេះ តំបន់ការពារធម្មជាតិភាគច្រើននឹងប្រតិបត្តិការដោយប្រើប្រាស់ផែនការគ្រប់គ្រងសាមញ្ញ ដែលមានគោលបំណងច្បាស់លាស់ តាមយុទ្ធសាស្ត្រជាអាទិភាព និងការកំណត់ថវិកា។

ការពង្រឹងការអនុវត្តច្បាប់តាមរយៈការពង្រឹងសមត្ថភាពដល់មន្ត្រីឧទ្យានុរក្ស យ៉ាងហោចណាស់សម្រាប់រយៈពេល៥ឆ្នាំខាងមុខគឺមានមន្ត្រីចំនួន ៥០០នាក់ ត្រូវបានឆ្លងតាមវគ្គបណ្តុះបណ្តាលជំនាញ និងការបំពាក់ដោយសម្ភារៈល្បាតទំនើប។ ការលើកកម្ពស់ជំនាញ និងចំណេះដឹង ជាមួយជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានសម្រាប់គោលដៅពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងគាំទ្រពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធគឺជាការចាំបាច់លើការពង្រឹងកិច្ចសហប្រតិបត្តិការ។

សារៈសំខាន់នៃតំបន់ការពារធម្មជាតិគឺផ្តល់ជម្រកធម្មជាតិសម្រាប់សត្វព្រៃ ដែលបច្ចុប្បន្នកំពុងទទួលរងហានីភ័យនៅឡើយ ហើយក្រសួងបរិស្ថានបាននឹងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការអភិរក្ស ដៃគូរអភិវឌ្ឍន៍ និងសាកលវិទ្យាល័យនានា ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវចំណេះដឹងមូលដ្ឋាន គាំទ្រដល់ការអភិរក្ស និងផែនការសកម្មភាពស្តារឡើងវិញ សម្រាប់ដោះស្រាយការគំរាមកំហែងដល់ប្រភេទសត្វ និងរុក្ខជាតិនានា និងប្រព័ន្ធអេកូឡូស៊ី។ ម៉្យាងវិញទៀត កិច្ចខិតខំប្រឹងប្រែងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីប្រសិទ្ធភាពគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ ព្រមទាំងការចែករំលែកបទពិសោធន៍ល្អៗ គំនិតច្នៃប្រឌិត និងបច្ចេកវិទ្យាថ្មីៗ ក៏ជាទិសដៅចម្បង សម្រាប់ការចូលរួមអនុវត្តន៍ផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ។

## គោលដៅយុទ្ធសាស្ត្រ២៖ លើកកម្ពស់ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយចីរភាព

ការផ្ទេរដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ ទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រង គឺចាំបាច់ត្រូវបន្តកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ដើម្បីធានាថាដីសម្បទានសេដ្ឋកិច្ចដែលស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន បានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិធានច្បាប់នានា ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន និងការកាត់បន្ថយការគម្រាមកំហែង ដែលអាចជះឥទ្ធិពលដល់តំបន់ការពារធម្មជាតិ។ គ្រប់សកម្មភាពអភិវឌ្ឍន៍នៅក្នុងតំបន់ការពារធម្មជាតិនឹងត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់តាមរយៈការអនុវត្តច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធានាដល់សង្គតភាពរវាងការអភិវឌ្ឍ និងការអភិរក្ស។

ការកើនឡើងនៃផ្ទៃដីតំបន់ការពារធម្មជាតិដែលស្ថិតក្នុងដែនយុត្តាធិការរបស់ក្រសួងបរិស្ថាន បង្កើតបានជាដែនទេសភាពអភិរក្សដែលមានភាពទូលំទូលាយជាប់ៗគ្នា និងជាឱកាសក្នុងការរៀបចំឡើងនូវរបៀងអភិរក្សជីវៈចម្រុះ ដើម្បីសម្រួលដល់បន្លាស់ទីរបស់ពពួកសត្វព្រៃធំៗ ឬសត្វព្រៃបន្លាស់ទីតាមរដូវកាល ពីតំបន់ការពារធម្មជាតិមួយទៅកាន់តំបន់ការពារធម្មជាតិមួយផ្សេងទៀត។ ផែនទីប្រព័ន្ធអេកូឡូស៊ីនឹងត្រូវបានប្រើប្រាស់សម្រាប់កំណត់សក្តានុពលទីតាំង និងភ្ជាប់ចន្លោះសំខាន់ៗសម្រាប់របៀងអភិរក្សជីវៈចម្រុះ ដើម្បីបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីមួយពេញលេញ។

## គោលដៅយុទ្ធសាស្ត្រ៣៖ ពង្រីកការចូលរួម របស់សហគមន៍មូលដ្ឋាន និងបង្កើនផលប្រយោជន៍

កិច្ចខិតខំប្រឹងប្រែងមួយក្នុងការចូលរួមអនុវត្តគោលនយោបាយវិមជ្ឈការ អាជ្ញាធរមូលដ្ឋាននឹងទទួលបានការបណ្តុះបណ្តាល និងការកសាងសមត្ថភាពលើយន្តការនៃកិច្ចសហការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមទាំងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ផងដែរ។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងនឹងផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់នៃការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិប្រកបដោយចីរភាពតាមរយៈការបង្កើនជីវភាពរស់នៅ ការអភិវឌ្ឍតំបន់សក្តានុពលទេសចរណ៍ធម្មជាតិ និងតំបន់បេតិកភណ្ឌធម្មជាតិ។

ការផ្តល់ឱកាសដ៏មានអត្ថន័យ និងដោយផ្ទាល់ដល់បុរស និងស្ត្រី ក្នុងការចូលរួមផ្តួចផ្តើមគំនិតប្រើប្រាស់ធនធានដោយចីរភាពក្នុងតំបន់ការពារធម្មជាតិ វានឹងជួយកាត់បន្ថយសម្ពាធលើធនធានធម្មជាតិផងព្រមទាំងបង្កើនជម្រើសលើកកម្ពស់ជីវភាពដល់សហគមន៍មូលដ្ឋានផង។ ការអភិវឌ្ឍគំនិតនេះជាឱកាស

ឱ្យមានការផ្លាស់ប្ដូរលើការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តភាពចេញ ដោយសហគមន៍មូលដ្ឋានអាចមានគំនិតចូលរួមសហប្រតិបត្តិការក្នុងការងារតាមដាន និងអាចធានាសុវត្ថិភាពធនធានក្នុងតំបន់ការពារធម្មជាតិធម្មជាតិទៀតផង។ កិច្ចការទាំងនេះរួមមាន ការណែនាំបច្ចេកវិទ្យាថ្មីៗក្នុងការបង្កើនទិន្នផលកសិកម្ម ការរៀបចំជំនួញខ្នាតតូច ការទទួលបាននូវហិរញ្ញប្បទានសម្រាប់ចូលរួមក្នុងកម្មវិធីស្ដារព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ និងការត្រួតពិនិត្យតាមដានព្រមទាំងបង្កើតឡើងនូវផលិតផលអេកូទេសចរណ៍**"គុណភាពខ្ពស់-ផលប៉ះពាល់ទាប"** ក្រោមការចូលរួមយ៉ាងសកម្មពីសហគមន៍មូលដ្ឋាន។

## គោលដៅយុទ្ធសាស្ត្រ៤: ពង្រឹងសមត្ថភាពស្ថាប័ននិងបង្កើនកិច្ចសហប្រតិបត្តិការ

ការវិនិយោគថវិកាបន្ថែមពីរាជរដ្ឋាភិបាល គឺមានសារៈសំខាន់ណាស់ សម្រាប់បំពាក់សម្ភារបរិក្ខារដល់មន្ត្រីជំនាញទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំហ្វឹកហ្វឺន ត្រៀមលក្ខណៈ និងលើកទឹកចិត្តដល់មន្ត្រីអនុវត្តន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះនៅតាមតំបន់ការពារធម្មជាតិ នាពេលបច្ចុប្បន្ននៅកម្ពុជា។ សមត្ថភាពបច្ចេកទេសនៃមន្ត្រីជំនាញចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាបន្ទាន់ ដើម្បីធ្វើអភិបាលកិច្ចគាំទ្រដល់ការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីតំបន់ការពារធម្មជាតិ និងអាជ្ញាធរមូលដ្ឋាន ដែលមានតួនាទីសំខាន់ក្នុងការចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិ។ មជ្ឈមណ្ឌលបណ្ដុះបណ្ដាលថ្នាក់តំបន់ចំនួនបីនឹងត្រូវរៀបចំបង្កើតឡើង ក្នុងគោលបំណងប្រមូលផ្ដុំបណ្ដុះបណ្ដាលដល់អាជ្ញាធរមូលដ្ឋាន ឧទ្យានុរក្ស និងមន្ត្រីតំបន់ការពារធម្មជាតិ ឱ្យកាន់តែមានភាពជិតស្និទ្ធ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

កិច្ចសហការសកម្មរវាងបណ្ដាក្រសួងពាក់ព័ន្ធ ជាមួយនឹងសាកលវិទ្យាល័យ អង្គការអភិរក្ស និងដៃគូអភិវឌ្ឍន៍នានាគឺជាការចាំបាច់ក្នុងការកៀរគរធនធាន សម្រាប់គាំទ្រដល់ការពង្រីកបន្ថែមនូវមេរៀនបទពិសោធន៍ល្អៗក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ កិច្ចការទាំងនេះរួមមាន ការឯកភាពគ្នាក្នុងការកំណត់អាទិភាពរួមសម្រាប់ការងារអនាគត ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានអំពីការត្រួតពិនិត្យតាមដាន និងរាយការណ៍អំពីជីវៈចម្រុះ និងការគាំទ្របង្កើតឡើងនូវមូលដ្ឋានទិន្នន័យអភិរក្សថ្នាក់ជាតិ នៅក្រសួងបរិស្ថាន សម្រាប់ផ្ដល់ព័ត៌មានរៀបចំផែនការគ្រប់គ្រងតាមតំបន់ការពារធម្មជាតិនីមួយៗ។

## ធនធានហិរញ្ញវត្ថុ

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ(២០១៧-២០៣១) ត្រូវបានប៉ាន់ប្រមាណនូវតម្រូវការឱ្យមានហិរញ្ញប្បទានបន្ថែម សម្រាប់ដំណើរការអនុវត្តក្នុងរយៈពេល៥ឆ្នាំដំបូង(២០១៧-២០២១)សរុបប្រមាណ៤៦,៨(សែសិបប្រាំមួយក្បៀសប្រាំបីលានដុល្លាអាមេរិច) បន្ថែមពីលើថវិកាជាតិបច្ចុប្បន្នទាំងលើប្រាក់បៀវត្ស និងចំណាយប្រតិបត្តិការនានារបស់ក្រសួងបរិស្ថាន។

យុទ្ធសាស្ត្រក្នុងការកៀរគរធនធាននឹងត្រូវបានបង្កើតឡើង ដោយប្រើសំណុំពិពិធកម្មប្រភពថវិកានានា ដើម្បីដោះស្រាយនូវតម្រូវការបន្ទាន់សម្រាប់តំបន់ការពារធម្មជាតិ។ បច្ចុប្បន្នមិនមានយន្តការរួមណាមួយសម្រាប់ប្រមូល និងបង្វែរចំណូលផ្ទាល់ពីថ្លៃចូលទស្សនា ផាកពិន័យ ឬពន្ធផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិលើសកម្មភាពប្រតិបត្តិការ រៀបចំហេដ្ឋារចនាសម្ព័ន្ធ ឬកិច្ចប្រឹងប្រែងក្នុងការស្ដារឡើងវិញប្រព័ន្ធអេកូឡូស៊ីឡើយ។ ការធ្វើកំណែទម្រង់សារពើពន្ធនឹងត្រូវបានយកចិត្តទុកដាក់ពិចារណា ដើម្បីបង្វែរថវិកាទាំងនេះ និងចំណូលដទៃទៀត ទៅក្នុងថវិកាសម្រាប់ចំណាយប្រតិបត្តិ

ការលើតំបន់ការពារធម្មជាតិ។ ថវិកាទាំងនេះអាចប្រើប្រាស់បានដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ដើម្បីចំណាយលើសកម្មភាពនៅក្នុងតំបន់ការពារធម្មជាតិបន្ថែមពីលើថវិកាជាតិដែលមានស្រាប់។ លើសពីនេះ ចំណូល និងចំណាយផ្សេងៗដែលទទួលបានពីតំបន់ការពារធម្មជាតិ ត្រូវតែបញ្ជ្រាបចូលតាមចរន្តនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងថវិកាជាតិ។

នៅពេលដែលការគ្រប់គ្រងបានត្រឹមត្រូវ តំបន់ការពារធម្មជាតិ គឺជាតំណាងឱ្យយុទ្ធសាស្ត្រមួយដ៏មានប្រសិទ្ធភាព និងប្រសិទ្ធផលបំផុត ក្នុងការថែរក្សាប្រព័ន្ធអេកូឡូស៊ី សម្រាប់ចូលរួមដោះស្រាយបញ្ហាប្រឈមជាសកល គឺការកាត់បន្ថយភាពក្រីក្រ ការបន្សាំ និងការកាត់បន្ថយទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងជាប្រភពទ្រទ្រង់ និងផ្តល់សេវាកម្មបរិស្ថាន។ ទោះបីជាការវិនិយោគដំបូងលើការគ្រប់គ្រងតំបន់ការពារធម្មជាតិមានតម្លៃខ្ពស់ក៏ដោយ តែវានឹងបានទទួលផលប្រយោជន៍មហិមាត្រឡប់មកវិញ លើប្រព័ន្ធអេកូឡូស៊ី សង្គម និងសេដ្ឋកិច្ច។

## ១. សេចក្តីផ្តើម

បច្ចុប្បន្នកម្ពុជាមានតំបន់ការពារធម្មជាតិចំនួនច្រើនជាង ៤៦ កន្លែង ចែកចេញជា ៨ប្រភេទ[1] និងចំនួនរបៀងអភិរក្សជីវៈចម្រុះដែលបានបង្កើតថ្មីៗនេះ ដោយគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៧,៤លាន ហិកតា (៤១%នៃផ្ទៃដីប្រទេស) ស្ថិតនៅក្រោមដែនយុត្តាធិការរបស់ក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានជាសេនាធិការ។ ឧបសម្ព័ន្ធ១ បង្ហាញអំពីប្រភេទ ឈ្មោះ និងផ្ទៃដីនៃតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា និងឧបសម្ព័ន្ធ២ បង្ហាញអំពីផែនទីតំបន់ការពារធម្មជាតិកម្ពុជា។

កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសនានាលើពិភពលោក ដែលមានភាគរយផ្ទៃដីតំបន់ការពារធម្មជាតិខ្ពស់ជាងគេ ហើយនៅតំបន់អាស៊ីមានប្រទេសប៊ូតានមួយដែរ មានភាគរយផ្ទៃដីតំបន់ការពារធម្មជាតិខ្ពស់ប្រហាក់ប្រហែលនឹងកម្ពុជាដែរ(៤០%នៃផ្ទៃដីសរុប)។ គោលដៅជីវៈចម្រុះ Aichi១១ នៃអនុសញ្ញាស្តីពីជីវៈចម្រុះ(CBD Aichi Biodiversity Target #11) បានអំពាវនាវដល់ប្រទេសជាសមាជិកឱ្យការពារតំបន់ដីគោក និងតំបន់ដីសើម ឱ្យបានយ៉ាងតិច១៧% និងសម្រាប់តំបន់សមុទ្រ និងតំបន់ឆ្នេរឱ្យបានយ៉ាងតិច១០% ត្រឹមឆ្នាំ២០២០។ ប្រទេសកម្ពុជាមានតំបន់ការពារធម្មជាតិដីគោក និងដីសើម លើសពីគោលដៅកំណត់ ហើយកម្ពុជាកំពុងតែបន្តកំណត់តំបន់ការពារធម្មជាតិសមុទ្រ និងឆ្នេរបន្ថែមទៀត ដើម្បីធានាកិច្ចការពារតំបន់ឆ្នេរ និងសមុទ្រឱ្យបានគ្រប់ជ្រុងជ្រោយ។

ប្រទេសកម្ពុជាស្ថិតនៅជ្រោយឥណ្ឌូចិន ដែលត្រូវបានពិភពលោកទទួលស្គាល់ជាសកលថា មានតំបន់ជីវៈចម្រុះសំខាន់ៗ និងមានផ្ទៃដីព្រៃឈើធម្មជាតិធំជាងគេនៅក្នុងទ្វីបអាស៊ី។ គេបានសន្និដ្ឋានថាមានផ្ទៃដីព្រៃឈើស្តុកកាបូនប្រហែល៣០% ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា ហើយវាដើរតួនាទីសំខាន់ក្នុងការស្តុកទុកកាបូនព្រៃឈើ ដែលរួមចំណែកលើកកម្ពស់កម្មវិធីរេដបូក ប្រព័ន្ធធានាសុវត្ថិភាព និងការសម្រេចបានជាផលប្រយោជន៍រួម (ឧទា. គាំទ្រទាំងការអភិរក្សជីវៈចម្រុះ និងការបង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន)។ ក្រៅពីនេះកម្ពុជាក៏មានតំបន់អាទិភាពរបៀងអភិរក្សជីវៈចម្រុះចំនួនប្រាំក្នុងចំណោមតំបន់អាទិភាពចំនួនប្រាំបួន នៃមហាអនុតំបន់ទន្លេមេគង្គ។ តំបន់ការពារធម្មជាតិកម្ពុជាបានផ្តល់ទីជម្រកសម្រាប់សត្វព្រៃប្រមាណជិត២% នៃប្រភេទសត្វព្រៃដែលកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក ដែលមានក្នុងបញ្ជីក្រហមរបស់អង្គការ IUCN រួមមាន ថនិកសត្វចំនួន៣៤ប្រភេទ បក្សីចំនួន៣៩ប្រភេទ និងល្មូនចំនួន២០ប្រភេទ។ តំបន់ដែលមានផលិតភាពពាណិជ្ជកម្មខ្ពស់បំផុតក្នុងប្រទេសកម្ពុជា ក៏រួមមានតំបន់ការពារធម្មជាតិនៅក្នុងនោះដែរ រួមមាន៖ តំបន់ឋាបនីជីវមណ្ឌលទន្លេសាប និងតំបន់ការពារទេសភាពអង្គរ។

ប្រព័ន្ធតំបន់ការពារធម្មជាតិកម្ពុជាមានសារៈសំខាន់សម្រាប់ជីវៈចម្រុះថ្នាក់តំបន់ និងពិភពលោក ហើយក៏ជាផ្នែកមួយនៃសម្បត្តិធម្មជាតិដ៏សំខាន់របស់ប្រទេស។ តាមការប៉ាន់ស្មាន ៤០% នៃសេដ្ឋកិច្ចពិភពលោក និង៨០% នៃសេចក្តីត្រូវការរបស់អ្នកក្រីក្រ គឺបានមកពីធនធានជីវៈចម្រុះ ហើយជីវៈចម្រុះ

[1] តំបន់ឧទ្យានជាតិ តំបន់ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់ស្នូលនៃឋបនីយជីវមណ្ឌល តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់ឧទ្យានជាតិសមុទ្រ

នេះទៀតសោតក៏បង្កើនលទ្ធភាពបន្សាំ និងបង្កើនភាពធន់ទ្រាំទៅនឹងបញ្ហាប្រឈមរបស់ពិភពលោក ពិសេសគឺការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ តំបន់ការពារធម្មជាតិក៏បានផ្តល់នូវផលិតផល និងសេវាកម្មចម្រុះយ៉ាងសំបូរបែបដល់សហគមន៍ជនបទ ដែលពឹងអាស្រ័យលើធនធានព្រៃឈើ ដូចជា៖ ប្រូតេអ៊ីន ឱសថ និងអនុផលព្រៃឈើ។ល។ កិច្ចការពារនិងថែរក្សាតំបន់ការពារធម្មជាតិទាំងនេះ នឹងជួយដល់កំណើនសេដ្ឋកិច្ចប្រជាជននាពេលអនាគត ហើយក៏ចូលរួមដល់ការអភិវឌ្ឍជាតិផងដែរ។ ការកាត់បន្ថយភាពក្រីក្រគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយសារៈសំខាន់ធនធានក្នុងតំបន់ការពារធម្មជាតិគឺអាចនឹងរួមចំណែកប្រកបដោយប្រសិទ្ធភាព និងគាំទ្រនិរន្តភាពនៃជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងការអភិវឌ្ឍតាមវិស័យ តាមរយៈលទ្ធផលវាស់វែងបាននៃការកាត់បន្ថយភាពក្រីក្រ។

យោងតាមសន្ទស្សន៍នៃការអភិវឌ្ឍរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) បានបង្ហាញថា៖ ប្រទេសកម្ពុជាឈរនៅលំដាប់ថ្នាក់ទី១៤៣ ក្នុងចំណោមប្រទេស១៨៨ ហើយនៅឆ្នាំ២០១៥ ប្រទេសកម្ពុជាសម្រេចបាននូវការថយចុះនៃភាពក្រីក្រពី ៥៣% ក្នុងឆ្នាំ២០០៤ មក ២០% ក្នុងឆ្នាំ២០១២ ដោយបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហវត្ស (លំដាប់ថ្នាក់លេខ៥ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍) និងទទួលបាននូវសូចនាករសង្គមកាន់តែប្រសើរ (លំដាប់ថ្នាក់លេខ១ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច)។ ដូច្នេះ ដើម្បីជានានិរន្តភាពនៃវឌ្ឍនភាពនេះ ប្រទេសកម្ពុជាគួរតែវិនិយោគលើធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធដែលជាមូលដ្ឋានយុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយចីរភាព និងអភិវឌ្ឍន៍បៃតងនាពេលអនាគត។

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិគឺជាឯកសារគោល និងជាយុទ្ធសាស្ត្រទីមួយសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា។ ឯកសារនេះក៏ជាឯកសារណែនាំមួយក្នុងចំណោមឯកសារយុទ្ធសាស្ត្រជាតិផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងបំពេញបន្ថែមដល់បណ្តាយុទ្ធសាស្ត្រជាតិផ្សេងទៀត។

## ២. ចក្ខុវិស័យ បេសកកម្ម និងគោលបំណង

**ចក្ខុវិស័យ៖** ប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា រួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងនោះរួមទាំងការកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានជីវៈចម្រុះ ធនធានធម្មជាតិ វប្បធម៌ និងសេវាប្រព័ន្ធអេកូឡូស៊ី។

**បេសកកម្ម៖** ជាដំណើរឆ្ពោះទៅកាន់ការសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបទៅដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌។

**គោលបំណង៖** ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ មានគោលបំណងដូចខាងក្រោម៖

១.ថែរក្សា និងលើកកម្ពស់ តម្លៃអេកូឡូស៊ី និងវប្បធម៌ ក្នុងតំបន់ការពារធម្មជាតិ

២.លើកកម្ពស់ការចូលរួមការងារ និងការគាំទ្រពីសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងអភិរក្សតំបន់ការពារធម្មជាតិ

៣.អភិវឌ្ឍន៍គំនិតច្នៃប្រឌិតថ្មីៗក្នុងការអភិរក្ស និងអភិវឌ្ឍន៍ រួមមានឱកាសសម្រាប់ចីរភាពវិស័យអេកូទេសចរណ៍ និងយន្តការហិរញ្ញប្បទាន

៤. ផ្តល់នូវព័ត៌មានពាក់ព័ន្ធជាក់លាក់ និងទាន់ពេលវេលា សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព

៥. ពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសហការក្នុងភាពជាដៃគូជាមួយនឹងទីភ្នាក់ងាររាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិរក្ស (អង្គការអភិរក្ស) និងដៃគូអភិវឌ្ឍន៍។

## ៣. គោលការណ៍ណែនាំ

គោលការណ៍ណែនាំសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលអនាគត រួមមានៈ

### ក. ការការពារនិងអភិរក្សជាចម្បង

ការអភិរក្សជីវៈចម្រុះគឺជាគោលបំណងចម្បងសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ទាំងដែនគោក និងដែនសមុទ្រ ហើយសកម្មភាពទាំងនេះ ត្រូវចាត់ទុកជាសកម្មភាពអាទិភាព។ សមិទ្ធផលទាំងនេះអាចសម្រេចបានតាមរយៈការគ្រប់គ្រង ការប្រើប្រាស់ដីដោយស្របច្បាប់ និងបទបញ្ញត្តិនានា ការកំណត់ព្រំប្រទល់ ការកំណត់តំបន់ប្រើប្រាស់និងគ្រប់គ្រង ការផ្តល់អាជ្ញាប័ណ្ណ ការពង្រឹងការអនុវត្តច្បាប់ ការវាយតម្លៃ និងការតាមដានត្រួតពិនិត្យ ដែលមានចែងក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ(២០០៨) និងបញ្ញត្តិផ្សេងៗទៀត ដែលនឹងមានចែងក្នុងក្រមធនធានធម្មជាតិ និងបរិស្ថានថ្មី។

### ខ. លើកកម្ពស់សមធម៌

សម្រាប់ប្រជាជនក្រីក្រ និងក្រុមជនងាយរងគ្រោះ តំបន់ការពារធម្មជាតិជាប្រភពផ្តល់នូវសន្តិសុខស្បៀង និងផ្តល់ឱកាសសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ យើងនឹងត្រូវខិតខំប្រឹងប្រែង ដើម្បីធានាថាពួកគាត់ទាំងនេះបានចូលរួម ក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងទទួលបានផលប្រយោជន៍ពីការចូលរួមទាំងនេះ។

### គ. ការរៀបចំផែនការ និងការគ្រប់គ្រងដោយចំណេះដឹងជាមូលដ្ឋាន

ចំណេះដឹងល្អៗអាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើផែនការ ការរៀបចំ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលតំណាងឱ្យសារព័ន្ធមជ្ឈដ្ឋានធម្មជាតិដ៏ល្អនៃប្រព័ន្ធអេកូឡូស៊ី។ ការយល់ដឹងពីប្រភេទសត្វព្រៃ ទីជម្រក និងប្រព័ន្ធអេកូឡូស៊ី គឺផ្តល់ជាចំណេះដឹងមូលដ្ឋានមួយផ្នែក រីឯការយកចិត្តទុកដាក់លើសង្គម សេដ្ឋកិច្ច និងនយោបាយ រួមជាមួយនឹងប្រពៃណី និងចំណេះដឹងមូលដ្ឋាននឹងផ្តល់ជាព័ត៌មានសំខាន់មួយផ្នែកទៀត។

### ឃ. ការរៀបចំ និងគ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលអនាគត

បណ្តាញតំបន់ការពារធម្មជាតិ គឺត្រូវរៀបចំ និងគ្រប់គ្រង ឱ្យស្របទៅតាមបម្រែបម្រួលនៃប្រព័ន្ធអេកូឡូស៊ីនាពេលអនាគត ដោយរួមទាំងការព្យាករណ៍ពីការប្រែប្រួលនៃការកើនឡើងកំដៅភពផែនដី។ កិច្ចការទាំងនេះ គឺតម្រូវឱ្យប្រើប្រាស់វិធីសាស្រ្តបន្សាំក្នុងការអភិរក្សធនធានតាមរយៈការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីប្រមូលផ្តុំនូវចំណេះដឹងថ្មីៗ ដើម្បីទទួលបានព័ត៌មានជាក់លាក់ សម្រាប់ជាជំនួយដល់អ្នករៀបចំផែនការអភិរក្ស។

### ង. កម្រិតគ្រប់គ្រងដែនទេសភាព

ដែនទេសភាពដ៏ធំទូលំទូលាយ ត្រូវបានគ្រប់គ្រងដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល ហើយដែលដែនទេសភាពនោះបានផ្តល់នូវធនធាន និងសេវាកម្មអេកូឡូស៊ី។ កិច្ចការនេះត្រូវសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីបំពេញបន្ថែមសមត្ថភាព និងបង្កើនការយល់ដឹងទាក់ទងនឹងកិច្ចការពារតំបន់ការពារធម្មជាតិ និងអភិរក្សជីវៈចម្រុះឱ្យបានកាន់តែមានប្រសិទ្ធភាព។

# ៤. ការវិភាគយុទ្ធសាស្ត្រ

## ៤.១ បរិបទអភិបាលកិច្ច

តំបន់ការពារធម្មជាតិជាតិបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន តាមព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ស្ដីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ។ ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ បានផ្ដល់ជាមូលដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិកម្ពុជា ពិសេសក្នុងច្បាប់ស្ដីពីតំបន់ការពារធម្មជាតិបានលើកកម្ពស់ឱ្យមានការប្រើប្រាស់តាមចំណាត់ថ្នាក់ IUCN សម្រាប់ការរៀបចំតំបន់ការពារធម្មជាតិ ដោយមានការកំណត់និងបែងចែកតំបន់គ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ ដើម្បីធានាបាននូវ៖

- ផ្ដល់កិច្ចការពារឱ្យបានគ្រប់ជ្រុងជ្រោយដល់បណ្ដាតំបន់ដែលមានតម្លៃអភិរក្សខ្ពស់
- អភិវឌ្ឍន៍ឱ្យបានសមស្របបណ្ដាតំបន់ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់
- បង្កើនការចូលរួមឱ្យបានពេញលេញ និងផ្ដល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច

ជំពូកទី៥នៃច្បាប់ ស្ដីពីតំបន់ការពារធម្មជាតិ តម្រូវឱ្យរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលជាត្រីវិស័យជួយដល់ការរៀបចំផែនការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ និងការអនុវត្តច្បាប់ និងត្រូវធានាឱ្យមានភាពស៊ីសង្វាក់នឹងយុទ្ធសាស្ត្រជាតិដទៃៗទៀត។

នៅមានច្បាប់ជាច្រើនទៀតដែលមានការពាក់ព័ន្ធដូចជា ច្បាប់ស្ដីពីព្រៃឈើ(២០០២) ច្បាប់ស្ដីពីជលផល(២០០៦) ច្បាប់ស្ដីពីគ្រប់គ្រងធនធានទឹក(២០០៧) ច្បាប់ភូមិបាល(២០០១) និងច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(១៩៩៦) ដែលមានឥទ្ធិពលដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា។ ក្រៅពីនេះក៏មានគោលនយោបាយ និងយុទ្ធសាស្ត្រអំពីការអភិវឌ្ឍ និងការអភិរក្សជាច្រើនទៀត រួមមាន៖

- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨)
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៣-២០១៨)
- ផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតង(២០១៣-២០៣០)
- ផែនការយុទ្ធសាស្ត្រស្ដីពីការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣)
- ផែនការយុទ្ធសាស្ត្ររេដបូកជាតិកម្ពុជា(២០១៧-២០២៦) និង
- យុទ្ធសាស្ត្រជាតិបរិស្ថាន និងផែនការសកម្មភាព (២០១៦-២០២៣) កំពុងរៀបចំ។

យុទ្ធសាស្ត្រជាតិរេដបូកកម្ពុជា(NRS)ផ្ដល់ជាផែនទីបង្ហាញផ្លូវ សម្រាប់ការអនុវត្តគោលនយោបាយ និងវិធានការដោះស្រាយនានា ទៅលើការបាត់បង់និងរេចរិលព្រៃឈើ។ NRS គឺមានការពាក់ព័ន្ធជាពិសេសទៅ NPASMP ដែលនឹងធ្វើឱ្យប្រសើរឡើងតាមរយៈជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីធានាថាផ្ទៃដីព្រៃឈើ(និងការស្តុកកាបូនរបស់ពួកគេ) បានផ្ដល់នូវផលប្រយោជន៍ដល់ជីវៈចម្រុះ និងអត្ថប្រយោជន៍ជាច្រើនដទៃទៀត។ ម្យ៉ាងវិញទៀត យុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងគឺមានសារៈសំខាន់ណាស់ សម្រាប់ធានាតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍនៅក្នុងការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព រួមទាំងតំបន់ការពារធម្មជាតិទាំងឡាយ និងលើកទឹកចិត្តធ្វើឥណទានកាបោនសម្រាប់ទ្រទ្រង់ការអភិវឌ្ឍ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់សច្ចាប័នអនុសញ្ញាអន្តរជាតិមួយចំនួន ដែលឆ្លុះបញ្ចាំងពីការ

គ្រប់គ្រងតំបន់ការពារធម្មជាតិនៅកម្ពុជា ហើយអនុសញ្ញាទាំងនេះរួមមាន៖ អនុសញ្ញាស្តីពីជីវៈចម្រុះ (CBD) អនុសញ្ញាអន្តរជាតិស្តីពីពាណិជ្ជកម្មនៃប្រភេទក្រុមសត្វ និងក្រុមរុក្ខជាតិដែលរងគ្រោះថ្នាក់ (CITES) អនុសញ្ញានៃក្របខ័ណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) អនុសញ្ញាស្តីពីសារៈសំខាន់នៃដីសើមអន្តរជាតិ(អនុសញ្ញារ៉ាមសារ)។

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** គឺជាយន្តការអន្តរក្រសួង ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់តាមបែបវិមជ្ឈការ និងសហវិមជ្ឈការក្នុងក្របខណ្ឌទូទាំងប្រទេស។ កំណែទម្រង់នេះមានការជាប់ពាក់ព័ន្ធជាពិសេសក្នុងការលើកកម្ពស់តួនាទីទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ រួមទាំងតំបន់ការពារធម្មជាតិផងដែរ។

ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដឹកនាំរៀបចំជាមួយអន្តរក្រសួង ក្នុងការពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្តជាតិស្តីពីជីវៈចម្រុះ និងផែនការសកម្មភាព ដែលបានចាប់ផ្តើមរៀបចំតាំងពីឆ្នាំ២០០២មក ហើយបានធ្វើបច្ចុប្បន្នភាពរួចរាល់ព្រមទាំងទទួលបានការអនុម័តនៅឆ្នាំ២០១៦ ហើយចំណែកផែនការយុទ្ធសាស្រ្តជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនេះ ក៏បានបន្សុីគ្នាទៅតាមគោលដៅជាយុទ្ធសាស្រ្ត និងអនុសាសន៍អាទិភាពសំខាន់ៗសម្រាប់តំបន់ការពារធម្មជាតិផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានជូនដំណឹងនូវបំណងក្នុងការបង្កើតក្រមធនធានធម្មជាតិ និងបរិស្ថានកាលពីខែមីនា ឆ្នាំ២០១៥ ហើយដែលក្រមនេះនឹងបង្កើតឡើងនូវគោលការណ៍ជាផ្លូវការ ដើម្បីណែនាំការអនុវត្តច្បាប់ដែលមានស្រាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ និងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ក្រមនេះក៏បានលើកស្នើឡើងនូវវិសោធនកម្ម ដើម្បីជានាសុខដុមកម្ម និងកំណត់ច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់បណ្តាក្រសួងពាក់ព័ន្ធក្នុងអភិបាលកិច្ចធនធានធម្មជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ចឱ្យក្រសួងបរិស្ថានដឹកនាំ គ្រប់គ្រង ការពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងពិនិត្យលើការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។ ជាផ្នែកមួយនៃកំណែទម្រង់យុត្តាធិការក្នុងការគ្រប់គ្រងធនធានធម្មជាតិ រាជរដ្ឋាភិបាលបានធ្វើការផ្ទេរព្រៃការពារ (ពីមុននេះគឺស្ថិតក្នុងយុត្តាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) មកក្រសួងបរិស្ថានគ្រប់គ្រងវិញ។ ទន្ទឹមនឹងនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានទទួលសិទ្ធគ្រប់គ្រងតំបន់សម្បទានដីសេដ្ឋកិច្ចដែលមាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ ហើយដែលពីមុននេះគឺស្ថិតក្នុងយុត្តាធិការរបស់ក្រសួងបរិស្ថាន (អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦)។

ដើម្បីការប្រព្រឹត្តទៅតាមតួនាទី និងភារកិច្ចថ្មី ក្រសួងបរិស្ថានបានរៀបចំសម្រួលរចនាសម្ព័ន្ធជាថ្មី (អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦)។ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ គឺនៅតែជាអង្គភាពទទួលបន្ទុកក្នុងកិច្ចការពារ និងអភិរក្សជីវៈចម្រុះ និងពិនិត្យមើលការប្រើប្រាស់ធនធានធម្មជាតិ និងការគ្រប់គ្រងទិន្នន័យទាំងនេះប្រកបដោយចីរភាព នៅក្នុងប្រព័ន្ធតំបន់

ការពារធម្មជាតិកម្ពុជាដដែល ដែលឥឡូវមាននាយកដ្ឋានចំណុះចំនួនប្រាំពីរ[2] សម្រាប់បំពេញតួនាទី ភារកិច្ចខាងលើ។ អគ្គនាយកដ្ឋានដែលទើបបង្កើតថ្មីគឺ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន មាននាយកដ្ឋានចំណុះចំនួនបួន[3] ដែលមានតួនាទីគ្រប់គ្រង សម្របសម្រួល ជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីពង្រឹងការចូលរួមគ្រប់គ្រង ការការពារ និងការអភិរក្សតំបន់ការពារធម្មជាតិ។ អគ្គនាយកដ្ឋានរដ្ឋបាលចំណេះដឹង និងព័ត៌មានបរិស្ថាន មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទិន្នន័យបរិស្ថាន (នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ) និងដឹកនាំសម្របសម្រួលឱ្យមានភាពរីកចម្រើនលើវិស័យអប់រំបរិស្ថាន។ កិច្ចសហការយ៉ាងជិតស្និទ្ធរវាងអគ្គនាយដ្ឋានទាំងបីនេះ គឺមានសារៈសំខាន់ណាស់ក្នុងការអនុវត្តយុទ្ធសាស្ត្រដែលបានលើកស្នើឡើងនេះ និងសកម្មភាពពាក់ព័ន្ធទៅនឹងសហប្រតិបត្តិការក្នុងការគ្រប់គ្រង ការរៀបចំផែនទី ការលើកកម្ពស់ការយល់ដឹង និងការអប់រំបរិស្ថាន។

## ៤.២ បញ្ហាប្រឈម

ការផ្ទេរកាតព្វកិច្ចគ្រប់គ្រងតំបន់ព្រៃអភិរក្សពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មកក្រសួងបរិស្ថានក្នុងពេលថ្មីៗនេះ បានធ្វើឱ្យទំហំផ្ទៃដីតំបន់ការពារធម្មជាតិកើនឡើងទ្វេរដង គឺប្រមាណ ៤១% នៃផ្ទៃដីប្រទេសកម្ពុជាទាំងមូល។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនេះ គឺជាបញ្ហាប្រឈមសម្រាប់ក្រសួងបរិស្ថាន ទាំងធនធានមនុស្ស និងថវិកានៅមានកំណត់។ ជាងនេះទៅទៀត តំបន់ការពារធម្មជាតិទាំងនោះកំពុងតែបន្តស្ថិតនៅក្រោមសម្ពាធ និងការគំរាមកំហែង ដែលបញ្ហាទាំងនេះ វានៅតែជាក្តីបារម្ភលើការគ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន នូវស្ថេរភាព និងធានាសុវត្ថិភាពក្នុងការរក្សាបានប្រសិទ្ធភាព និងសារៈសំខាន់ជាសកល និងសម្រាប់ជាតិ ព្រមទាំងការផ្តល់ឱកាសសម្រាប់ធានាដល់ការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

តំបន់ការពារធម្មជាតិនៅកម្ពុជា ដែលរំពឹងថាជាតំបន់ជួយដល់ប្រសិទ្ធភាពក្នុងការអភិរក្សជីវៈចម្រុះ និងរួមចំណែកដល់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនោះ ក៏ជួបប្រទះការគំរាមកំហែង ដូចតំបន់ការពារធម្មជាតិដទៃទៀតនៅតំបន់អាស៊ីដែរ គឺដោយសារការរេចរឹលទីជម្រក ការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តភាព រួមផ្សំនឹងកំណើនប្រជាជន និងតម្រូវការពីទីផ្សារពិភពលោកផងដែរ។

ការកាប់ព្រៃឈើ និងការបំបែកទីជម្រកជាផ្នែកតូចៗ បានធ្វើឱ្យប៉ះពាល់ដល់តំបន់ការពារធម្មជាតិ និងតួនាទីប្រព័ន្ធអេកូឡូស៊ីរបស់វា។ សកម្មភាពអភិវឌ្ឍន៍នានានៅក្នុងតំបន់ការពារធម្មជាតិ ដូចជា៖ ការដាំដំណាំកសិ-ឧស្សាហកម្ម ការសាងសង់ទំនប់វារីអគ្គិសនី ការធ្វើអាជីវកម្មរ៉ែ និងការសាងសង់ផ្លូវជាដើម គឺជាផលប៉ះពាល់ដោយផ្ទាល់ ដែលបានធ្វើឱ្យបាត់បង់នូវទីជម្រកធម្មជាតិ។ ចំណែកឯផលប៉ះពាល់ដោយប្រយោលវិញ រួមមាន៖ ផ្លូវថ្មីអាចធ្វើឱ្យមានសម្ពាធដល់តំបន់ការពារធម្មជាតិ ដែលរួមមានការរានដីខុសច្បាប់ ការចូលប្រមាញ់សត្វព្រៃ និងរុករកអនុផលព្រៃឈើមិនមាននិរន្តភាព។ ការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់ដោយសារតែតម្រូវការសត្វព្រៃកើនឡើង ទាំងក្នុងស្រុក និងពីប្រទេសជិតខាង បានធ្វើឱ្យចំនួនសត្វព្រៃមានការថយចុះយ៉ាងខ្លាំង និងបណ្តាលឱ្យតំបន់ការពារធម្មជាតិបាត់បង់នូវជីវៈចម្រុះដែលជាវត្ថុបំណងដើមនៃការបង្កើតតំបន់ការពារធម្មជាតិ។

---

[2] នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ. នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងកើតទន្លេមេគង្គ នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប នាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប នាយកដ្ឋានអភិរក្សសមុទ្រ និងតំបន់ឆ្នេរ នាយកដ្ឋានអធិការកិច្ចនិងពង្រឹងការអនុវត្តច្បាប់។

[3] នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ. នាយកដ្ឋានជីវភាពសហគមន៍ នាយកដ្ឋានតំបន់បេតិកភ័ណ្ឌ នាយកដ្ឋានទេសចរណ៍ធម្មជាតិ។

នៅពេលដែលការគំរាមកំហែងជារូបវ័ន្តនៅតែមានគួរឱ្យកត់សម្គាល់ បញ្ហាប្រឈមដ៏ធំ និងចំពោះមុខ គឺទាក់ទងទៅអភិបាលកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិ និងលទ្ធភាពនៃការអនុវត្តយុទ្ធសាស្រ្តជាតិថ្មីៗ ក៏ដូចជាការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិឱ្យមានប្រសិទ្ធភាព។ បញ្ហាចំបងៗទាំងនេះ រួមមាន៖

- កង្វះខាតការកំណត់ព្រំប្រទល់(ការចុះបញ្ជិការ) ផែនការគ្រប់គ្រង និងការកំណត់បែងចែកតំបន់គ្រប់គ្រងឱ្យបានច្បាស់លាស់ក្នុងកិច្ចការពារ តំបន់ស្នូល តំបន់អភិរក្សក្នុងតំបន់ការពារធម្មជាតិ។ ជាលទ្ធផលនៃសកម្មភាពអភិវឌ្ឍន៍មួយចំនួន គឺស្ថិតនៅភាពផុយស្រួយនៅឡើយ ហើយអាចធ្វើឱ្យមានផលប៉ះពាល់ដល់ជីវៈចម្រុះយ៉ាងខ្លាំង។ លើសពីនេះ សិទ្ធិក្នុងការកាប់ដីធ្លីក្នុងតំបន់ការពារធម្មជាតិមិនទាន់មានភាពច្បាស់លាស់ ដែលជាមូលហេតុមួយបណ្តាលឱ្យមានទំនាស់ និងសកម្មភាពរំលោភទន្ទ្រាន ហើយធ្វើឱ្យតំបន់ការពារធម្មជាតិមានការបាត់បង់ផ្ទៃដី
- ពិបាករក្សាបានស្ថេរភាពនៃការកាត់បន្ថយ និងលប់បំបាត់ការគំរាមកំហែងមកលើតំបន់ការពារធម្មជាតិ ពិសេសទាក់ទងទៅនឹងការកាប់ព្រៃឈើ ការចោះដើមឈើជងជ័រ ការបរបាញ់សត្វព្រៃ ការដាក់អន្ទាក់សត្វព្រៃ ការនេសាទត្រីខុសច្បាប់ ការរានដីព្រៃ និងការប្រមូលអនុផលព្រៃឈើដោយខុសច្បាប់ និងការធ្វើអន្តោប្រវេសន៍ចូលមករស់នៅក្នុងតំបន់ការពារធម្មជាតិ
- កិច្ចសហប្រតិបត្តិការនៅមានកម្រិត រវាងក្រសួងពាក់ព័ន្ធនឹងការទទួលខុសត្រូវលើការគ្រប់គ្រងធនធានធម្មជាតិ ឬការរៀបចំដែនដី
- ការបណ្តុះបណ្តាលបច្ចេកទេសនៅមានកម្រិត សម្រាប់ឧទ្យានុរក្សដែលមានភារកិច្ចទទួលខុសត្រូវក្នុងការអនុវត្តផែនការសកម្មភាពប្រចាំថ្ងៃលើការគ្រប់គ្រងទូទាំងតំបន់ការពារធម្មជាតិនីមួយៗ ក៏ដូចជាកម្រិតជំនាញបច្ចេកទេសគ្រប់គ្រងសម្រាប់មន្ត្រីតំបន់ការពារធម្មជាតិផងដែរ
- ចំណុចចុងក្រោយ ហើយប្រហែលជាសំខាន់បំផុតនោះគឺ ថវិការាជរដ្ឋាភិបាលមិនទាន់ឆ្លើយតបឱ្យបានគ្រប់គ្រាន់នៅឡើយដើម្បីថែរក្សាជីវៈចម្រុះ និងពង្រឹងការអភិរក្សប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលបច្ចុប្បន្នកើនទំហំស្មើរតែមួយភាគបីនៃផ្ទៃប្រទេស។

## ៤.៣ ដំណោះស្រាយ

រាជរដ្ឋាភិបាលទទួលស្គាល់ថា ធនធានមនុស្ស និងថវិកានៅមានកម្រិតនៅឡើយ ហើយការកំណត់អាទិភាពសកម្មភាពនានា សម្រាប់ជួយទប់ស្កាត់ជាបន្ទាន់ទៅនឹងការគំរាមកំហែងមកលើតំបន់ការពារធម្មជាតិណាដែលមានតម្លៃអភិរក្សជីវចម្រុះខ្ពស់វាជាគោលដៅចាំបាច់ ដើម្បីធានាបាននូវនិរន្តរភាពដល់ជីវភាពសហគមន៍មូលដ្ឋាន ដែលបច្ចុប្បន្នកំពុងជួបបញ្ហាប្រឈមនៅឡើយ។

### ៤.៣.១ ធានានូវតម្លៃវប្បធម៌និងប្រព័ន្ធអេកូឡូស៊ី

ការកំណត់ព្រំប្រទល់ និងការចុះបញ្ជិកា សម្រាប់តំបន់ការពារធម្មជាតិនីមួយៗ និងតំបន់របៀងអភិរក្សជីវៈចម្រុះ គឺជាតម្រូវការបំផុត ដែលពុំទាន់បានបញ្ចប់នៅឡើយ។ ទន្ទឹមនេះ គោលការណ៍ណែនាំក្នុងការរៀបចំកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនីមួយៗគឺជាការចាំបាច់បំផុត[4]។

[4] ច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ បានបែងចែកជា៤តំបន់គ្រប់គ្រងគឺ៖ ១.តំបន់ស្នូល(តម្លៃអភិរក្សខ្ពស់ និងហាមមិនឱ្យចូល) ២.តំបន់អភិរក្ស (តម្លៃអភិរក្សខ្ពស់ ហើយការចូលតំបន់នេះមានកម្រិតបំផុតលើកលែងតែជូនដំណឹងទៅអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាមុន) ៣.តំបន់

ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង មិនត្រឹមតែមានសារៈសំខាន់ក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ដីនៅតំបន់ការពារធម្មជាតិប៉ុណ្ណោះទេ ថែមទាំងអាចកំណត់តំបន់គោលដៅសម្រាប់ការអនុវត្តរេដបូកផងដែរ ដូចជា៖ ដាំព្រៃឈើឡើងវិញ ឬបង្កើនកាបោនស្តុកព្រៃឈើ។ ចំណែកឯវគ្គបណ្តុះបណ្តាលើការអនុវត្តច្បាប់ និងការកសាងសមត្ថភាពនឹងត្រូវបានបង្កើនល្បឿនសម្រាប់ជួយដល់មន្ត្រីឧទ្យានុរក្ស និងអាជ្ញាធរមូលដ្ឋាន ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការហាមសកម្មភាពខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ។ កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋានក៏មានសារៈសំខាន់ផងដែរ ក្នុងការឱ្យពួកគេចូលរួមក្នុងការត្រួតពិនិត្យ និងរាយការណ៍ ផ្តល់ឱកាសលើជីវភាពរស់នៅ និងដើម្បីលើកកំពស់ការយល់ដឹងសម្រាប់គោលបំណងតំបន់ការពារធម្មជាតិនិងបទប្បញ្ញត្តិច្បាប់។

ចំណែកឯផែនការគ្រប់គ្រងតាមតំបន់ការពារធម្មជាតិនីមួយៗគឺនៅមានកម្រិតនៅឡើយ ព្រោះផែនការគ្រប់គ្រងទាំងនេះបានទទួលជំនួយបច្ចេកទេស និងថវិកា តាមរយៈបណ្តាគម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាប៉ុណ្ណោះ ដូច្នេះនៅពេលដែលគម្រោងបានបញ្ចប់ សកម្មភាពសំខាន់ៗមិនបានបន្តអនុវត្តន៍ឡើយ។ ហេតុនេះ តម្រូវការចាំបាច់ជាក់ស្តែងគឺ ការរក្សាសុវត្ថិភាពនៃព្រំប្រទល់តំបន់ការពារធម្មជាតិដែលមានស្រាប់ បង្កើតគោលការណ៍ណែនាំ អនុវត្តការកំណត់និងបែងចែកតំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រងសាមញ្ញតាមតំបន់ការពារធម្មជាតិនីមួយៗ ពិសេសចាប់ផ្តើម សម្រាប់តំបន់ការពារធម្មជាតិណាដែលមានអាទិភាព។

បច្ចុប្បន្នការពង្រឹងការអនុវត្តច្បាប់ និងការដើរល្បាត គឺជាសកម្មភាពចំបងសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយសារតែមានបទល្មើសព្រៃឈើកើតមានស្ទើរតែគ្រប់ប្រព័ន្ធតំបន់ការពារធម្មជាតិ។ យោងតាមកិច្ចស្រាវជ្រាវក្រៅផ្លូវការនៃមន្ត្រីតំបន់ការពារធម្មជាតិបានបង្ហាញថា ការគំរាមកំហែងមកលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមមាន៖ ការកាប់ឈើ ការបរបាញ់និងដាក់អន្ទាក់សត្វ ការនេសាទខុសច្បាប់ និងការរានដីព្រៃឈើធ្វើជាកម្មសិទ្ធ ព្រមទាំងសកម្មភាពអភិវឌ្ឍន៍ និងការដកហូតអនុផលព្រៃឈើមិនមាននិរន្តភាព។ ឧទា. បទល្មើសព្រៃឈើត្រូវបានទទួលស្គាល់ថាបានកើតមានឡើងស្ទើរតែគ្រប់ឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ។ ហេតុនេះ តម្រូវការជាបន្ទាន់ មិនត្រឹមតែការពង្រឹងការអនុវត្តច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន តាមរយៈការផ្តល់ឱកាសនូវជម្រើសមុខរបរចិញ្ចឹមជីវិត និងការលើកកម្ពស់ការយល់ដឹងទាក់ទងនឹងលិខិតបទដ្ឋានច្បាប់ និងគោលនយោបាយអភិរក្សតំបន់ការពារធម្មជាតិ ក៏ត្រូវតែយកចិត្តទុកដាក់ជាបន្ទាន់ផងដែរ។

តំបន់ការពារធម្មជាតិគឺមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការផ្តល់ទីជម្រកធម្មជាតិសម្រាប់សត្វព្រៃ និងប្រភេទរុក្ខជាតិនានា ហើយបច្ចុប្បន្នកំពុងរងហានីភ័យ។ ក្រសួងបរិស្ថាននឹងសហការជាមួយក្រសួងពាក់ព័ន្ធ អង្គការអភិរក្ស និងសាកលវិទ្យាល័យនានា ដើម្បីពង្រឹងចំណេះដឹងមូលដ្ឋានសម្រាប់គាំទ្រដល់ផែនការសកម្មភាពអភិរក្ស និងស្តារធនធានជីវៈចម្រុះឡើងវិញ សម្រាប់ឆ្លើយតបទៅនឹងការគំរាមកំហែងដែលកំពុងកើតមានលើប្រភេទសត្វ-រុក្ខជាតិនានា និងប្រព័ន្ធអេកូឡូស៊ីនៅតំបន់ការពារធម្មជាតិ។

កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិរក្សតំបន់ការពារធម្មជាតិ ក៏នឹងត្រូវបានពង្រឹងពង្រីកផងដែរ ជាពិសេសជាមួយបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីចែករំលែកនូវមេរៀនបទពិសោធន៍ បច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតថ្មីៗ។

---

ប្រើប្រាស់ដោយចីរភាព (តម្លៃអភិវឌ្ឍន៍សេដ្ឋកិច្ចខ្ពស់ដែលរួមចំណែកដល់ការបង្កើនជីវភាពសហគមន៍មូលដ្ឋាន) និង៤.តំបន់សហគមន៍ (សម្រាប់អភិវឌ្ឍន៍ដីសេដ្ឋកិច្ចសង្គមនៅសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច)។

### ៤.៣.២ ធានាតុល្យភាពអាទិភាពរវាងអភិរក្ស និងអភិវឌ្ឍន៍

យោងតាមច្បាប់តំបន់ការពារធម្មជាតិ ២០០៨ រាជរដ្ឋាភិបាលកម្ពុជា អាចចេញលិខិតអនុញ្ញាតក្នុងសកម្មភាពអភិវឌ្ឍន៍ និងវិនិយោគនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ ប៉ុន្តែទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានសមស្រប។ ដូច្នេះហើយទើបក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងតំបន់ការពារធម្មជាតិមានការផ្តល់ជាសម្បទានដីសេដ្ឋកិច្ចមួយចំនួន សម្រាប់គម្រោងវិនិយោគផ្នែក កសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងពេលដែលពុំទាន់មានការបែងចែកតំបន់គ្រប់គ្រងនៅឡើយនោះ បានបង្កជាបញ្ហាប្រឈមមួយចំនួន ដែលមានករណីខ្លះសកម្មភាពអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងចំលើទីតាំងសំខាន់ៗនៃតំបន់ការពារធម្មជាតិ ហើយបានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សារៈសំខាន់នៃតម្លៃជីវៈចម្រុះ។

បច្ចុប្បន្នការបញ្ឈប់ការអនុញ្ញាតផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី និងការពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ដោយរាជរដ្ឋាភិបាលកម្ពុជា ជាឱកាសបង្កើនល្បឿនក្នុងការកំណត់ និងបែងចែកតំបន់គ្រប់គ្រងឱ្យបានច្បាស់លាស់ រវាងតំបន់អភិរក្ស និងតំបន់អភិវឌ្ឍន៍នៅតាមតំបន់ការពារធម្មជាតិនីមួយៗ ដើម្បីធានាដល់ការរួមចំណែកនៃសម្បទានដីសេដ្ឋកិច្ច ក្នុងការបង្កើនជីវភាពរស់នៅដល់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច(ដូចមានចែងនៅក្នុងច្បាប់តំបន់ការពារធម្មជាតិ)។ ក្រសួងបរិស្ថាននឹងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការត្រួតពិនិត្យសកម្មភាពសម្បទានដីសេដ្ឋកិច្ចដែលមានសុពលភាព ដោយពង្រឹងតាមគោលការណ៍ច្បាប់ ដើម្បីធានាថា សម្បទានដីសេដ្ឋកិច្ចបានផ្តល់ផលប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ច ការអភិរក្ស និងរួមចំណែកជួយលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។

ប្រព័ន្ធតំបន់ការពារធម្មជាតិគួរតែជាតំណាងនូវប្រភេទសត្វ-រុក្ខជាតិនិងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែលតម្រូវឱ្យមានកិច្ចការពារ។ ក្រៅពីនេះ ប្រព័ន្ធតំបន់ការពារធម្មជាតិត្រូវតែមានរបៀងអភិរក្សជីវៈចម្រុះសម្រាប់តភ្ជាប់ពីតំបន់ការពារធម្មជាតិមួយទៅតំបន់ការពារធម្មជាតិមួយទៀត ដើម្បីឱ្យតំបន់ការពារធម្មជាតិមានផ្ទៃដីទូលាយ និងធានាកុំឱ្យមានការកាត់ផ្តាច់ទីជម្រក និងងាយស្រួលសម្រាប់ប្រភេទសត្វព្រៃធំៗស្វែងរកចំណី ពិសេសសត្វបន្លាស់ទីតាមរដូវកាលមានភាពងាយស្រួលរស់នៅ។ ការធ្វើឱ្យប្រសើរឡើងនៃរបៀងតភ្ជាប់តំបន់ការពារធម្មជាតិមួយទៅនឹងតំបន់ការពារធម្មជាតិមួយទៀតនេះ គឺជាសកម្មភាពដែលមានប្រសិទ្ធភាពបំផុត សម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួងបរិស្ថាននឹងប្រើប្រាស់ផែនទីតំបន់អេកូឡូស៊ី ដើម្បីកំណត់ឱកាសអភិរក្សក្នុងកម្រិតដែនទេសភាពទាំងនៅតំបន់របៀងអភិរក្សជីវៈចម្រុះ និងរវាងបណ្តាតំបន់ការពារធម្មជាតិដែលមានស្រាប់ ពិសេសការកំណត់អត្តសញ្ញាណជម្រើសឱ្យបានល្អបំផុតសម្រាប់របៀងអភិរក្សជីវៈចម្រុះ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែលមានសារៈសំខាន់។

### ៤.៣.៣ លើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់គ្រង

វិធីសាស្ត្រសកម្មបន្ថែមនឹងត្រូវបានប្រើក្នុងការជំរុញការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើម្បីរួមគ្នាគ្រប់គ្រង ដោយគោរពតាមតម្រូវការ និងសេចក្តីប្រាថ្នារបស់ពួកគាត់ ក្នុងគោលដៅលើកកម្ពស់ទាំងការងារអភិរក្សសម្រាប់តំបន់ការពារធម្មជាតិ និងការបង្កើនជម្រើសមុខរបររបស់សហគមន៍មូលដ្ឋាន។បទពិសោធន៍ស្តីពីការបង្កើតតំបន់សហគមន៍ការពារធម្មជាតិ(CPAs) និងការប្រើធនធានធម្មជាតិតាមលក្ខណៈប្រពៃណី(មិនធ្វើពាណិជ្ជកម្ម)នឹងជួយពង្រឹងដល់កិច្ចខិតខំប្រឹងប្រែងសហការគ្នានៅក្នុងការ

គ្រប់គ្រងតំបន់ការពារធម្មជាតិ។ ម៉្យាងទៀត ការពង្រីកឱកាសសម្រាប់ជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងអត្ថប្រយោជន៍ដល់សហគមន៍មូលដ្ឋាននឹងក្លាយជាការរួមវិភាគទានយ៉ាងសំខាន់ ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសមធម៌យេនឌ័រ។ ឧទា. វិសាលភាពអភិវឌ្ឍន៍បន្ថែម ដូចជាសក្តានុពលបង្កើតអេកូទេសចរណ៍នៅក្នុងប្រទេសកម្ពុជា មិនត្រឹមតែជាប្រភពបន្ថែមប្រាក់ចំណូលសម្រាប់សហគមន៍មូលដ្ឋាន និងការគ្រប់គ្រងតំបន់ការពារប៉ុណ្ណោះទេ ប៉ុន្តែវាជាឧបករណ៍មួយដើម្បីលើកកម្ពស់ និងបង្កើនការយល់ដឹងពីសារៈសំខាន់នៃតំបន់ការពារធម្មជាតិ សម្រាប់ភ្ញៀវទេសចរក្នុងស្រុកនិងបរទេស។

ក្រសួងបរិស្ថានបាននឹងកំពុងអនុវត្តតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ ដែលដឹកនាំដោយគណៈកម្មាធិការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយក្នុងពេលថ្មីៗនេះ ក្រសួងបានធ្វើប្រតិភូកម្មជូនដល់អាជ្ញាធរថ្នាក់ក្រោមជាតិ នូវមុខងារមួយចំនួនដែលទាក់ទងនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ រួមមាន៖ ការចូលរួមគ្រប់គ្រងសហគមន៍ដល់អាជ្ញាធរឃុំ/សង្កាត់ និងការទទួលខុសត្រូវក្នុងការលើកកម្ពស់ការយល់ដឹង អភិវឌ្ឍន៍ជីវភាពរស់នៅ និងពង្រឹងការអនុវត្តច្បាប់ជូនដល់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ (ប្រកាសលេខ៣៦ និង៣៧ របស់ក្រសួងបរិស្ថាន ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦) និងសារាចរណែនាំលេខលេខ០៥ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីវិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ។ កំណែទម្រង់ទាំងនេះនឹងធ្វើឱ្យការធ្វើផែនការគ្រប់គ្រង ការអនុវត្ត និងការពង្រឹងការអនុវត្តច្បាប់កាន់តែជិតស្និទ្ធជាមួយនឹងសហគមន៍ដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ។

### ៤.៣.៤ ជំរុញការគ្រប់គ្រងដោយប្រសិទ្ធភាព និងប្រសិទ្ធផល

ក្នុងពេលថ្មីៗនេះផ្ទៃដីតំបន់ការពារធម្មជាតិមានការកើនឡើងទ្វេដង តំបន់ទាំងនេះស្ថិតក្រោមដែនយុត្តាធិការនៃក្រសួងបរិស្ថានដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានជាសេនាធិការ។ ហេតុនេះ ការធ្វើឱ្យប្រសើរឡើងទាំងសមត្ថភាព និងធនធាន ដល់អគ្គនាយកដ្ឋានទាំងពីរគឺជាការចាំបាច់ ដើម្បីធានាសុវត្ថិភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល សម្រាប់ជាប្រយោជន៍រួមដល់ប្រជាពលរដ្ឋកម្ពុជាក្នុងពេលបច្ចុប្បន្ន និងអនាគត។

ការផ្តល់បន្ថែមដោយនាយករដ្ឋមន្ត្រីនូវមន្ត្រីឧទ្យានុរក្សចំនួន៣០០នាក់ទៀត លើចំនួនឧទ្យានុរក្សដែលមានស្រាប់ និងការផ្ទេរមន្ត្រីបច្ចេកទេសមួយចំនួនមកពីរដ្ឋបាលព្រៃឈើ ព្រមទាំងការធ្វើប្រតិភូកម្មការគ្រប់គ្រងតំបន់ការពារធម្មជាតិដល់អាជ្ញាធរថ្នាក់ក្រោមជាតិ បានជួយសម្រាលបន្ទុកក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិដែលបានពង្រីកវិសាលភាពនេះ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានសេសសល់នូវបញ្ហាប្រឈមសំខាន់ៗ ដូចជា៖ កម្រិតជំនាញនៃមន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (មន្ត្រីជំនាញGDANCP GDLC និងមន្ទីរបរិស្ថានខេត្ត-ក្រុង)គឺនៅមានកម្រិតនៅឡើយ ក្នុងលទ្ធភាពការគ្រប់គ្រង សម្របសម្រួលនឹង គាំទ្រដើម្បីឆ្លើយតបតាមតម្រូវការនៅមូលដ្ឋានក្នុងការរៀបចំផែនការ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានឱ្យមាននិរន្តរភាពក្នុងតំបន់ការពារធម្មជាតិ។ ម៉្យាងវិញទៀត ភាពប្រទាក់ក្រឡា និងស្មុគស្មាញនៃប្រព័ន្ធធម្មជាតិ គឺទាមទារឱ្យមន្ត្រីមានសមត្ថភាពជំនាញទាំងផ្នែកវិទ្យាសាស្ត្រ ផ្នែកសង្គម និងការស្រាវជ្រាវ ដែលបញ្ហាទាំងនេះ គឺជាប្រការសំខាន់សម្រាប់បង្កើនសមត្ថភាពមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីផ្តល់ការណែនាំ និងបណ្តុះបណ្តាលដល់មន្ត្រីជំនាញថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន។ ប្រធានបទជាអាទិភាព រួមមាន៖ ការគ្រប់គ្រងសត្វព្រៃ ការធ្វើផែនទីប្រព័ន្ធអេកូឡូស៊ី និងការសិក្សាតម្លៃនៃធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

ទិន្នន័យគោលអំពីជីវៈចម្រុះដែលមានស្រាប់នៅក្នុងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា មានគុណភាពមិនដូចគ្នាទេ តំបន់ការពារធម្មជាតិណាដែលមានការគាំទ្រមូលនិធិ និងជំនួយបច្ចេកទេសពីខាង

ក្រៅជាទូទៅគឺមានគុណភាពល្អ ក្រៅពីនេះគឺគុណភាពនៅមានកម្រិត។ កង្វះខាតកិច្ចសហការ និងការចែករំលែកទិន្នន័យ និងព័ត៌មានមានស្រាប់ នៅមានការពិបាក ដើម្បីស្វែងរកបានសម្រាប់គោលបំណងនៃការរៀបចំផែនការ និងការគ្រប់គ្រង។ ការវាយតម្លៃធនធានជីវៈចម្រុះសារឡើងវិញគឺជាមូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដោយផ្តល់នូវទិន្នន័យដែលមានសារៈសំខាន់សម្រាប់អ្នកគ្រប់គ្រងអាចស្វែងយល់ និងដំណោះស្រាយបញ្ហាទាក់ទងទៅនឹងការប្រែប្រួលបរិស្ថាន។ ជាការចាំបាច់ផងដែរ ក្នុងការជំរុញឱ្យមានការវាយតម្លៃតាមបែបវិទ្យាសាស្ត្រសាមញ្ញមួយសម្រាប់ធ្វើការតាមដាននូវប្រភេទជីវៈចម្រុះ ដែលក្រុមឧទ្យានុរក្ស ក៏ដូចជាក្រុមសហគមន៍មូលដ្ឋានអាចអនុវត្តន៍បានក្នុងសកម្មភាពការងារជាទូទៅរបស់ពួកគេ។ ស្ថាប័នសិក្សាស្រាវជ្រាវ អង្គការអភិរក្ស និងដៃគូអភិវឌ្ឍន៍នានា គួរត្រូវបានលើកទឹកចិត្ត និងសម្របសម្រួល ដើម្បីរួមចំណែកដល់ការបង្កើតប្រព័ន្ធវាយតម្លៃតាមបែបវិទ្យាសាស្ត្រសម្រាប់គ្រប់តំបន់ការពារធម្មជាតិទាំងអស់។

ផ្នែកមួយក្នុងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធបច្ចេកវិទ្យាទំនើប គួរតែយកចិត្តខ្ពស់ផងដែរ ក្នុងការផ្តល់នូវឧបករណ៍ចាំបាច់សម្រាប់ការអនុវត្ត និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋានមួយដែលសមស្រប។ ប្រព័ន្ធនេះនឹងផ្តល់ព័ត៌មានអំពីការសិក្សាស្រាវជ្រាវ ការរៀបចំផែនការ និងការរៀបចំគោលនយោបាយ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ប្រតិបត្តិការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

អាទិភាពមួយសម្រាប់ការវាយតម្លៃធនធាន គឺជាការវាយតម្លៃលើសារៈសំខាន់នៃធនធានធម្មជាតិដែលមាននៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ និងរៀបចំចងក្រងជាឯកសារចំណាត់ថ្នាក់ អំពីសារៈសំខាន់នៃធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិទាំងនោះ ដោយថ្លឹងថ្លែងអំពីអត្ថប្រយោជន៍ឬតម្លៃ ការវិភាគចំណេញ-ខាត ដែលអាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ពិចារណាលើការអភិរក្ស ឬការវិនិយោគដើម្បីអភិវឌ្ឍន៍។ ការវាយតម្លៃធនធានធម្មជាតិគួរតែរួមបញ្ចូលទាំងការផ្តល់ជាផលិតផល និងជាសេវាកម្ម (ឧទា. ឈើ អុស អនុផលព្រៃឈើ និងផលិតផលកសិកម្ម) និងសេវានិយ័តកម្ម (ឧទា. ការស្តុកកាបោន និងទឹក)។ ការវិភាគសេដ្ឋកិច្ចរបៀបនេះ គឺជាគន្លឹះក្នុងការទ្រទ្រង់ការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្រាប់តំបន់ការពារធម្មជាតិ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតង។ អាទិភាពសម្រាប់ការអភិវឌ្ឍគោលនយោបាយមួយ គឺដើម្បីធានាឱ្យមានការយល់ដឹងអំពីច្បាប់ធនធានធម្មជាតិ និងគោលនយោបាយ និងការលើកកម្ពស់ឱ្យទទួលស្គាល់ពីគុណតម្លៃនៃតំបន់ការពារធម្មជាតិ ក្នុងការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ី និងការធានាជីវភាពរស់នៅរបស់សហគមន៍ជនបទ។ ប្រការទាំងនេះនឹងមានចែងក្នុងក្រមធនធានធម្មជាតិនិងបរិស្ថានថ្មី ដើម្បីប្រែក្លាយទស្សនទានទាំងនេះទៅជាការអនុវត្តជាក់ស្តែង។

## ៥. គោលដៅយុទ្ធសាស្ត្រ

ដើម្បីដោះស្រាយការគំរាមកំហែង និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិកម្ពុជា ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ បានធ្វើការបែងចែកជាបួនគោលដៅយុទ្ធសាស្ត្រ ហើយគោលដៅយុទ្ធសាស្ត្រនីមួយៗសុទ្ធតែមានគោលបំណងជាក់លាក់បន្ថែមមួយចំនួន។ គោលដៅយុទ្ធសាស្ត្រទាំងនេះ រួមមាន៖

- គោលដៅយុទ្ធសាស្ត្រទី១៖ កំណត់អាទិភាពនិងពង្រឹងការការពារនិងអភិរក្សធនធានធម្មជាតិ
- គោលដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយចីរភាព
- គោលដៅយុទ្ធសាស្ត្រទី៣៖ ពង្រីកការចូលរួមនិងបង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន
- គោលដៅយុទ្ធសាស្ត្រទី៤៖ ពង្រឹងសមត្ថភាពស្ថាប័ននិងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ

តារាងខាងក្រោម បង្ហាញសេចក្តីសង្ខេបអំពីទំនាក់ទំនងរវាងការគម្រាមកំហែង គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព៖

| ការគម្រាមកំហែងមកលើតំបន់ការពារធម្មជាតិ (កត្តាដោយផ្ទាល់ និងប្រយោល) | គោលដៅយុទ្ធសាស្ត្រ | សកម្មភាពអាទិភាព |
|---|---|---|
| **កត្តាដោយផ្ទាល់** | | |
| ការបាត់បង់ទីជម្រក និងការរេចរិល ធនធាន ដោយសកម្មភាពអភិវឌ្ឍន៍ នៅក្នុងតំបន់ការពារធម្មជាតិ | គយស ១ និង២ | ➢ បញ្ចប់ការបោះព្រំប្រទល់ ចុះបញ្ជិកា កំណត់និងបែងចែកតំបន់គ្រប់គ្រង ដើម្បីកំណត់ឱ្យបានច្បាស់លាស់ តំបន់ស្នូល និងតំបន់អភិរក្សសម្រាប់កិច្ចការពារ<br>➢ បញ្ជាក់ហេតុផលក្នុងការកំណត់ព្រំប្រទល់ ដោយដកចេញ/ស្តារតំបន់រេចរឹលជាអចិន្ត្រៃយ៍ និងបន្ថែមតំបន់អភិរក្សថ្មីៗទៀត (រាប់បញ្ចូលទាំងរបៀងអភិរក្សជីវៈចម្រុះ)<br>➢ ជានាតាមដានត្រួតពិនិត្យ និងពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាព លើសកម្មភាពអភិវឌ្ឍន៍នានា ដូចមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្តនានា<br>➢ ត្រួតពិនិត្យ តាមដាននិងវាយតម្លៃធនធានធម្មជាតិ។ |
| សកម្មភាពល្មើសច្បាប់ក្នុងការការពារធម្មជាតិ ដូចជា៖ កាប់ឈើ បាញ់សត្វ បំពុលសត្វ នេសាទត្រី និងទន្ទ្រានដីធ្វើជាកម្មសិទ្ធិ ។ល។ | គយស ១ ៣ និង៤ | ➢ ផ្តល់វគ្គបណ្តុះបណ្តាលជាបន្ទាន់លើការពង្រឹងការអនុវត្តច្បាប់សម្រាប់ឧទ្យានុរក្ស និងនាយកតំបន់ការពារធម្មជាតិ<br>➢ បណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រងសត្វព្រៃដល់មន្ត្រីជំនាញក្រសួងបរិស្ថាន<br>➢ ពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការតាមដានត្រួតពិនិត្យ រាយការណ៍ និងអភិវឌ្ឍន៍លើជម្រើសមុខរបរចិញ្ចឹមជីវិតរបស់ពួកគាត់<br>➢ បង្កើតប្រព័ន្ធទិន្នន័យប្រមូលផ្តុំមួយដែលនាយកតំបន់ មន្ទីរបរិស្ថាន និងអគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អាចប្រើប្រាស់បានសម្រាប់តាមដានសកម្មភាពនៃការពង្រឹងការអនុវត្តច្បាប់។ |
| **កត្តាដោយប្រយោល** | | |
| ផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ | គយស ១ និង៤ | ➢ យកចិត្តទុកដាក់លើការរៀបចំផែនការគ្រប់គ្រង និងការត្រួតពិនិត្យតំបន់ការពារធម្មជាតិដោយផ្តោតទៅលើការ កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ<br>➢ បញ្ចូលសកម្មភាពបន្សាំ សកម្មភាពកាត់បន្ថយ និងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី ជាគោលដៅសម្រាប់គ្រប់គ្រង តំបន់ការពារ |
| កង្វះខាតលើការកំណត់បែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រង | គយស ១ | ➢ បញ្ចប់ការកំណត់ និងបែកចែកតំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រងសាមញ្ញ (ទិន្នន័យតំបន់ការពារធម្មជាតិ) ដែលសង្ខេបពីគុណតម្លៃនៃការអភិរក្ស និងយុទ្ធសាស្ត្រជាអាទិភាពសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ |

| | | |
|---|---|---|
| ការចូលរួមមានកម្រិតរបស់សហគមន៍ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ | គយស<br>៣ និង៤ | ➢ ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រង<br>➢ បង្កើតជម្រើសលើការចិញ្ចឹមជីវភាពរបស់សហគមន៍មូលដ្ឋាន (រួមមាន ការបង្កើតតំបន់ទេសចរណ៍ធម្មជាតិ)<br>➢ ពង្រឹងការអប់រំ និងការបង្កើនចំណេះដឹង<br>➢ គាំទ្រដល់ការបណ្តុះបណ្តាលសមត្ថភាពដល់អាជ្ញាធរមូលដ្ឋានដែលមានមុខងារកាន់តែសំខាន់ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ |
| ទំនាស់នៃការប្រើប្រាស់ដីដែលកំពុងតែកើតមាន | គយស<br>២ និង៣ | ➢ ធ្វើឱ្យមានសុខដុមកម្មរវាងសកម្មភាពអភិវឌ្ឍន៍ជាមួយនឹងគោលដៅនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ<br>➢ ពង្រឹងឡើងវិញ គណៈកម្មាធិការជាតិដោះស្រាយទំនាស់ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ |
| កង្វះខាតបុគ្គលិកជំនាញ | គយស<br>១ និង៤ | ➢ ពង្រឹងការកសាងសមត្ថភាពជំនាញលើផ្នែកវិទ្យាសាស្ត្រ និងស្រាវជ្រាវសម្រាប់មន្ត្រី អកជ (ជាពិសេសលើផ្នែកគ្រប់គ្រង និងតាមដានសត្វព្រៃ កសាងផែនទីប្រព័ន្ធអេកូឡូស៊ី និងការកំណត់តម្លៃធនធានធម្មជាតិ)<br>➢ ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញបច្ចេកទេស លើមុខជំនាញរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការវិភាគលើចំណុចខ្វះខាត ការគ្រប់គ្រងទិន្នន័យ ការគ្រប់គ្រងគម្រោង និងការសរសេរគម្រោងស្នើសុំ។<br>➢ ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីតំបន់ការពារធម្មជាតិ លើមុខជំនាញ ពង្រឹងការអនុវត្តច្បាប់ ការត្រួតពិនិត្យតាមដានជីវៈចម្រុះ និងវិធានដោយមានការចូលរួមផ្សេងៗទៀតសម្រាប់ការចូលរួមពីអ្នកពាក់ព័ន្ធនៅមូលដ្ឋាន។ |
| ហេដ្ឋារចនាសម្ព័ន្ធ និងធនធានហិរញ្ញវត្ថុមានកំណត់ | គយស<br>៤ | ➢ ស្វែងយល់ជម្រើសផ្សេងៗសម្រាប់បង្កើតចំណូលដោយផ្ទាល់ពីតំបន់ការពារធម្មជាតិ (ឧទា. ចំណូលពីអ្នកមកទស្សនាក្នុងតំបន់អេកូទេសចរណ៍ សេវាកម្មបរិស្ថាន កម្មវិធីរេដបូក)<br>➢ ស្វែងរកថវិកាប្រតិបត្តិការសម្រាប់តំបន់ការពារធម្មជាតិ<br>➢ បង្ហាញពីគុណតម្លៃសេដ្ឋកិច្ចនៃតំបន់ការពារធម្មជាតិ ក្នុងការគាំទ្រដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង។ |
| កង្វះខាតទិន្នន័យគោល និងវិធានសម្រាប់ប្រមូល រក្សាទុក និងចែករំលែកព័ត៌មាននៃតំបន់ការពារធម្មជាតិ | គយស<br>៤ | ➢ បង្កើនកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងអង្គការអភិរក្សនានា<br>➢ រួមបញ្ចូលគ្នានូវទិន្នន័យព័ត៌មានដែលមានស្រាប់ ស្តីពីជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី<br>➢ អនុម័តប្រព័ន្ធស្តង់ដាតាមដានត្រួតពិនិត្យជីវៈចម្រុះសម្រាប់ធ្វើការតាមដានត្រួតពិនិត្យនៅទីវាលជាក់ស្តែង<br>➢ វិនិយោគប្រព័ន្ធទិន្នន័យប្រមូលផ្តុំ ដែលអាចគ្រប់គ្រង និងចែករំលែកទិន្នន័យព័ត៌មានភូមិសាស្ត្រ (GIS) ពីប្រភេទសត្វ-រុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ |

ខាងក្រោមនេះផ្តល់នូវទិដ្ឋភាពសង្ខេប និងផែនការសកម្មភាពសម្រាប់គោលដៅយុទ្ធសាស្ត្រនីមួយៗ។ សូចនាករ រយៈពេលខ្លី (៥ឆ្នាំ) មធ្យម (១០ឆ្នាំ) និងរយៈពេលវែង (១៥ឆ្នាំ) និងតម្រូវការថវិកាសម្រាប់រយៈពេល៥ឆ្នាំដំបូង (២០១៧-២០២១) ដូចមានចែងក្នុងឧបសម្ព័ន្ធ៣ខាងក្រោម។

## ៥.១ គោលដៅយុទ្ធសាស្ត្រ១៖ កំណត់អាទិភាពនិងពង្រឹងការការពារនិងអភិរក្សធនធានធម្មជាតិ

### ៥.១.១ ធានាការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ បែងចែកតំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រង

កម្មវិធីនៃសកម្មភាពទាំងនេះនឹងត្រូវបានអនុវត្ត ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ទៅតាមលំដាប់នៃជំហានប្រទាក់ក្រឡាគ្នា ដូចខាងក្រោម៖

១. **ការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ៖** ផ្តល់អាទិភាពលើការកំណត់ព្រំប្រទល់ផ្នែកខាងក្រៅ (ព្រំប្រទល់ព័ទ្ធជុំវិញ)នៃតំបន់ការពារធម្មជាតិ និងតំបន់របៀងអភិរក្សជីវៈចម្រុះ ដែលមានចុះបញ្ជិកាទិន្នន័យវាស់វែងក្នុងផែនទីមូលដ្ឋានទិន្នន័យនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងធ្វើការបោះបង្គោលព្រំ ដោយយកចិត្តទុកដាក់តាមចំណុចមានមនុស្សចេញចូល-ឆ្លងកាត់(ឧទា. តាមផ្លូវ និងផ្លូវលំក្នុងព្រៃ ។ល។) និងដាក់ផ្ទាំងប៉ាណូនៅតាមដងផ្លូវ។

២. **ផែនការគ្រប់គ្រង៖** ក្នុងរយៈពេលប្រាំឆ្នាំដំបូង ត្រូវបង្កើតឡើងនូវឯកសារទិន្នន័យព័ត៌មានតំបន់ការពារធម្មជាតិដែលខ្លីតែជាក់លាក់ និងសង្ខេបអំពីតម្លៃនៃការអភិរក្ស និងយុទ្ធសាស្ត្រអាទិភាពសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ ហើយឯកសារនេះក៏អាចជាត្រីវិស័យសម្រាប់កំណត់ និងបែងចែកតំបន់គ្រប់គ្រង និងផ្តួចផ្តើមរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។ ក្នុងរយៈពេលវែងនឹងត្រូវបង្កើតឡើងនូវផែនការគ្រប់គ្រងលម្អិតដែលជា «**ផែនការធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**» រួមមានយុទ្ធសាស្ត្រសម្រាប់និរន្តរភាពនៃជីវភាពរស់នៅ និងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី។

៣. **ការកំណត់និងបែងចែកតំបន់គ្រប់គ្រង៖** បង្កើតឡើងនូវគោលការណ៍ណែនាំ ក្នុងការកំណត់ និងបែងចែកតំបន់គ្រប់គ្រង និងធ្វើអត្តសញ្ញាណលើទិន្នន័យព័ត៌មានដែលមានស្រាប់។ ជាអាទិភាពគឺការកំណត់តំបន់ស្នូល និងតំបន់អភិរក្សក្នុងតំបន់ការពារធម្មជាតិ (ឧទា. ដោយផ្អែកលើតំបន់ដែលសំបូរជីវៈចម្រុះ និងតម្លៃអេកូឡូស៊ីខ្ពស់) និងពុំអនុញ្ញាតសកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មកើតមានឡើងក្នុងតំបន់ទាំងនោះឡើយ។

យោងច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានចែងថា៖ *«ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង ការកែប្រែព្រំប្រទល់តំបន់ការពារធម្មជាតិ និងការបង្កើតតំបន់ការពារធម្មជាតិថ្មី ត្រូវកំណត់ដោយអនុក្រឹត្យ ហើយការរៀបចំគោលការណ៍ណែនាំ នៃការកសាងផែនការសកម្មភាពសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗត្រូវសម្រេចដោយប្រកាសរបស់ក្រសួងបរិស្ថាន»*។

៤. **ត្រួតពិនិត្យ តាមដាននិងវាយតម្លៃធនធានធម្មជាតិ៖** បង្កើតប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃធនធានព្រៃឈើនៅតំបន់ការពារធម្មជាតិ និងតំបន់របៀងអភិរក្សជីវៈចម្រុះ។ បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានធម្មជាតិ ដូចជាទិន្នន័យសារពើភ័ណ្ឌព្រៃឈើ ធនធានគម្របព្រៃឈើ ល្បាត បទល្មើសព្រៃឈើ ការកាប់រានដីព្រៃ។

### ៥.១.២ ពង្រឹងការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង

ពង្រឹងការអនុវត្តច្បាប់រួមមានកម្មវិធីចំនួនពីរ ដែលត្រូវប្រើក្នុងរយៈពេលវែងគឺ ការលើកកម្ពស់ការយល់ដឹងដល់សហគមន៍មូលដ្ឋាន និងពង្រឹងសមត្ថភាពក្នុងការអនុវត្តច្បាប់។ គោលបំណងជាបឋមគឺការកាត់បន្ថយបណ្តាបទល្មើសនានា ដែលកំពុងកើតមានឡើងក្នុងតំបន់ការពារធម្មជាតិ។ ការធ្វើឱ្យកាន់តែប្រសើរក្នុងការអនុវត្តច្បាប់ និងកិច្ចសហការជាមួយសហគមន៍មូលដ្ឋាន គឺជាដំណោះស្រាយមួយ ដែលបច្ចុប្បន្នការគំរាមកំហែងកំពុងប្រឈមក្នុងតំបន់ការពារធម្មជាតិ។ បណ្តាសកម្មភាពអាទិភាព រួមមាន៖

១. ***លើកកម្ពស់ការយល់ដឹង៖*** ផ្តល់ការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋាន (រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ និងក្រុមប្រឹក្សាអភិវឌ្ឍន៍ឃុំ/សង្កាត់) អំពីច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលទាក់ទងទៅនឹងសិទ្ធប្រើប្រាស់ធនធាន និងការទទួលខុសត្រូវរបស់សហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងឱកាសបង្កើនកម្រិតជីវភាពរស់នៅរបស់ពួកគាត់ ជាមួយនឹងការរួមចំណែកការពារនិងអភិរក្សតំបន់ការពារធម្មជាតិ។

២. ***ពង្រឹងសមត្ថភាពអនុវត្តច្បាប់៖*** តម្រូវឱ្យមានការវិនិយោគទាំងលើផ្នែក សម្ភារៈ និងការបណ្តុះបណ្តាល រួមមាន៖

ក. ទិញបន្ថែមនូវ រថយន្ត និងម៉ូតូ ព្រមទាំងកាណូត (សម្រាប់ប្រើនៅតំបន់ដីសើម និងឆ្នេរសមុទ្រ) ឧបករណ៍ GPS ម៉ាស៊ីនថតរូប និងសម្ភារៈបច្ចេកទេសទំនើបៗមួយចំនួនទៀត ដែលអាចបម្រើដល់ការងារនៅទីវាល

ខ. ផ្តល់វគ្គបណ្តុះបណ្តាលជំនាញ ផ្នែកអនុវត្តន៍ច្បាប់ ដល់ឧទ្យានុរក្ស ដោយសហការជាមួយនឹងកងកំលាំងប្រដាប់អាវុធ

គ. ផ្តល់វគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋានដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនការចូលរួមសកម្មភាពល្បាត ពិសេសសកម្មភាពសហគមន៍តំបន់ការពារធម្មជាតិ និងរៀបចំជាបណ្តាញផ្តល់ព័ត៌មាននៅមូលដ្ឋានរបស់ពួកគាត់

ឃ. បង្កើតក្រុមចល័ត-ប្រតិកម្មរហ័ស ពង្រឹងការអនុវត្តច្បាប់ ដែលរួមមានតំណាងពីរដ្ឋបាលផ្សេងៗទៀត ក៏ដូចជាកងរាជអាវុធហត្ថ ដើម្បីគាំទ្រសកម្មភាពអន្តរាគមន៍ ក្នុងករណីតម្រូវការបង្ក្រាបជាទ្រង់ទ្រាយធំ

ង. លើកទឹកចិត្តដល់ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យល្បាតសាមញ្ញ ដូចជាស្មាត (Spatial Monitoring and Reporting Tool) និងមីស្ស (Management Information System)នៅទូទាំងតំបន់ការពារធម្មជាតិ

ច. រឹតបណ្តឹងការដាក់ទោសទណ្ឌ និងការឃាត់ខ្លួនជនល្មើស

ឆ. ស្វែងរកឱកាសផ្តល់ការលើកទឹកចិត្ត និងផលប្រយោជន៍ផ្សេងៗ សម្រាប់ឧទ្យានុរក្ស ក្នុងការទប់ស្កាត់សកម្មភាពល្មើសច្បាប់នៅតាមតំបន់ការពារធម្មជាតិ

ជ. បង្កើតប្រព័ន្ធទិន្នន័យប្រមូលផ្តុំមួយ ដែលនាយកតំបន់ មន្ទីរបរិស្ថាន និង អ.ក.ធ អាចប្រើប្រាស់សម្រាប់តាមដានសកម្មភាពនៃការពង្រឹងការអនុវត្តច្បាប់

សកម្មភាពកាត់បន្ថយការគំរាមកំហែង នឹងត្រូវបានដោះស្រាយបន្ថែមទៀត តាមរយៈការបង្កើតជម្រើសមុខរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់សហគមន៍មូលដ្ឋាន ដែលអាចជំនួសឱ្យការប្រើប្រាស់ធនធានធម្មជាតិដោយមិនមាននិរន្តរភាព(សូមមើលគយស ៣.៣)។

### ៥.១.៣ ជំរុញការការពារ ការអភិរក្ស និងការស្តារឡើងវិញនៃជីវៈចម្រុះ

សារៈសំខាន់នៃតំបន់ការពារធម្មជាតិគឺការផ្តល់ដែនជម្រកធម្មជាតិ សម្រាប់សត្វព្រៃ (រួមទាំងប្រភេទរុក្ខជាតិ និងមច្ឆជាតិ) ដែលបច្ចុប្បន្នកំពុងទទួលរងនូវហានិភ័យ។ ក្រសួងបរិស្ថាននឹងរួមសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការអភិរក្ស និងសាកលវិទ្យាល័យនានា ដើម្បីពង្រឹងមូលដ្ឋានចំណេះដឹង គាំទ្រការងារអភិរក្ស រៀបចំផែនការសកម្មភាពអភិរក្ស ព្រមទាំងរួមគ្នាដោះស្រាយនូវការគំរាមកំហែងមកលើបណ្តាប្រភេទជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។ បណ្តាយុទ្ធសាស្រ្តជាក់លាក់ រួមមាន៖

១. បញ្ចប់ការរៀបចំផែនទីប្រព័ន្ធអេកូឡូស៊ី ដើម្បីកំណត់ចំណុចពិសេសដែលមានជីវៈចម្រុះសំខាន់ៗ និងបង្កើនឱកាសក្នុងការផ្សារភ្ជាប់តំបន់ការពារធម្មជាតិមួយទៅតំបន់ការពារធម្មជាតិមួយទៀតតាមរយៈរបៀងអភិរក្សជីវៈចម្រុះ (សូមមើលគយស ២.២)
២. បង្កើតប្រព័ន្ធស្តង់ដារក្នុងការវាយតម្លៃជីវៈចម្រុះ ដែលអាចចែករំលែក និងប្រើប្រាស់សម្រាប់ការត្រួតពិនិត្យជាប្រចាំ អំពីស្ថានភាព និងនិន្នាការ នៃប្រភេទសត្វនិងរុក្ខជាតិដែលរងហានិភ័យ នៅក្នុងតំបន់ការពារធម្មជាតិ(សូមមើលគយស ៤.២)
៣. គាំទ្រការសិក្សាស្រាវជ្រាវ និងចំណេះដឹងមូលដ្ឋាន (លក្ខណៈប្រពៃណី) ដើម្បីបង្កើតផែនការសកម្មភាពអភិរក្សប្រភេទសត្វ និងរុក្ខជាតិជាក់លាក់មួយ ពិសេសប្រភេទសត្វកំពុងរងការគម្រាមកំហែងឬតំបន់រេចរឹល។ ទាំងនេះរួមទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនគម្របព្រៃឈើ តាមរយៈការស្តារព្រៃឈើនៅតាមតំបន់រេចរឹល
៤. ទប់ស្កាត់ការនាំចូលប្រភេទសត្វនិងរុក្ខជាតិចម្លង រាតត្បាត និងដុះរាលដាលនានា ដែលនឹងគម្រាមកំហែងដល់ប្រភេទរុក្ខជាតិ និងសត្វ ដែលជាប្រភេទដើមនៅតាមតំបន់ការពារធម្មជាតិ
៥. ពង្រីកការអភិរក្សក្រៅតំបន់ ដោយការស្តារឡើងវិញ និងបង្កើនសក្តានុពលតំបន់អភិរក្ស ដើម្បីសម្រួលដល់ប្រភេទដែលរងហានិភ័យវិលទៅកាន់ជម្រកធម្មជាតិដើមរបស់វាវិញ
៦. ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ដោះស្រាយការគំរាមកំហែងប្រភេទនានា និងប្រព័ន្ធអេកូឡូស៊ី ដែលរួមមាន៖
   ក. ប្រសិទ្ធភាពនៃផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ(សូមមើលគយស ១.១)
   ខ. សកម្មក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ(សូមមើលគយស ១.២)
   គ. ប្រសិទ្ធភាពពង្រឹងការអនុវត្តច្បាប់(សូមមើលគយស ១.២)
   ឃ. ធ្វើឱ្យប្រសើរឡើងសមត្ថភាពវិទ្យាសាស្រ្តក្នុងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (សូមមើលគយស ៤.១)
   ង. កិច្ចសហប្រតិបត្តិការក្នុងការផ្ទេរបច្ចេកវិទ្យា (សូមមើលគយស ៤.២)

### ៥.១.៤ ពង្រីកកិច្ចសហការប្រតិបត្តិការអន្តរជាតិ

កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ពង្រឹងការគ្រប់គ្រង និងការអភិរក្សតំបន់ការពារធម្មជាតិក៏នឹងត្រូវបានពង្រឹងពង្រីក ជាពិសេសក្នុងបរិបទថ្នាក់តំបន់ដើម្បីចែករំលែកនូវមេរៀនពិសោធន៍ល្អៗ គំនិតច្នៃប្រឌិត និងបច្ចេកវិទ្យាថ្មី។ ចំណុចជាក់លាក់ដែលត្រូវដាក់បញ្ចូល រួមមាន៖

១. គាំទ្របណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន ដើម្បីប្រយុទ្ធប្រឆាំងនឹងអាជីវកម្មសត្វព្រៃខុសច្បាប់ និងការប្តេជ្ញាអនុវត្តន៍អនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើរុក្ខជាតិ និងសត្វព្រៃដែលជិតផុតពូជ (CITES)

២. មហាអនុតំបន់មេគង្គ - ពង្រីកច្រករបៀងសម្រាប់ការអភិរក្សជីវៈចម្រុះឆ្លងដែន

៣. គណៈកម្មការពិភពលោកនៃតំបន់ការពារធម្មជាតិប្រចាំតំបន់អាស៊ីអាគ្នេយ៍ (WCPA) - ចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងចែករំលែកព័ត៌មាន ទាក់ទងនឹងតំបន់ការពារធម្មជាតិ

៤. ដៃគូសកម្មភាពប្រភេទសត្វ-រុក្ខជាតិអាស៊ាន IUCN (ASAP) សម្ព័ន្ធអន្តរភ្នាក់ងារដើម្បីដោះស្រាយ ប្រភេទរងហានិភ័យខ្ពស់នៃប្រភេទសត្វឆ្អឹងកងមិនមែនជាសត្វសមុទ្រក្នុងតំបន់អាស៊ី-អាគ្នេយ៍

៥. សម្ព័ន្ធឧទ្យានុរក្សអន្តរជាតិ( និងសម្ព័ន្ធឧទ្យានុរក្សអាស៊ី ) - ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំឧទ្យានុរក្សតំបន់ ការពារធម្មជាតិ ដើម្បីចែករំលែកបទពិសោធន៍ និងបច្ចេកវិទ្យាថ្មីៗ

៦. កិច្ចព្រមព្រៀងបរិស្ថានពហុភាគី ( ឧទា.CBD, UNFCCC, CITES, Ramsar Convention ) - ចូលរួម កិច្ចប្រជុំថ្នាក់តំបន់ និងសន្និសិទនៃបណ្តាភាគី និង

៧. កិច្ចព្រមព្រៀងទ្វេភាគី - អនុវត្តន៍យុទ្ធសាស្ត្រទទួលផលប្រយោជន៍ទាំងសងខាង( ឧទា. អនុស្សារណៈ យោគយល់ជាមួយប្រទេសចិន និងអាហ្វ្រិកខាងត្បូងស្តីពីបញ្ហាអាទិភាពបរិស្ថាន )។

## ៥.២ គោលដៅយុទ្ធសាស្ត្រ២៖ បង្កើនការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយចីរភាព

### ៥.២.១ ធ្វើសុខដុមកម្មនៃសកម្មភាពអភិវឌ្ឍន៍ជាមួយនឹងគោលបំណងគ្រប់គ្រងតំបន់ការពារធម្មជាតិ

ការផ្ទេរដីសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់គ្រងនាពេលថ្មីៗនេះ ជាការចាំបាច់គឺត្រូវមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងទាំងពីរ (MoE and MAFF) ដើម្បីធានាថា ដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ក្នុងពេលបច្ចុប្បន្នបានរួមចំណែក ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន ទន្ទឹមនឹងការរួមគ្នាកាត់បន្ថយការគម្រាមកំហែង ដែលអាចជះឥទ្ធិពលដល់តំបន់ការពារធម្មជាតិ ពិសេសទីតាំងដីសម្បទានសេដ្ឋកិច្ចទាំងនោះ។ កម្មវិធីនេះ នឹងបំពេញបន្ថែមជាមួយសកម្មភាពដែលស្ថិតនៅក្នុងគយស១.១ (ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង) ដើម្បីកំណត់ឱ្យបានច្បាស់ពីតំបន់ស្នូល តំបន់អភិរក្ស នៃតំបន់ការពារធម្មជាតិនីមួយៗ ដោយផ្អែកលើ ទិន្នន័យព័ត៌មានវិទ្យាសាស្ត្រ និងចំណេះដឹងមូលដ្ឋាន។ សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ តាមនិយម ន័យគឺជាផ្នែកមួយក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារធម្មជាតិ។ ហេតុនេះ បណ្តាសកម្មភាព ដែលត្រូវធ្វើសហការជាមួយ MAFF-FA មានដូចខាងក្រោម៖

១. ត្រួតពិនិត្យតាមដានសកម្មភាពនៅតំបន់អភិវឌ្ឍន៍ដោយចីរភាព ដើម្បីធានាថា សកម្មភាពទាំងនោះ បានអនុវត្តស្របតាមគោលការណ៍ច្បាប់ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

២. គាំទ្រដល់ម្ចាស់សម្បទានដីសេដ្ឋកិច្ច ក្នុងការផ្តល់ឱកាសការងារ និងបណ្តុះបណ្តាលដល់សហគមន៍ មូលដ្ឋាន និងបង្កើនការចូលរួមពីម្ចាស់សម្បទានដីសេដ្ឋកិច្ចក្នុងសកម្មភាពស្តារព្រៃឈើ និងប្រព័ន្ធ អេកូឡូស៊ី

៣. ជ្រើសរើសក្រុមហ៊ុន (ក្រុមហ៊ុនគំរូឈានមុខ) ដែលគាំទ្រដល់គោលគំនិតគ្រប់គ្រងតំបន់ការពារ ធម្មជាតិប្រកបដោយចីរភាព ហើយមានឥទ្ធិពលដល់បណ្តាសម្បទានដីសេដ្ឋកិច្ចផ្សេងទៀត ដើម្បី ធ្វើឱ្យកាន់តែប្រសើរឡើងនៃការទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ( ឧទា. វារីអគ្គិសនី រ៉ែ និងផ្លូវថ្នល់ ) ដែលបានស្នើឡើងឬ បានផ្តួចផ្តើមអនុវត្តន៍នៅក្នុងតំបន់ការពារធម្មជាតិ ក៏នឹងត្រូវតម្រូវឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងតាមប្រការដែលមានចែងក្នុងក្រមធនធានធម្មជាតិ និងបរិស្ថានថ្មី។ ដើម្បីដោះស្រាយទំនាស់

ក្នុងការប្រើប្រាស់ដីធ្លី ដែលស្ថិតនៅក្នុង ឬជាប់នឹងតំបន់ការពារធម្មជាតិ ដំណើរការយន្តការគណៈកម្មាធិការជាតិដោះស្រាយទំនាស់លើការគ្រប់គ្រងតំបន់ការពារធម្មជាតិគឺជាការចាំបាច់។

### ៥.២.២ ការផ្សារភ្ជាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ

ការពង្រីកវិសាលភាពនៃតំបន់ការពារធម្មជាតិដែលស្ថិតក្នុងដែនយុត្តាធិការក្រសួងបរិស្ថាន ធ្វើឱ្យប្រទេសកម្ពុជាមានដែនទេសភាពតំបន់ការពារធម្មជាតិគ្របដណ្តប់នៅភាគខាងកើតទន្លេមេគង្គ ភាគខាងជើង និងភាគខាងត្បូង បឹងទន្លេសាប ដែលលាតសន្ធឹងធំ និងបន្តបន្ទាប់គ្នា(ឧបសម្ព័ន្ធ ២)។ ការបង្កើតរបៀងអភិរក្សជីវៈចម្រុះ គឺជាឱកាសសម្រាប់ពិនិត្យពិច័យលើការផ្សាភ្ជាប់រវាងតំបន់ដែនទេសភាពទាំងនេះ ដើម្បីធានាភាពងាយស្រួលក្នុងការបន្លះទីនៃប្រភេទសត្វធំៗ និងប្រភេទសត្វបន្លះទីតាមរដូវកាល ពីតំបន់ការពារធម្មជាតិនីមួយៗ តាមរយៈបណ្តារបៀងអភិរក្សជីវៈចម្រុះទាំងនោះ។

ដើម្បីធានាថាតំបន់ការពារធម្មជាតិពិតជាស្ថិតនៅ «**ទីតាំងត្រឹមត្រូវ**» (ឧទា. ការជ្រើសរើសផ្អែកលើមូលដ្ឋានទិន្នន័យវិទ្យាសាស្ត្រ) ការប្រើព័ត៌មានទីតាំងប្រព័ន្ធ GIS និងមូលដ្ឋានផែនទីប្រព័ន្ធអេកូឡូស៊ីចម្រុះ ផ្អែកលើទិន្នន័យល្អបំផុតដែលមានស្រាប់នឹងកំណត់ក្នុងការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងនេះ និងបំពេញបានភាពខ្វះចន្លោះ ដើម្បីបង្កើតឱ្យបានប្រព័ន្ធអេកូឡូស៊ីមួយពេញលេញ។ ព័ត៌មានទីតាំងនឹងត្រូវ៖

១. ការប្រើប្រាស់ផែនទីប្រព័ន្ធអេកូឡូស៊ី ឆ្លុះបញ្ចាំងភាពត្រួតស៊ីគ្នារវាងតំបន់ដែលមានតម្លៃជីវៈចម្រុះខ្ពស់ ជាមួយតំបន់ការពារធម្មជាតិដែលមានស្រាប់ ហើយកំណត់ភាពខ្វះចន្លោះនៃការគ្របដណ្តប់តំបន់ទាំងនេះ
២. ពិនិត្យមើលការប្រើប្រាស់ដីបច្ចុប្បន្នក្នុងបណ្តាតំបន់ដែលស្ថិតនៅជាប់នឹងតំបន់ការពារធម្មជាតិ ដើម្បីកំណត់ជម្រើសក្នុងការពង្រីកព្រំប្រទល់ ឬបង្កើតរបៀងអភិរក្សតភ្ជាប់តំបន់ការពារធម្មជាតិទាំងនោះ ក្នុងគោលដៅកាត់បន្ថយទីជម្រកដែលដាច់ជាផ្នែកៗ និងរក្សាប្រព័ន្ធអេកូឡូស៊ី
៣. ជាជំនួយក្នុងការកំណត់ថា តើការប្រែប្រួលព្រំប្រទល់តំបន់ការពារធម្មជាតិទាំងនោះអាចនឹងបង្កើនកម្រិតប្រព័ន្ធអេកូឡូស៊ី ប្រភេទជីវៈចម្រុះសំខាន់ៗ ឬការប្រើប្រាស់តាមបែបប្រពៃណីដែរឬទេ និង
៤. ពិចារណាលើស្ថានភាព ឬព្រំប្រទល់បច្ចុប្បន្ននៃតំបន់ការពារធម្មជាតិមួយចំនួន ដែលប្រព័ន្ធអេកូឡូស៊ីនៅទីនោះមានវិបត្តិធ្ងន់ធ្ងរ បណ្តាលមកពីការបាត់បង់ទីជម្រក ឬការអភិវឌ្ឍហួសប្រមាណ ដែលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ (ឧទា. តំបន់ដែនជម្រកសត្វព្រៃស្នួល និងនាមដូនសំ)។

ការកំណត់ និងការបង្កើតតំបន់ការពារធម្មជាតិសមុទ្រ/តំបន់ឆ្នេរ និងតំបន់ដីសើម ក៏ជាចំណុចអាទិភាពមួយដែរ ដើម្បីធានាថាតំបន់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ប្រភេទផ្សេងៗទៀត ត្រូវបានរួមបញ្ចូលយ៉ាងគ្រប់គ្រាន់ទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិថ្នាក់ជាតិ។

## ៥.៣ គោលដៅយុទ្ធសាស្ត្រ៣៖ ពង្រីកការចូលរួមនិងបង្កើនផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន

គោលបំណងយុទ្ធសាស្ត្រ៣នេះនឹងត្រូវបានដឹកនាំអនុវត្តន៍ដោយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន។

### ៥.៣.១ បង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងដំណើរការរៀបចំផែនការគ្រប់គ្រង

តាមប្រកាសលេខ ៣៥ របស់ក្រសួងបរិស្ថាន អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននឹងទទួលខុសត្រូវក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាពលើការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិដល់មន្ត្រីរដ្ឋបាលឃុំ/សង្កាត់ រួមទាំងសហគមន៍តំបន់ការពារដែលមានស្រាប់។ ដើម្បីបង្កើតកិច្ចសន្ទនាក្នុងន័យស្ថាបនាជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច មន្ត្រីនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (ក៏ដូចជាមន្ត្រី GDANCP) ចាំបាច់ត្រូវទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រនៃការចូលរួម និងយេនឌ័រ ដើម្បីជួយជំរុញអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានចូលរួម។ វគ្គបណ្តុះបណ្តាលនេះ (បណ្តុះបណ្តាលគ្រូបង្គោល) អាចត្រូវបានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិ ដែលមានបទពិសោធន៍ខ្ពស់ក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍។

ការអប់រំផ្សព្វផ្សាយ និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អាចនឹងត្រូវបានបន្តអនុវត្តក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ដោយផ្តោតជាសំខាន់លើ៖

១. ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសម្រាប់យុទ្ធនាការក្នុងការលើកកម្ពស់ការយល់ដឹង (ដោយភាសាសាមញ្ញ និងគោរពសិទ្ធយេនឌ័រ) បង្ហាញពីសារៈសំខាន់នៃជីវៈចម្រុះ និងការអភិរក្សធនធានធម្មជាតិ ដែលជាមធ្យោបាយផ្សារភ្ជាប់ជីវភាពចិញ្ចឹមជីវិតជាមួយនិងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព
២. ពង្រីកការយល់ដឹងអំពីច្បាប់និងបទបញ្ញត្តិទាក់ទងនឹងសិទ្ធ និងតួនាទីនៃការប្រើប្រាស់ធនធានជាលក្ខណៈប្រពៃណីនៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ
៣. បញ្ជ្រាបគោលការណ៍អភិរក្ស ការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងសមធម៌យេនឌ័រទៅក្នុងកម្មវិធីសិក្សាតាមសាលារៀននៅមូលដ្ឋាន។

ផលប្រយោជន៍នៃការបង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងដំណើររៀបចំការផែនការគ្រប់គ្រងមាន ដូចជា៖

- ប្រមូលចំណេះដឹងមូលដ្ឋាន និងជាលក្ខណៈប្រពៃណីរបស់សហគមន៍ ដើម្បីពង្រឹងផែនការគ្រប់គ្រង និងការកំណត់និងការបែងចែកតំបន់គ្រប់គ្រង(សូមមើលគយស ១.១)ក៏ដូចជាការចូលរួមចំណែកក្នុងដំណើរការវាយតម្លៃជីវៈចម្រុះ(សូមមើលគយស ១.៣ និង ៤.២)
- បង្កើតនូវបណ្តាញជនបង្គោលមូលដ្ឋានសំខាន់ៗ ដែលអាចជួយឧទ្យានុរក្សក្នុងការពង្រឹងការអនុវត្តច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ(សូមមើលគយស ១.២)
- លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃតុល្យភាពរវាងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានជាមួយនឹងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ(គយស ៣.៣)។

*** គួរកត់សម្គាល់ថាការចូលរួមរបស់សហគមន៍មូលដ្ឋាន គឺចាំបាច់ត្រូវមានការលើកទឹកចិត្ត ដោយហេតុថាពួកគាត់មានការរវល់មមាញឹកក្នុងសកម្មភាពរកចំណូលដើម្បីជីវភាពប្រចាំថ្ងៃរបស់ពួកគាត់។

### ៥.៣.២ គាំទ្រយន្តការសហការក្នុងការគ្រប់គ្រង

«**សហប្រតិបត្តិការក្នុងការគ្រប់គ្រង**» គឺជាយន្តការគ្រប់គ្រងតំបន់ការពារធម្មជាតិមួយដែលថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃៗទៀត ត្រូវចេះសម្របសម្រួលចែករំលែកតួនាទី និងការទទួលខុសត្រូវ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុង

ការធ្វើវិសហមជ្ឈការតាមរយៈ គ.ជ.អ.ប ក្រសួងបរិស្ថានបានធ្វើប្រតិភូកម្មរួចជាស្រេចនូវមុខងារមួយចំនួន ទាក់ទងនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ជូនដល់អាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រកិច្ចសហការគ្រប់គ្រង។ ទាំងនេះរួមមានការធ្វើប្រតិភូកម្មតួនាទីពាក់ព័ន្ធនឹងការងារសហគមន៍ដល់រដ្ឋបាលឃុំ/សង្កាត់ និងការទទួលខុសត្រូវក្នុងការលើកកម្ពស់ការយល់ដឹង ការអភិវឌ្ឍជីវភាពនៅមូលដ្ឋាន និងការពង្រឹងអនុវត្តច្បាប់ ដល់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ។

យន្តការសហការមួយទៀតគឺការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ដែលផ្តល់ជាមធ្យោបាយសំខាន់ៗ សម្រាប់ធានាដល់ខ្សែក្រវាត់បៃតង កាត់បន្ថយការទន្ទ្រានដីខុសច្បាប់ និងសម្របសម្រួលជាមួយប្រជាជននៅថ្នាក់មូលដ្ឋាន ក្នុងការចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិ។ បន្តលើកទឹកចិត្តគាំទ្រដល់សហគមន៍តំបន់ការពារធម្មជាតិ ដែលមានស្រាប់ដោយបញ្ជ្រាបផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិទៅក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់ ដែលជាមធ្យោបាយក្នុងការគាំទ្រគោលនយោបាយសម្រាប់ពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋាន ក្នុងដំណើរការផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ លើសពីនេះ សហគមន៍តំបន់ការពារធម្មជាតិ ឬបណ្តាយន្តការសហការគ្រប់គ្រងផ្សេងៗទៀត ក៏ត្រូវមានការរៀបចំ និងឧបត្ថម្ភគាំទ្រផងដែរ។

ការលើកទឹកចិត្តក្នុងទម្រង់ជាថវិកា ឧបករណ៍/សម្ភារៈ ឥស្សរិយយស ឬប័ណ្ណសរសើរ ត្រូវបានយកចិត្តទុកដាក់ពិចារណាសម្រាប់សហគមន៍តំបន់ការពារធម្មជាតិ ដែលទទួលបានជោគជ័យខ្ពស់ក្នុងការចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានដោយនិរន្តរភាពក្នុងសហគមន៍របស់ខ្លួន។

### ៥.៣.៣ ពង្រីកឱកាសនៃការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន

ការផ្តល់ឱកាសចូលរួមដោយផ្ទាល់និងពេញលេញដល់សហគមន៍មូលដ្ឋានទាំងបុរស និងស្ត្រីក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ការពារធម្មជាតិ នឹងកាត់បន្ថយនូវសំពាធនៃការប្រើប្រាស់ធនធានធម្មជាតិ និងផ្តល់នូវការបង្កើនជម្រើសសម្រាប់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានផងដែរ។ តាមរយៈការបង្កើនជម្រើសនានា ដែលអាចជំនួសឱ្យការប្រើប្រាស់ធនធានធម្មជាតិមិនមាននិរន្តរភាព សហគមន៍មូលដ្ឋានអាចមានទឹកចិត្តក្នុងការបំពេញតួនាទី លើការត្រួតពិនិត្យតាមដាន និងជួយធានាសុវត្ថិភាពធនធានក្នុងតំបន់ការពារធម្មជាតិ។ បណ្តាសកម្មភាពទាំងនោះរួមមាន៖

១. ការបង្កើនជម្រើសការងារដល់សហគមន៍ ដោយផ្សារភ្ជាប់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងសកម្មភាពវិនិយោគឯកជនផ្សេងទៀតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ (សូមមើលគយស ២.១)
២. គាំទ្រផ្នែកបច្ចេកវិទ្យា ក្នុងការបង្កើនទិន្នផលកសិកម្ម ដែលធ្វើការដាំដុះដោយសហគមន៍មូលដ្ឋាន (ដោយសហការជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
៣. ជំរុញបង្កើតអាជីវកម្មខ្នាតតូច និងគំនិតផ្តួចផ្តើម ដើម្បីទទួលបានហិរញ្ញប្បទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់ការកែច្នៃអនុផលព្រៃឈើ និងស្វែងរកទីផ្សារសម្រាប់ផល-អនុផលព្រៃឈើ ផលិតផលសិប្បកម្ម និងឱសថបុរាណ និង
៤. លើកទឹកចិត្តកិច្ចខិតខំប្រឹងប្រែងសហការក្នុងការត្រួតពិនិត្យតាមដានសកម្មភាពខុសច្បាប់ នៅក្នុងតំបន់ការពារធម្មជាតិ និងជំរុញការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងកម្មវិធីស្តារព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីឡើងវិញ។

ឱកាសពង្រីកវិស័យអេកូទេសចរណ៍គឺជាមធ្យោបាយមួយ ក្នុងការគាំទ្រទាំងការងារអភិរក្ស និងការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងតំបន់ការពារធម្មជាតិ ដែលក្នុងនោះសហគមន៍ជាអ្នកផ្តល់កន្លែងស្នាក់នៅ និងសេវាកម្មសម្រាប់ភ្ញៀវទេសចរ។ មេរៀនពិសោធន៍ល្អៗពីតំបន់អេកូទេសចរនានាដែលកំពុងមានសកម្មភាព (ឧទា. ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ» ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព តំបន់ស្នូលដីសើមព្រែកទាល់ និងដែនជម្រកសត្វព្រៃពាមក្រសោប) អាចជាគំរូសម្រាប់ការបង្កើតយុទ្ធសាស្ត្រជាក់លាក់នៃអេកូទេសចរណ៍នៅក្នុងតំបន់ការពារធម្មជាតិផ្សេងទៀត ដោយៈ

១. កំណត់សក្តានុពលតំបន់អេកូទេសចរណ៍ដែលមានស្រាប់ និងតំបន់ដែលនឹងបង្កើតថ្មី ដោយផ្តោតលើតំបន់ទេសភាពធម្មជាតិ ក៏ដូចជាតំបន់វប្បធម៌ និងបេតិកភណ្ឌធម្មជាតិ
២. ពិចារណាទៅលើបណ្តាតំបន់ ដែលមានគុណភាពគ្រប់គ្រាន់ ក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាក្នុងចំនួនមួយគ្រប់គ្រាន់ ដែលអាចធានានិរន្តរភាពហិរញ្ញវត្ថុ ដែលរួមវិភាគទានដល់សហគមន៍មូលដ្ឋានក្នុងការចាត់ចែងសម្រាប់សេវាកម្មទេសចរណ៍ឱ្យបានល្អប្រសើរបំផុត
៣. បង្កើតទេសចរណ៍ធម្មជាតិ(ជាកញ្ចប់)ដែលអាចទាក់ទាញអ្នកទេសចរ រួមទាំងមគ្គុទេសទេសចរណ៍លើដំណើរកំសាន្ត បោះជំរុំ ផ្ទះស្នាក់នៅ (ទេសចរអាចកំសាន្តជាមួយបទពិសោធន៍វប្បធម៌តាមរយៈការស្នាក់នៅជាមួយគ្រួសារប្រជាជន) ឧទ្យានរុក្ខសាស្ត្រ(នៅទីក្រុង) និងផ្តល់ឱកាសឱ្យទេសចរអាចផ្តល់នូវសេវាកម្មដោយស្ម័គ្រចិត្តរបស់ពួកគាត់ក្នុងការស្រាវជ្រាវ និងការវាយតម្លៃស្ថានភាពជីវៈចម្រុះ
៤. រៀបចំបទបញ្ញាផ្ទៃក្នុង និងយុទ្ធសាស្ត្រទីផ្សារ យន្តការចែករំលែកផលប្រយោជន៍ និងមធ្យោបាយក្នុងការត្រួតពិនិត្យតាមដានផលប៉ះពាល់នៃសកម្មភាពអេកូទេសចរណ៍(តាមរយៈការបង្កើតប្រព័ន្ធធានាសុវត្ថិភាព)
៥. រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ដើម្បីបណ្តុះបណ្តាលសហគមន៍មូលដ្ឋានក្នុងគំនិតផ្តួចផ្តើមអនុវត្តន៍ទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិនីមួយៗ

សមាសភាគនៃទេសចរណ៍ធម្មជាតិគួរផ្តោតសំខាន់ ដោយឈរលើមូលដ្ឋាន«**គុណភាពខ្ពស់ ផលប៉ះពាល់ទាប**» ជាបទពិសោធន៍ដល់ភ្ញៀវទេសចរ ដើម្បីធានានូវនិរន្តរភាពនៃគុណតម្លៃតំបន់ការពារធម្មជាតិ។

## ៥.៤ គោលដៅយុទ្ធសាស្ត្រ៤៖ ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ

### ៥.៤.១ ធានាឱ្យមានចំនួនមន្ត្រីគ្រប់គ្រាន់ មានសមត្ថភាព និងធនធានសមស្រប

តម្រូវការជាបន្ទាន់នៅថ្នាក់មូលដ្ឋានគឺផ្តល់ការបណ្តុះបណ្តាល និងធនធានស្របតាមតម្រូវការដល់មន្ត្រីតំបន់ការពារធម្មជាតិ និងឧទ្យានុរក្ស ដើម្បីអនុវត្តន៍ការពង្រឹងអនុវត្តន៍ច្បាប់ប្រកបដោយប្រសិទ្ធភាពត្រួតពិនិត្យតាមដានជីវៈចម្រុះ និងការចូលរួមពីអ្នកពាក់ព័ន្ធ (សូមមើលគយស១.២)។ អាទិភាពបន្ទាន់ចំពោះមុខគឺត្រូវធានាថា ឧទ្យានុរក្សថ្មីចំនួន ៣០០នាក់ ត្រូវបានទទួលការបណ្តុះបណ្តាលកម្រិតមូលដ្ឋានដែលបង្រៀនដោយឧទ្យានុរក្សដែលមានបទពិសោធន៍ខ្ពស់ និងបានឆ្លងកាត់វគ្គបណ្តុះបណ្តាលគ្រូបង្គោល។ ម្យ៉ាងទៀត ត្រូវធានានូវចំនួនមន្ត្រីឧទ្យានុរក្សដែលមានជំនាញដែលបានចាត់តាំងឱ្យទៅកាន់ការងារនៅតាមប្រព័ន្ធតំបន់ការពារធម្មជាតិនឹងមានចំនួនមន្ត្រីជំនាញកាន់តែកើនឡើង ហើយក្រសួងបរិស្ថាននឹងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ភូមិភាគចំនួនបីកន្លែង(ខាងត្បូង ខាងជើង និងខាងកើត) ក្នុងគោលបំណងប្រមូលផ្តុំ ផ្តល់នូវការបណ្តុះបណ្តាលដល់អាជ្ញាធរមូលដ្ឋាន ឧទ្យានុរក្ស និងមន្ត្រីតំបន់ការពារធម្មជាតិ បង្ក

ឱ្យមានភាពកាន់តែជិតស្និទ្ធិ និងលើកកម្ពស់កិច្ចសហការក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិឱ្យកាន់តែមានប្រសិទ្ធភាព។

នៅថ្នាក់ជាតិ (GDANCP/GDLC) និងថ្នាក់ក្រោមជាតិ (មន្ទីរបរិស្ថាន) ក៏មានតម្រូវការបន្ទាន់ប្រហាក់ប្រហែលគ្នានេះដែរ ក្នុងការពង្រឹងសមត្ថភាពជំនាញបច្ចេកទេស ដើម្បីមានលទ្ធភាពផ្តល់នូវការត្រួតពិនិត្យ សម្របសម្រួល និងគាំទ្រដល់អាជ្ញាធរថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។ ដោយភាពចម្រុះស្មុគ្រស្មាញនៃប្រព័ន្ធធម្មជាតិដូច្នេះ សមត្ថភាពលើផ្នែកវិទ្យាសាស្ត្រ និងការស្រាវជ្រាវ គឺជាប្រការសំខាន់ដែលត្រូវធ្វើឱ្យប្រសើរឡើង ជាពិសេសកម្រិតសមត្ថភាពនៃមន្ត្រីជំនាញGDANCP ដើម្បីផ្តល់ការណែនាំ និងបណ្តុះបណ្តាលដល់មន្ត្រីជំនាញថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាន។ ប្រធានបទជាអាទិភាពរួមមាន៖ ការគ្រប់គ្រងសត្វព្រៃ ការធ្វើសារពើភ័ណ្ឌព្រៃឈើ ការធ្វើផែនទីប្រព័ន្ធអេកូឡូស៊ី និងការសិក្សាតម្លៃនៃធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ។ល។ ប្រការដែលត្រូវយកចិត្តទុកដាក់ក្នុងគោលបំណងនេះ គឺការបង្កើតឡើង អង្គភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

ក្រសួងបរិស្ថាននឹងស្វះស្វែងរកអ្នកជំនាញបច្ចេកទេស ដែលមានការយល់ដឹងជាមូលដ្ឋាននូវវិធីសាស្ត្រទំនើប និងថ្មីៗ ដើម្បីសហការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីដែលកំពុងបំរើការងារនឹងត្រូវបានបង្កើតឡើង និងអនុវត្តន៍ក្នុងកម្រិតអាទិភាពជាមូលដ្ឋាន ដោយផ្តល់នូវកញ្ចប់សម្រាប់វគ្គបណ្តុះបណ្តាលតាមលំដាប់លំដោយ។ វគ្គបណ្តុះបណ្តាលទាំងនេះ ត្រូវតែរួមបញ្ចូលនូវការយកចិត្តទុកដាក់ដល់សមធម៌យេនឌ័រ ដើម្បី៖

១. ពង្រឹងប្រសិទ្ធភាពមន្ត្រី និងឧទ្យានុរក្ស ដើម្បីកាត់បន្ថយសកម្មភាពល្មើសច្បាប់ ការគំរាមកំហែងដទៃទៀតនៅក្នុងតំបន់ការពារធម្មជាតិ ការត្រួតពិនិត្យ ការតាមដានស្ថានភាពជីវៈចម្រុះ ការលើកកម្ពស់ចូលរួមជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន និងការបង្កើនជម្រើសមុខរបរសម្រាប់ជីវភាពរស់នៅរបស់សហគមន៍
២. បង្កើនការយល់ដឹងបច្ចេកទេសដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការធ្វើផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការត្រួតពិនិត្យតាមដាន( ឧទា. ការរៀបចំផែនការគ្រប់គ្រង ការសិក្សាវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង ការរៀបចំផែនការតាមបែបសាមញ្ញ ការបង្កើតប្រព័ន្ធត្រួតពិនិត្យតាមដានស្ថានភាពជីវៈចម្រុះ និងការចែករំលែកទិន្នន័យ
៣. ផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស និងការគ្រប់គ្រង ដល់មន្ត្រីថ្នាក់ជាតិ ពីរបៀបសរសេរគម្រោងស្នើសុំថវិកា ការគ្រប់គ្រងគម្រោង និងការអនុវត្តសកម្មភាពទៅតាមលក្ខខណ្ឌគម្រោង។

ការរៀបចំកញ្ចប់ថវិកាលើកទឹកចិត្ត គួរត្រូវបានអនុវត្តន៍សាកល្បងសម្រាប់ជូនដល់មន្ត្រីបំពេញការងារនៅតាមតំបន់ការពារធម្មជាតិ និងផ្តល់ឱកាសឱ្យពួកគេអភិវឌ្ឍន៍ខ្លួន ដោយផ្អែកលើស្នាដៃតាមរយៈការវាយតម្លៃ។ ម៉្យាងវិញទៀត ការរៀបចំ និងពិនិត្យមើលឡើងវិញនូវមូលដ្ឋានសម្ភារៈ បច្ចេកទេស រចនាសម្ព័ន្ធគ្រប់គ្រង គឺជាការចាំបាច់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការធានាថា មន្ត្រីមានឧបករណ៍/វិធានជាមូលដ្ឋាន ដើម្បីឱ្យពួកគេបំពេញការងាររបស់ខ្លួនទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល (សូមមើលគយស ១.២)។

### ៥.៤.២ បង្កើនកិច្ចសហការសិក្សាស្រាវជ្រាវ រៀបចំផែនការ និងអភិវឌ្ឍន៍គោលនយោបាយ

ដើម្បីពង្រឹងកិច្ចសហការអន្តរ-ក្រសួង ក្នុងការអនុម័តវិធីសាស្ត្រអភិរក្សក្នុងកម្រិតដែនទេសភាព សម្រាប់ការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានបានសម្របសម្រួលកំណែទម្រង់អភិបាលកិច្ចបរិស្ថាន ដែលនឹងផ្តល់នូវឱកាសសម្រាប់៖

- ពិនិត្យឡើងវិញនូវច្បាប់និងបទប្បញ្ញត្តិបរិស្ថាននាពេលបច្ចុប្បន្ន សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ដោយលើកកម្ពស់តម្លៃនៃតំបន់ការពារធម្មជាតិ ក្នុងការផ្តល់សេវាប្រព័ន្ធអេកូឡូស៊ី និងការរួមចំណែកដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន
- ដោះស្រាយ និងកំណត់ច្បាស់នូវការទទួលខុសត្រូវលើធនធាន និងដែនយុត្តាធិការត្រួតស៊ីគ្នាក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលដែលមានតួនាទីអភិបាលកិច្ចលើវិស័យធនធានធម្មជាតិ
- ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់និងគោលនយោបាយដែលមានឥទ្ធិពលដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

នៅកម្រិតបច្ចេកទេស កិច្ចសហការលើការស្រាវជ្រាវ និងតាមដានប្រភេទជីវៈចម្រុះ ជាមួយនឹងបណ្តាអង្គភាព សាកលវិទ្យាល័យ អង្គការអភិរក្ស និងដៃគូអភិវឌ្ឍន៍ ដោយរួមបញ្ចូល៖

១. ការបង្កើតនូវការអនុវត្តជាក់ស្តែងឱ្យកាន់តែច្រើនថែមទៀត និងការឆ្លើយតប ដែលផ្សារភ្ជាប់ទៅនឹងការសិក្សាស្រាវជ្រាវតម្រង់ទិសតាមអាទិភាព សម្រាប់ការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

២. កិច្ចខិតខំប្រឹងប្រែងជាក់លាក់ក្នុងការបង្កើតទិន្នន័យគោលអំពីជីវៈចម្រុះ សម្រាប់តំបន់ការពារធម្មជាតិ ដែលអាចត្រូវបានចែករំលែកយ៉ាងទូលំទូលាយ និងបានប្រើសម្រាប់វាស់ស្ទង់ពីភាពរីកចំរើនក្នុងការសម្រេចបានគោលដៅអភិរក្ស

៣. ពង្រីកបន្ថែមតាមគំរូដែលទទួលបានជោគជ័យក្នុងការអនុវត្ត សម្រាប់ការត្រួតពិនិត្យតាមដាន ជីវៈចម្រុះ និងពង្រឹងការអនុវត្ត ដែលនឹងអាចក្លាយទៅជាសកម្មភាពប្រចាំថ្ងៃរបស់មន្ត្រីតំបន់ការពារធម្មជាតិ

៤. ការបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យអភិរក្សប្រមូលផ្តុំនៅក្នុងក្រសួងបរិស្ថាន សម្រាប់ផ្តល់ព័ត៌មានក្នុងដំណើរការរៀបចំផែនការគ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិនីមួយៗ និង

៥. ការចាប់ផ្តើមអនុវត្តន៍សាកល្បងដើម្បីកំណត់តម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

កិច្ចសហការបច្ចេកទេសរវាងក្រសួងបរិស្ថាន និងបណ្តាក្រសួង អង្គការអភិរក្ស និងស្ថាប័នអប់រំសិក្សា នឹងត្រូវសម្របសម្រួលតាមរយៈកិច្ចប្រជុំជាទៀងទាត់ (យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ) ដើម្បីចែករំលែកព័ត៌មាន បង្កើតស្តង់ដាររួមមួយសម្រាប់ការចែករំលែកទិន្នន័យ និងរៀបចំសំណើមូលនិធិសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិដែលជាអាទិភាព។

## ៦. ការបញ្ជ្រាបយេនឌ័រ

ការឆ្លុះបញ្ចាំងក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សមធម៌យេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី គឺជាគោលដៅអភិវឌ្ឍន៍ជាតិយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា និងត្រូវបានចាត់ទុកថាបញ្ហាគន្លឹះ ក្នុងការសម្រេចឱ្យបាននូវការអភិរក្ស និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

នៅតាមតំបន់ជនបទ ភាគច្រើននៃស្ត្រីគឺជាអ្នកដែលមានជីវភាពក្រីក្រ និងស្ថិតក្នុងចំណោមអ្នកដែលងាយរងគ្រោះបំផុត។ ក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាគឺកំពុងយកចិត្តទុកដាក់លើបញ្ហាទាំងនេះ ព្រោះពួកគេពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យកសិកម្ម និងធនធានធម្មជាតិ។ ការលើកកម្ពស់សមធម៌យេនឌ័រនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវអាហារ រូបត្ថម្ភ ឱកាសការងារកាន់តែច្រើន និងធ្វើឱ្យប្រសើរឡើងសុខុមាលភាពគ្រួសារ តាមរយៈការយល់ដឹងពីធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ដែលបានដើរតួនាទីយ៉ាងសំខាន់សម្រាប់ការចិញ្ចឹមជីវិតដល់គ្រួសារសហគមន៍ជនបទ។ ការយល់ដឹងអំពីផលប្រយោជន៍ និងអាទិភាពខុសគ្នារវាងបុរស និងស្ត្រី វិធីសាស្ត្រគ្រប់គ្រងតំបន់ការពារធម្មជាតិ អាចត្រូវបានបង្កើតឡើងដោយកាត់បន្ថយទំនាស់ និងគាំទ្រទាំងការអភិរក្ស និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។ នេះបញ្ជាក់ពីការទទួលខុសត្រូវក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងទិដ្ឋភាពនៃការអនុវត្ត NPASMP ដើម្បីធានាថា បញ្ហាអន្តរវិស័យនឹងទទួលបានការគាំទ្រយ៉ាងទូលំទូលាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ការបញ្ជ្រាបយេនឌ័រទៅក្នុងយុទ្ធសាស្ត្រ និងសកម្មភាពនានា នឹងបង្ហាញអំពីសារៈសំខាន់នៃការផ្ដល់អំណាចដល់ក្រុមស្ត្រី និងក្រុមងាយរងគ្រោះ ឱ្យចូលរួមក្នុងការធ្វើផែនការ ការគ្រប់គ្រង និងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត ដែលទាក់ទងទៅនឹងតំបន់ការពារធម្មជាតិ និងការចែករំលែកផលប្រយោជន៍ដោយសមធម៌ ពីឱកាសក្នុងការប្រកបរបរចិញ្ចឹមជីវិត។ យុទ្ធសាស្ត្រ និងសកម្មភាពទាំងនេះ រួមមាន៖

១.បញ្ចូលឱ្យមានតំណាងយេនឌ័រក្នុងវគ្គបណ្ដុះបណ្ដាល និងការកសាងសមត្ថភាពរបស់មន្ត្រីតំបន់ការពារធម្មជាតិ

២.បញ្ចូលឱ្យមានតំណាងយេនឌ័រក្នុងការបង្កើតកម្មវិធីអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង និងការរៀបចំឯកសារបណ្ដុះបណ្ដាល ជូនដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់(ដោយរាប់បញ្ចូលទាំងស្ត្រី និងយុវជន)

៣.គិតពិចារណាលើតម្រូវការរបស់ស្ត្រីក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យសមស្រប សម្រាប់ការកំណត់តំបន់គ្រប់គ្រង និងការធ្វើផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ (ឧទា. លទ្ធភាពក្នុងការប្រើប្រាស់ទឹក និងប្រមូលអនុផលព្រៃឈើ)

៤.បង្កើតឱកាសក្នុងការប្រកបរបរចិញ្ចឹមជីវិតដែលគិតគូរទៅលើសមត្ថភាព និងកម្លាំងរបស់ស្ត្រី (ឧទា. គម្រោងមីក្រូឥណទាន ទេសចរណ៍តាមបែបសហគមន៍ សិប្បកម្មកែច្នៃអនុផលព្រៃឈើ)

៥.ធានាឱ្យបាននូវផ្នែកមួយនៃប្រភពចំណូលពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី (ឧទា. ការស្រូបកាបោន) ដើម្បីរក្សាទុកជាពិសេសសម្រាប់ការលើកកម្ពស់សមធម៌ និងជាផលប្រយោជន៍នៅក្នុងសហគមន៍

៦.បង្កើតលក្ខណៈវិនិច្ឆ័យសមធម៌យេនឌ័រ និងកំណត់គោលដៅសូចនាករ សម្រាប់ត្រួតពិនិត្យតាមដានវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ការចូលរួមយ៉ាងសកម្មរបស់ស្ត្រីក្នុងការអនុវត្តគោលដៅ និងសកម្មភាពរបស់ NPASMP នឹងពង្រឹងសមធម៌យេនឌ័រ ជំរុញការអភិរក្ស និងការលើកស្ទួយជម្រើសនៃការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានជាក់ស្ដែង ស្របជាមួយនឹងផលប្រយោជន៍ និងអាទិភាពទាំងបុរសនិងស្ត្រី។

## ៧. ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

តំបន់ការពារធម្មជាតិជាតំណាងឱ្យឱកាសតែមួយគត់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ដែលតួនាទីរបស់វាចូលរួមកាត់បន្ថយផលប៉ះពាល់ពីគ្រោះខ្យល់ព្យុះ ទឹកជំនន់ និងរាំង

ស្ងួត ហើយក៏ផ្តល់ជម្រើសសម្រាប់សង្គមក្នុងការលើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការស្រូបយកកាបោន និងការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ។ ការសិក្សាលើអត្ថបទជាង១០០នាពេលថ្មីៗនេះ វិធានការដែលពេញនិយមជាងគេសម្រាប់ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺការពង្រីកចំនួនផ្ទៃដីតំបន់ការពារធម្មជាតិ [5]។ ហេតុនេះហើយ បានជាការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃយុទ្ធសាស្រ្តយ៉ាងសំខាន់ក្នុងការបន្សុាំ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ការគិតគូរដើម្បីរួមចំណែកជាមួយសកលលោកទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំ NPASMP ដោយផ្តោតទាំងការកាត់បន្ថយ និងការបន្សុាំ។ ចំពោះការកាត់បន្ថយការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍សកម្មភាពដើម្បីអនុវត្តន៍រេដបូកនៅក្នុងតំបន់គោលដៅដែលបានជ្រើសរើស ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ រួមផ្សំនឹងការស្រូបកាបោន និងការគាំទ្រក្នុងការបង្កើតកម្មវិធីហិរញ្ញប្បទានដោយនិរន្តរភាព សម្រាប់កាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងពង្រឹងការអភិរក្ស។ ការលើកកម្ពស់សកម្មភាពបង្កើនការស្តុកកាបោនតាមរយៈការខិតខំស្តារ ការពារ និងអភិរក្សព្រៃឈើ (ពិសេសនៅក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាព) លើជម្រើសផ្សេងៗនៃការប្រើប្រាស់ដី អាចផ្តល់ផលចំណេញទាំងខាងតម្លៃសេដ្ឋកិច្ច និងការអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ នោះបើប្រៀបធៀបទៅនឹងការវិនិយោគដែលកាប់ព្រៃក្នុងផ្ទៃដីធំៗ (ឧទា. ការរុករករ៉ែ ការដាំដំណាំកសិ-ឧស្សាហកម្ម)។

ចំពោះការបន្សុាំ យើងមានផែនការរៀបចំយុទ្ធសាស្ត្រ ក្នុងការវាយតម្លៃហេតុប៉ះពាល់នាពេលអនាគតនៃការប្រែប្រួលអាកាសធាតុទៅលើធនធានជីវៈចម្រុះ សេវាប្រព័ន្ធអេកូឡូស៊ី និងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ សកម្មភាពទាំងនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំកំណត់តំបន់ និងផែនការគ្រប់គ្រង សម្រាប់តំបន់ការពារធម្មជាតិនីមួយៗ ក៏ដូចជាការបង្កើតសកម្មភាពលើកកម្ពស់ការចិញ្ចឹមជីវិតផងដែរ។ ការរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់អនាគត ការគិតគូរទៅលើការប្រែប្រួលអាកាសធាតុ គឺជាប្រការសំខាន់ ដោយត្រូវបង្កើតប្រព័ន្ធដែលមានលក្ខណៈគ្រប់គ្រាន់តំណាងឱ្យប្រព័ន្ធអេកូឡូស៊ីមួយពេញលេញ និងផ្សារភ្ជាប់គ្នាបានល្អ ហើយមានភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលបានព្យាករណ៍សម្រាប់ពេលអនាគត។

## ៨. ធនធានហិរញ្ញវត្ថុ

ច្បាប់នៃតំបន់ការពារធម្មជាតិ (ជំពូកទីVII) សំដៅលើមូលនិធិតំបន់ការពារធម្មជាតិ រួមបញ្ចូល **ទាំងមូលនិធិតំបន់ការពារធម្មជាតិ** ក្រោមការគ្រប់គ្រងជាលក្ខណៈអន្តរក្រសួងដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មូលនិធិដែលបានលើកឡើងក្នុងឯកសារនេះ គឺមិនទាន់បានបង្កើតនៅឡើយទេ ហើយការវិភាជន៍ថវិកាជាតិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិក៏នៅមានកម្រិតជាពិសេស បើប្រៀបធៀបទៅនឹងប្រទេសផ្សេងទៀតដែលមានទំហំផ្ទៃដីតំបន់ការពារធម្មជាតិគ្របដណ្តប់តូចជាងប្រទេសកម្ពុជា។ ជាលទ្ធផលថវិកាក្រសួងបរិស្ថាននាពេលបច្ចុប្បន្ន គឺបានត្រឹមតែសម្រាប់បៀវត្សមន្ត្រី ការចុះពិនិត្យនៅទីវាល និងការងាររដ្ឋបាល ហើយថវិកាទាំងនេះផ្តល់ឱកាសតិចតួចប៉ុណ្ណោះ សម្រាប់

[5] Heller, N. and E. Zavaleta (2009); Biodiversity management in the face of climate change: A review of 22 years of recommendations. Biological Conservation 142(1): 14-32.

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាព និងការបណ្តុះបណ្តាល[6]។ ការកើនឡើងនៃថវិកាបន្តិចម្តងៗសម្រាប់ក្រសួងបរិស្ថានក្នុងពេលថ្មីៗនេះ គឺជាជំហានវិជ្ជមានមួយ ហើយតម្រូវឱ្យមានការបង្កើនថែមទៀត ដើម្បីប្រសិទ្ធិភាពក្នុងការបំពេញតួនាទី និងភារកិច្ចទទួលខុសត្រូវ លើទំហំការងារកាន់តែធំឡើងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលរាជរដ្ឋាភិបាលបានប្រគល់ជូនក្រសួងបរិស្ថាន។ ថវិកាមួយភាគធំសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការអភិរក្សជីវៈចម្រុះ ដែលបានផ្តល់នៅក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ គឺមួយភាគធំ ជាជំនួយលក្ខណៈពហុភាគី និងទ្វេភាគី ពីទីភ្នាក់ងារអង្គការអភិរក្សមួយចំនួន។ ដូច្នេះការងារបន្ទាន់ តម្រូវឱ្យបង្កើតផែនការកៀរគរធនធាន ដោយប្រើពិពិធកម្មមូលនិធិពីប្រភពផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការមូលនិធិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ប្រភេទនៃប្រភពមូលនិធិដែលត្រូវយកចិត្តទុកដាក់ដូចមានសង្ខេបខាងក្រោម៖

| ប្រភពមូលនិធិ | ឧទាហរណ៍ |
|---|---|
| មូលនិធិរាជរដ្ឋាភិបាល | ➢ ថវិកាជាតិ<br>➢ ម្ចាស់ជំនួយ (ពហុភាគី និងទ្វេភាគី)<br>➢ មូលនិធិអាកាសធាតុបៃតង (មូលនិធិ REDD+)<br>➢ មូលនិធិបរិស្ថានសកល (GEF-STAR-6)<br>➢ សំណងពីការបង់ថ្លៃការខូចខាតធនធានធម្មជាតិដោយសារការវិនិយោគ (Debt-for-Nature swaps)<br>➢ មូលនិធិទ័យទាន (Trust funds) (ឧទា.មូលនិធិតំបន់ការពារធម្មជាតិ) |
| ការបង់ពន្ធនិងការបង់ថ្លៃបន្ថែម | ➢ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច (បន្ទាប់ពីបានប្រតិបត្តិការអស់រយៈពេល៥ឆ្នាំ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមានកាតព្វកិច្ចបង់ប្រាក់ឈ្នួល១$/ហិកតា/ ឆ្នាំ ពីជួលដី)<br>➢ ការទូទាត់ពីវារីអគ្គីសនី និងសម្បទានរ៉ែ ("ការទូទាត់សំណងជុសជុលពីការបាត់បង់ជីវៈចម្រុះ")<br>➢ ពន្ធនៃការលើកទឹកចិត្តសម្រាប់ការអភិរក្សប្រព័ន្ធអេកូឡូស៊ី<br>➢ ការបង់ពន្ធបន្ថែមសម្រាប់សេវាសណ្ឋាគារ<br>➢ ការបង់ពន្ធបន្ថែមលើអាកាសយានដ្ឋានសម្រាប់ភ្ញៀវអន្តរជាតិ |
| តម្លៃសំបុត្រចូលទស្សនាតាមរមណីយដ្ឋាននានានៃតំបន់ការពារធម្មជាតិ តម្លៃសេវា និងការផ្តល់អាជ្ញាប័ណ្ណ | ➢ តម្លៃសម្រាប់ការចូលទស្សនានៅក្នុងតំបន់ការពារធម្មជាតិ<br>➢ តម្លៃសម្បទានទេសចរណ៍<br>➢ ការទូទាត់តម្លៃសេវាកម្មបរិស្ថាន (ឧទា. ទឹក កាបោន)<br>➢ តម្លៃសំណងផ្លូវច្បាប់ និងផាកពិន័យ |
| មូលនិធិសប្បុរសធម៌ ការផ្តល់វិភាគទាន និងការបែងចែកការចំណាយ | ➢ ការសហការ (CSR) និងការបរិច្ចាគជាលក្ខណៈបុគ្គល<br>➢ ដៃគូឯកជន-សាធារណៈ<br>➢ ការងារស្ម័គ្រចិត្តដើម្បីកាត់បន្ថយថ្លៃចំណាយបុគ្គលិក<br>➢ សហគ្រប់គ្រងជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ<br>➢ ការបង់ថ្លៃបន្ថែមដោយស្ម័គ្រចិត្ត (ភ្ញៀវចូលរួមវិភាគទាន តាមសណ្ឋាគារ និងតាមរយៈ"ប្រអប់វិភាគទាន" នៅតាមមជ្ឈមណ្ឌលសម្រាប់ភ្ញៀវទេសចរនៅក្នុងតំបន់ការពារធម្មជាតិ) |
| ចំណូលមកពីការលក់ផលិតផល | ➢ ផលិតផល ទំនិញ និងសេវាកម្មពីតំបន់ការពារធម្មជាតិ |

[6] ឆ្នាំ២០១៧ ថវិកាក្រសួងបរិស្ថានគឺតំណាងឱ្យតិចជាង0,40% នៃថវិកាប្រតិបត្តិប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជាទាំងមូល។

ក្រោមការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) ការពិនិត្យឡើងវិញនូវឱកាសក្នុងការចាត់ចែងនានា និងការប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាលសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ គឺជាកត្តាចាំបាច់ ដើម្បីអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ(NPASMP)។ នៅក្នុងការធ្វើកំណែទម្រង់សារពើពន្ធថ្នាក់ជាតិ គួរបញ្ចូលនូវការកំណត់យន្តការហិរញ្ញប្បទានថ្មីៗ ដើម្បីធានាតម្រូវការចាំបាច់លើដំណើរការគ្រប់គ្រងតំបន់ការពារធម្មជាតិ ហើយត្រូវបញ្ជ្រាបទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការថវិកាជាតិ។ ម្យ៉ាងវិញទៀត សកម្មភាពជាច្រើនដែលបានលើកស្នើឡើងក្នុងផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនេះ គឺតម្រូវឱ្យមានជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីខាងក្រៅ ជាពិសេស ការពង្រឹងសមត្ថភាពជាមូលដ្ឋានរបស់អគ្គនាយកដ្ឋានសំខាន់ទាំងពីរ (GDANCP និង GDLC) ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលវាជាសកម្មភាពអាទិភាព និងចាំបាច់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា។

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ(២០១៧-២០៣១) ត្រូវបានប៉ាន់ប្រមាណនូវតម្រូវការហិរញ្ញប្បទានប្រមាណ ៤៦.៨លានដុល្លា សម្រាប់រយៈពេល ៥ ឆ្នាំដំបូងដើម្បីចំណាយលើកម្មវិធីនៃគោលដៅយុទ្ធសាស្ត្រទាំងបួន ដែលបានកំណត់នៅក្នុង NPASMP នេះ(ឧបសម្ព័ន្ធ៤)។ ការចំណាយដែលបានលើកឡើងទាំងនេះ គឺជាតម្រូវការចំណាយបន្ថែមពីលើប្រាក់បៀវត្សរបស់មន្ត្រី និងការចំណាយរដ្ឋបាលនាពេលបច្ចុប្បន្ន ដែលបានផ្តល់ដោយក្រសួងបរិស្ថាន។

ជាចំណែកនៃការអនុវត្តថវិកាតាមកម្មវិធីដែលបានចាប់ផ្តើមក្នុងឆ្នាំ២០១៦ បច្ចុប្បន្នអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន គឺមានគណនី និងថវិកាផ្ទាល់ដែលអាចចាត់ចែងតាមអាទិភាពក្នុងការវិនិយោគប្រចាំឆ្នាំទៅឱ្យតំបន់ការពារធម្មជាតិនីមួយៗ។ បច្ចុប្បន្នគឺមិនទាន់មានយន្តការទូទៅសម្រាប់បង្វែរហិរញ្ញប្បទានមកពីខាងក្រៅ និងប្រាក់ចំណូលដែលទទួលបានពីការផាកពិន័យ និងប្រាក់ពន្ធ ដើម្បីចំណាយលើប្រតិបត្តិការ វិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬកិច្ចខិតខំស្តារទីជម្រកឡើងវិញក្នុងតំបន់ការពារធម្មជាតិនៅឡើយទេ។ ជាផ្នែកមួយនៃការធ្វើកំណែទម្រង់សារពើពន្ធ គឺការពិចារណាទៅលើការបង្វែរប្រាក់ចំណូលទាំងនោះ មកអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន សម្រាប់បម្រើឱ្យដំណើរការដឹកនាំ និងគ្រប់គ្រងតំបន់ការពារធម្មជាតិបន្ថែមពីលើថវិកាជាតិដែលមានស្រាប់។

## ៩. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (NPASMP) ក្នុងរយៈពេល ១៥ឆ្នាំ(២០១៧-២០៣១) គឺអាចស្របពេលជាមួយនឹងកម្មវិធីព្រៃឈើជាតិ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ សម្រាប់ជលផល ដែលជាបណ្តាផែនការយុទ្ធសាស្ត្រផ្សេងទៀតមានឥទ្ធិពលដល់ការគ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេសកម្ពុជា។

NPASMP នេះ នឹងត្រូវបានពិនិត្យសារឡើងវិញរៀងរាល់ ៥ ឆ្នាំម្តង (ក្នុងឆ្នាំ២០២១, ២០២៦, និង២០៣១) ដើម្បីវាយតម្លៃពីវឌ្ឍនភាព និងអាចធ្វើការកែសម្រួលតាមការចាំបាច់។ ក្របខណ្ឌលទ្ធផលការងារដែលរួមមានសូចនាករសម្រាប់នាយកដ្ឋាននីមួយៗដឹកនាំអនុវត្តន៍ និងគោលដៅ ដែលត្រូវសម្រេចបាន (ក្នុងរយៈពេល ខ្លី មធ្យម និងវែង) ទៅតាមគោលដៅយុទ្ធសាស្ត្រនីមួយៗនឹងត្រូវប្រើប្រាស់ដើម្បី

ត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិធៀបជាមួយ ទិន្នន័យគោលបច្ចុប្បន្ន (ឧបសម្ព័ន្ធ៣)។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវដឹកនាំអនុវត្តន៍ ដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ (GDANCP) និងអគ្គនាយកដ្ឋានសហគមន៍ មូលដ្ឋាន (GDLC) ដោយត្រូវធានាថា នាយកដ្ឋានជំនាញចំណុះឱ្យអគ្គនាយកដ្ឋានទាំងអស់ បានរៀបចំ ផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយលើកឡើងនូវបណ្តាសកម្មភាពអាទិភាព ដែលនាយកដ្ឋាននីមួយៗជាអ្នក ដឹកនាំ ឬសហការអនុវត្តន៍។ ស្រដៀងគ្នានេះដែរ មន្ទីរបរិស្ថានខេត្ត និងនាយកនៃតំបន់ការពារធម្មជាតិ នីមួយៗ ត្រូវរៀបចំដាក់បញ្ចូលនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនូវសកម្មភាពដែលពាក់ព័ន្ធទៅនឹងតំបន់របស់ ខ្លួនជាក់លាក់។ ការត្រួតពិនិត្យតាមដាន និងធ្វើរបាយការណ៍ត្រូវអនុវត្តន៍តាមទម្រង់មួយឯកភាពគ្នា ដើម្បី វាស់ស្ទង់ពីវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅប្រចាំឆ្នាំ។ រីឯ NCSD ក៏ត្រូវជួយសម្របសម្រួលក្នុងការ អនុវត្តសកម្មភាពអាទិភាពណាដែលមានការពាក់ព័ន្ធទៅនឹងអន្តរក្រសួង-ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ផងដែរ។

កម្មវិធីអនុសញ្ញាជីវៈចម្រុះដែលអនុវត្តន៍ការងារក្នុងតំបន់ការពារធម្មជាតិ (គោលដៅទី៤.២) បាន លើកទឹកចិត្តរាជរដ្ឋាភិបាលឱ្យត្រួតពិនិត្យតាមដាន និងធ្វើឱ្យមានប្រសិទ្ធភាពកាន់តែប្រសើរសម្រាប់តំបន់ ការពារធម្មជាតិ។ ការវាយតម្លៃប្រសិទ្ធិភាពនៃការគ្រប់គ្រងជាសំខាន់ គឺការវាយតម្លៃអំពីកម្រិតនៃភាព ជោគជ័យដែលសម្រេចតាមគោលដៅនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ លទ្ធផលពីការវាយតម្លៃ នឹង ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ជាតិ និងផ្តល់អនុសាសន៍សំខាន់ៗសម្រាប់ការអនុវត្តបន្ត ដែលជាផ្នែក មួយនៃយុទ្ធសាស្ត្រគ្រប់គ្រង។ សម្រាប់វិធីសាស្ត្រស្តង់ដា ដែលបានប្រើប្រាស់ក្នុងការវាយតម្លៃប្រសិទ្ធិភាពនៃ ការគ្រប់គ្រងកន្លងមកនៅក្នុងប្រទេសកម្ពុជា រួមមាន ការវាយតម្លៃរហ័សនិងការកំណត់អាទិភាពនៃការ គ្រប់គ្រងតំបន់ការពារធម្មជាតិ និងវិធានគ្រប់គ្រងតាមដានប្រសិទ្ធភាពសាមញ្ញ GEF (ឧទា. RAPPAM និង GEF-METT)។ សម្រាប់ការវាយតម្លៃនាពេលអនាគត បណ្តាសូចនាករអាចសម្រួលឡើងវិញ ដើម្បី វាស់វែងឱ្យដឹងថា តើតំបន់ការពារធម្មជាតិកំពុងត្រូវបានគ្រប់គ្រងនោះអនុវត្តបានល្អដល់កម្រិតណាជាមួយ នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ (ភាពធន់ ការបន្សាំ និងការកាត់បន្ថយ) និងការចិញ្ចឹមជីវិត ប្រកបដោយនិរន្តរភាព។

## ១០. សន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ (NPASMP) បង្ហាញអំពីតម្រូវការ បន្ទាន់សម្រាប់ការវិនិយោគថ្មីក្នុងតំបន់ការពារធម្មជាតិ ដើម្បីសម្រេចបាននូវសក្តានុពលរបស់វា ក្នុងការរួម ចំណែកដល់សេដ្ឋកិច្ចកម្ពុជា ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ដែលមានគោលដៅ សំខាន់សម្រាប់ជួយដល់ក្រុមជនងាយរងគ្រោះនៅក្នុងសង្គម។ ខណៈដែលរាជរដ្ឋាភិបាលមិនទាន់បានប៉ាន់ ប្រមាណអំពីតម្លៃ និងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីនៃតំបន់ការពារធម្មជាតិទាំងនេះ ដោយការគណនា ជាទឹកប្រាក់បាននោះ យើងអាចនិយាយដោយគ្មានក្តីបារម្ភថា តម្លៃមហាសាលគួរឱ្យកត់សម្គាល់នេះ គឺមាន កម្រិតគ្របដណ្តប់ល្មឹងល្មើយស្របតាមវិសាលភាពដ៏ធំទូលាយនៃតំបន់ការពារធម្មជាតិ។ តែទោះយ៉ាងណាក្តី តំបន់ធម្មជាតិ និងបេតិកភ័ណ្ឌធម្មជាតិ និងវប្បធម៌ទាំងនេះ បច្ចុប្បន្នកំពុងស្ថិតនៅក្រោមសម្ពាធនៃការ

បាត់បង់ទីជម្រកធម្មជាតិ ការប្រើប្រាស់ដោយគ្មាននិរន្តរភាព និងសកម្មភាពខុសច្បាប់ដែលកើតមានឡើងទូទាំងតំបន់ការពារធម្មជាតិ។

តម្រូវការបច្ចុប្បន្នគឺការវិនិយោគ ដែលនឹងអភិវឌ្ឍន៍សមត្ថភាពដល់ក្រសួងបរិស្ថាន (ជាពិសេសអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន) ដើម្បីពង្រឹងការគ្រប់គ្រង អភិរក្ស និងពង្រឹងការអនុវត្តច្បាប់ ពង្រីកឱកាសសម្រាប់ជីវភាពសហគមន៍ និងគាំទ្រការប្រើប្រាស់ធនធានដោយនិរន្តរភាពក្នុងតំបន់ការពារធម្មជាតិ។ កិច្ចសហការក្នុងកម្រិតមួយដែលមិនធ្លាប់មានពីមុនមកនឹងតម្រូវឱ្យមានរវាងបណ្ដាក្រសួង វិស័យឯកជន អង្គការអភិរក្ស និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាថាប្រព័ន្ធតំបន់ការពារធម្មជាតិនឹងបន្តការផ្ដល់នូវអត្ថប្រយោជន៍ដល់គ្រប់ជំនាន់នាពេលអនាគត។

# ឧបសម្ព័ន្ធ១ បញ្ជីតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា

| កូដ | តំបន់ការពារធម្មជាតិ | PROTECTED AREA | ផ្ទៃក្រឡា(ហ.ត) |
|---|---|---|---|
| | **ឧទ្យានជាតិ ១២** | **National Park 12** | **១.៧២០.២៦៩,៣៥** |
| ១ | ព្រះសុរាម្រិត-កុសមៈ (គិរីរម្យ) | Preah Soramarith Kosamak "Kirirom" | ៣៥.២៣២ |
| ២ | ព្រះមុនីវង្ស (បូកគោ) | Preah Munivong "Bokor" | ១៥៤.៤៥៨ |
| ៣ | កែប | Kep | ១.១៥២ |
| ៤ | ព្រះសីហនុ (រាម) | Pheah Sihanouk "Ream" | ១៥.០០០ |
| ៥ | បុទុមសាគរ | Botum Sakor | ១៧១.២៥០ |
| ៦ | ព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) | Preah Cheyvarama "Phnom Kulen" | ៣៧.៥០០ |
| ៧ | វីរៈជ័យ | Virachey | ៣៣២.៥០០ |
| ៨ | វើនសៃ-សៀមប៉ាង | Vensai Siempang | ៥៧.៤៦៩ |
| ៩ | ជួរភ្នំក្រវាញកណ្ដាល | Central Cardamom | ៤០១.៣១៣ |
| ១០ | អូយ៉ាដាវ | O'Yadao | ១០១.៣៤៨ |
| ១១ | ជួរភ្នំក្រវាញខាងត្បូង | Southern Cardamom | ៤១០.៣៩២ |
| ១២ | កោះរុង | Koh Rong | ២.៦៥៥,៣៥ |
| | **ដែនជម្រកសត្វព្រៃ ១៨** | **Wildlife Sanctuary 18** | **៣.៦៨៤.៣២៨** |
| ១៣ | ភ្នំឱរ៉ាល់ | Phnom Aural | ២៥៣.៧៥០ |
| ១៤ | ពាមក្រសោប | Peam Krasop | ២៣.៧៥០ |
| ១៥ | ភ្នំសំកុស | Phnom Somkos | ៣៣៣.៧៥០ |
| ១៦ | រនាមដូនសំ | Ronien Daun Sam | ១៧៨.៧៥០ |
| ១៧ | គូលែន-ព្រហ្មទេព | Kulen Promtep | ៤០២.៥០០ |
| ១៨ | បឹងពែរ | Beng Per | ២៤២.៥០០ |
| ១៩ | លំផាត់ | Lomphat | ២៥០.០០០ |
| ២០ | ភ្នំព្រេច | Phnom Prich | ២២២.៥០០ |
| ២១ | ភ្នំណាមលៀរ | Phnom NamLyr | ៤៧.៥០០ |
| ២២ | ស្នួល | Snoul | ៧៥.០០០ |
| ២៣ | ព្រៃឡង់ | Prey Lang | ៤៣១.៦៨៣ |
| ២៤ | ព្រះរការ | Preah Roka | ៩០.៣៦១ |
| ២៥ | សៀមប៉ាងខាងលិច | Western Siempang | ៦៥.៣៨៩ |
| ២៦ | ឆែប | Chhaeb | ១៩០.០២៧ |
| ២៧ | តាតៃ | Tatai | ១៤៤.២៧៥ |
| ២៨ | កែវសីមា | Koe Seima | ២៩២.៦៩០ |
| ២៩ | ស្រែពក | SrePok | ៣៧២.៩៧១ |
| ៣០ | សៀមប៉ាង | Siem Pang | ៦៦.៩៣២ |

| | | | |
|---|---|---|---|
| | **តំបន់ការពារទេសភាព ៨** | **Protected Landscape 8** | **១៤៩.៣៤៧,៣០** |
| ៣១ | អង្គរ | Angkor | ១០.៨០០ |
| ៣២ | បន្ទាយឆ្មារ | Banteay Chhmar | ៨១.២០០ |
| ៣៣ | ព្រះវិហារ | Preah Vihear | ៥.០០០ |
| ៣៤ | អន្លង់ព្រីង | An Long Pring | ២១៧ |
| ៣៥ | ទំនាបខាងជើងទន្លេសាប | North TonleSap | ៣១.១៥៩ |
| ៣៦ | បឹងព្រែកល្ពៅ | Boeung Prek Lpov | ៨.៣០៥ |
| ៣៧ | អាងត្រពាំងថ្ម | Ang Trapeng Thmor | ១២.៦៥០ |
| ៣៨ | បឹងព្រែកទប់ | Boeng Prektub | ១៦,៣០ |
| | **តំបន់ប្រើប្រាស់ច្រើនយ៉ាង ៥** | **Multiple Use Area 5** | **៤០៩.៦៦៩** |
| ៣៩ | ដងពែង | Dong Peng | ២៧.៧០០ |
| ៤០ | សំឡូត | Samlaut | ៦០.០០០ |
| ៤១ | ទន្លេសាប | Tonle Sap | ៣១៦.២៥០ |
| | *តំបន់ស្នូលបឹងទន្លេឆ្មារ (តំបន់រ៉ាមសារ)* | *Boeng Chhmar Core Area (Ramsar Site)* | *(១៤.៥៦០)* |
| | *តំបន់ស្នូលព្រែកទាល់ (តំបន់រ៉ាមសារ)* | *Prek Toal Core Area (Ramsar Site)* | *(២១.៣៤២)* |
| | *តំបន់ស្នូលស្ទឹងសែន* | *Stung Sen Core Area* | *(៦.៣៥៥)* |
| ៤២ | ពញាក្រែក | Punchearkrek | ១៩៩ |
| ៤៣ | ព្រែកទឹកសាបក្បាលឆាយ | Kbal Chay | ៥.៥២០ |
| | **តំបន់រ៉ាមសារ ៤** | **Ramsar 4** | **១៤.៦០០** |
| ៤៤ | ស្ទឹងត្រែង | Stung Treng | ១៤.៦០០ |
| | *(កោះកាពិ)* | *(Koh Kapik)* | *(១.២០០)* |
| | *(បឹងទន្លេឆ្មារ)* | *(Boeng Chhmar )* | *(១៤.៥៦០)* |
| | *(ស្នូលព្រែកទាល់)* | *(Prek Toal)* | *(២១.៣៤២)* |
| | **តំបន់បេតិកភណ្ឌធម្មជាតិ ១** | **Natural Heritage Park 1** | **២៤.៦៥៤** |
| ៤៥ | ភ្នំត្បែង | Phnom Tberng | ២៤.៦៥៤ |
| ៤៦ | **របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ** | **Biodiversity Cooridor of Protected Area** | **១.៤២៧.៩៤០** |
| | *របៀងអភិរក្សជីវៈចម្រុះឦសាន* | *NorthEast Corridor* | *(៧៥៧.៦៦១)* |
| | *របៀងអភិរក្សជីវៈចម្រុះឧត្តរ* | *NorthWest Corridor* | *(៥០០.៨១០)* |
| | *របៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ* | *Cardamom Corridor* | *(១៦៩.៤៦៩)* |
| | | **សរុបផ្ទៃដី** | **៧.៤៣០.៨០៧,៦៥** |

**កំណត់សម្គាល់៖**

១. តំបន់ប្រើប្រាស់ច្រើនយ៉ាង ទន្លេសាប នៃតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ចែកចេញជា ០៣ តំបន់ស្នូលគឺ បឹងទន្លេឆ្មារ ព្រែកទាល់ និងស្ទឹងសែន

២. របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ចែកចេញជា ០៣ របៀងអភិរក្សជីវៈចម្រុះគឺ ឦសាន ឧត្តរ និងជួរភ្នំក្រវាញ

៣. តំបន់រ៉ាមសារកោះកាពិ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃពាមក្រសោប និង ឧទ្យានជាតិបុទុមសាគរ

# ឧបសម្ព័ន្ធ២ ផែនទីតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា



# ឧបសម្ព័ន្ធ៣ ថវិកានិងសូចនាករលទ្ធផលនៃ NPASMP (២០១៧-២០៣១)

**សំគាល់៖** ថវិកាខាងក្រោមនេះ គឺពាក់ព័ន្ធនឹងរយៈពេលផែនការប្រាំឆ្នាំដំបូងប៉ុណ្ណោះ (២០១៧-២០២១) ដោយត្រូវបន្ថែមទៅលើការចំណាយសំខាន់ៗសម្រាប់មន្ត្រី និងការប្រតិបត្តិ ដែលបានផ្តល់ដោយក្រសួងបរិស្ថានបច្ចុប្បន្ន។

| គោលដៅយុទ្ធសាស្ត្រ គយស | សូចនាករលទ្ធផល | អគ្គនាយកដ្ឋានជំនាញ (ចំណុះ MoE)[៧] | ព័ត៌មានមូលដ្ឋាន (២០១៦) | ទិសដៅ ២០២១ | ថវិកា ២០១៧-២០២១ (ដុល្លារអាមេរិច) | ទិសដៅ ២០២១ | ទិសដៅ ២០៣១ |
|---|---|---|---|---|---|---|---|
| **គោលដៅយុទ្ធសាស្ត្រទី១- កំណត់អត្តសញ្ញាណនិងពង្រឹងការការពារនិងអភិរក្សធនធានធម្មជាតិ** | | | | | | | |
| **គយស ១.១-** ធានាឱ្យបាននូវព្រំប្រទល់តំបន់ការពារធម្មជាតិ ការកំណត់និងបែងចែកតំបន់គ្រប់គ្រង និងផែនការគ្រប់គ្រង | ក) ចំនួនតំបន់ការពារធម្មជាតិដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់នៅចំណុចច្រកចេញចូល (ផ្លូវធំ និងតូចៗល។) | GDANCP/GDLC និងការគាំទ្របច្ចេកទេសពី GIS-GDEKI | ៧ PAs | ៣៧ PAs | ១,៦២៥,០០០[១] | ១០០% នៃ PAs | ១០០% នៃ PAs |
| | ខ) ចំនួនតំបន់ការពារធម្មជាតិដែលមានព័ត៌មានច្បាស់លាស់ និងផែនការគ្រប់គ្រងសាមញ្ញ | GDANCP | ០ | ២៥ | ១,៥០០,០០០[២] | ១០០% | ១០០% |
| | គ) ចំនួនតំបន់ការពារធម្មជាតិទទួលបានផែនការគ្រប់គ្រងតំបន់ផ្លូវការ | GDANCP/GDLC និងការគាំទ្របច្ចេកទេសពី GIS-GDEKI | ៣ | ២៥ | ១,១០០,០០០[៣] | ៧៥% | ១០០% |
| | ឃ) ចំនួនរបៀងអភិរក្សជីវៈចម្រុះដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់ និងទទួលស្គាល់ផ្លូវការ | GDANCP/GDLC និងការគាំទ្របច្ចេកទេសពី GIS-GDEKI | ០ | ៥០% | ១,៥០០,០០០[៤] | ១០០% | ១០០% |
| | ង) ត្រួតពិនិត្យ តាមដាននិងវាយតម្លៃធនធានធម្មជាតិ | GDANCP | ០ | ២ លើក | ១,៥០០,០០០[៥] | | |
| **គយស ១.២-** ពង្រឹងការអនុវត្តច្បាប់ និងកាត់បន្ថយការគំរាមកំហែង | ក) ចំនួនតំបន់ការពារធម្មជាតិនឹងបានបំពាក់ឧបករណ៍ទំនើបសម្រាប់ពង្រឹងការអនុវត្តច្បាប់និងត្រួតពិនិត្យជីវៈចម្រុះ | GDANCP | ៤ | ៣០ | ៣,២៥០,០០០[៦] | ១០០% | ១០០% |
| | ខ) ចំនួនមន្ត្រីឧទ្យានុរក្សនឹងបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ | GDANCP | ៣០០ | ១,០០០ | ១,០៥០,០០០[៧] | ១០០% | ១០០% |
| | គ) ចំនួនតំបន់ការពារធម្មជាតិដែលសហគមន៍បានទទួលចំណេះដឹងផ្នែកបរិស្ថាន និងផ្នែកយេនឌ័រ | GDANCP/GDLC/GDEKI | ៤ | ៣០ | ១,៣០០,០០០[៨] | ៧៥% | ១០០% |

[៧] អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន

| គោលដៅយុទ្ធសាស្ត្រ គយស | សូចនាករលទ្ធផល | អគ្គនាយកដ្ឋានជំនាញ (ចំណុះ MoE)[៧] | ព័ត៌មានមូលដ្ឋាន (២០១៦) | ទិសដៅ ២០២១ | ថវិកា ២០១៧-២០២១ (ដុល្លារអាមេរិច) | ទិសដៅ ២០២១ | ទិសដៅ ២០៣១ |
|---|---|---|---|---|---|---|---|
| **គយស ១.៣-** បង្កើនការអភិរក្ស និងស្តារឡើងវិញនូវប្រភេទជីវៈចម្រុះ | ក) ចំនួនតំបន់ការពារធម្មជាតិដែលមានផែនការសកម្មភាពអភិរក្សប្រភេទជីវៈចម្រុះជាក់លាក់ | GDANCP | 0 | ១៥ | ១,១២៥,000[៩] | ៥0% | ១00% |
| | ខ) ចំនួនតំបន់ការពារធម្មជាតិដែលទទួលបានការស្តារព្រៃឈើ និងរុក្ខជាតិនានាក្រោមការអនុវត្ត | GDANCP | 0 | ១៥ | ៣,៧៥0,000[១០] | ៥0% | ១00% |
| **គយស ១.៤-** ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ | ក) មន្ត្រី GDANCP/GDLC នឹងចូលរួមក្នុងសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាសំខាន់ៗ | គ្រប់នាយកដ្ឋានជំនាញក្រោមអគ្គនាយកដ្ឋាន នៃក្រសួងបរិស្ថាន | - | បន្តធ្វើ | ៥00,000[១១] | - | - |
| | | | | **ទឹកប្រាក់សរុបសម្រាប់ គយស១:** | **១៨,២00,000** | | |
| **គោលដៅយុទ្ធសាស្ត្រទី២- លើកកម្ពស់ការគ្រប់គ្រងដោយចីរភាព** | | | | | | | |
| **គយស ២.១-** ធ្វើសុខដុមកម្មនៃសកម្មភាពអភិវឌ្ឍន៍ជាមួយនឹងគោលដៅនៃការគ្រប់គ្រងតំបន់ការពារ | ក) ជម្រុញឱ្យសម្បទានដីសេដ្ឋកិច្ចដែលមានក្នុងតំបន់ការពារធម្មជាតិ បានធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន | GDANCP ជាមួយកិច្ចសហការដោយ EIAD & MAFF | ១0% នៃ ELCs | ៦0% នៃ ELCs | ៣៧៥,000[១២] | ១00% នៃ ELCs | ១00% នៃ ELCs |
| | ខ) គណៈកម្មាធិការជាតិដោះស្រាយទំនាស់ក្នុងការគ្រប់គ្រប់តំបន់ការពារធម្មជាតិ និងបានបង្កើនដំណើរការដោះស្រាយលើជម្លោះដីធ្លី | MOE | - | រួចរាល់ | - | - | - |
| **គយស ២.២-** ភ្ជាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ | ក) រៀបចំផែនទីប្រព័ន្ធអេកូឡូស៊ី និងវិភាគភាពខ្វះចន្លោះនៃព័ត៌មាន ដើម្បីកំណត់ និងរៀបចំរបៀងជីវៈចម្រុះថ្មី និងធ្វើការកែសម្រួលព្រំប្រទល់តំបន់ការពារធម្មជាតិដែលមានស្រាប់ ដោយផ្អែកលើទិន្នន័យជាក់លាក់ | GDANCP/GDLC និងការគាំទ្របច្ចេកទេសពី GIS-GDEKI | - | រួចរាល់ | ២,៥00,000[១៣] | - | - |
| | ខ) ចំនួនតំបន់ការពារធម្មជាតិ សមុទ្រ/ឆ្នេរ បានស្នើឡើង និងទទួលបានការឯកភាព | GDANCP | ១ | ៤ | ៩00,000[១៤] | ៨ | ១0 |
| | គ) ចំនួនតំបន់តំបន់ការពារធម្មជាតិដីសើម បានស្នើឡើង និងទទួលបានការឯកភាព ពិសេសតំបន់រាមសារ | GDANCP | ៤ | ៨ | ១,២00,000[១៥] | ១២ | ១៥ |
| | | | | **ទឹកប្រាក់សរុបសម្រាប់ គយស ២:** | **៤,៩៧៥,000** | | |

| **គោលដៅយុទ្ធសាស្ត្រទី៣- ពង្រីកការចូលរួមរបស់សហគមន៍មូលដ្ឋាន និងបង្កើនផលប្រយោជន៍** | | | | | | | |
|---|---|---|---|---|---|---|---|
| **គយស ៣.១-** បង្កើនការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងដំណើរការរៀបចំផែនការគ្រប់គ្រង | ក) មន្ត្រីពី GDLC មន្ទីរបរិស្ថានខេត្ត និងនាយកឧទ្យាន នឹងទទួលបានការបណ្តុះបណ្តាលអំពីវិធីសាស្ត្រចូលរួម និងយេនឌ័រ ដើម្បីជម្រុញកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ (បណ្តុះបណ្តាលគ្រូបង្គោល) | GDLC/GDANCP | ០ | - | ៨០០,០០០[១៦] | - | - |
| | ខ)បង្កើត និងផ្សព្វផ្សាយយុទ្ធនាការលើកកម្ពស់ចំណេះដឹងពីគោលបំណង បទដ្ឋានគតិយុត្ត និងច្បាប់តំបន់ការពារធម្មជាតិសម្រាប់សមត្ថកិច្ចមូលដ្ឋាន | GDLC ជាមួយនឹងការគាំទ្រពី GDANCP and GDEKI | ០ | - | ១,២៥០,០០០[១៧] | - | - |
| | គ)ចំនួនតំបន់ការពារធម្មជាតិដែលបានរួមសហការជាមួយសហគមន៍មូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពស្តារប្រព័ន្ធអេកូឡូស៊ី និងព្រៃឈើ | GDANCP/GDLC | ៦ PAs | ៣០ PAs | ៦,០០០,០០០[១៨] | ១០០% នៃ PAs | ១០០% នៃ PAs |
| **គយស ៣.២-** គាំទ្រយន្តការកិច្ចសហប្រតិបត្តិការគ្រប់គ្រងតំបន់ការពារធម្មជាតិ | ក)ចំនួនសហគមន៍តំបន់ការពារធម្មជាតិបានទទួលការឯកភាពលើផែនការគ្រប់គ្រង | GDLC/GDANCP | ២២ CPAs | ៦០ CPAs | ១,៣៣០,០០០[១៩] | ៧៥% នៃ CPAs | ១០០% នៃ CPAs |
| | ខ)ចំនួនសហគមន៍តំបន់ការពារធម្មជាតិ បានចែករំលែកពីមេរៀនពិសោធន៍របស់ខ្លួនទៅសហគមន៍ដទៃៗទៀត និងទទួលបានគាំទ្រលើកិច្ចប្រតិបត្តិ | GDLC | ៥ | ៤០ | ១,៧៥០,០០០[២០] | ៧៥% | ១០០% |
| | គ)ចំនួនសហគមន៍តំបន់ការពារធម្មជាតិថ្មីត្រូវបានឯកភាពឱ្យបង្កើត ជាមួយនឹងការកំណត់ព្រំប្រទល់ច្បាស់លាស់ | GDLC/GDANCP | ០ | ២៥ | ១,២៥០,០០០[២១] | ៥០ | ៧៥ |
| **គយស ៣.៣-** ពង្រីកឱកាសសម្រាប់លើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន | ក)ចំនួនសហគមន៍តំបន់ការពារធម្មជាតិ បានកំណត់គោលដៅសម្រាប់លើកកម្ពស់ជីវភាពរស់នៅ | GDLC | ១៥ | ៥០ | ២,៦២៥,០០០[២២] | ៧៥% | ១០០% |
| | ខ)ចំនួនសហគមន៍តំបន់ការពារធម្មជាតិ ទទួលបានការសម្របសម្រួលលើឱកាសប្រើប្រាស់មីក្រូហិរញ្ញវត្ថុ (ដោយរួមបញ្ចូលនូវមុខរបរសម្រាប់ស្ត្រី) | GDLC | ៥ | ៣០ | ១,២៥០,០០០[២៣] | ៥០% នៃ CPAs | ១០០% នៃ CPAs |
| | គ)រៀបចំយុទ្ធសាស្ត្រអេកូទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ និងបង្កើតបណ្តាញអេកូទេសចរណ៍ធម្មជាតិ | GDANCP/GDLC | ០ | រួចរាល់ | ៣២៥,០០០[២៤] | - | - |
| | ឃ)ចំនួនសហគមន៍តំបន់ការពារធម្មជាតិ បានរៀបចំផែនការអាជីវកម្មសម្រាប់អភិវឌ្ឍន៍អេកូទេសចរណ៍ | GDLC | ៣ PAs | ១៥ PAs | ៩០០,០០០[២៥] | ៥០% នៃ PAs | ៧៥% នៃ PAs |
| | ង)ចំនួនសហគមន៍តំបន់ការពារធម្មជាតិ បានបង្កើតប្រាក់ចំណូលសម្រាប់ចូលរួមសកម្មភាពគ្រប់គ្រង និងអភិរក្ស | GDLC/GDANCP | ៣ | ១០ | - | ៥០% | ៧៥% |
| | | | | **ទឹកប្រាក់សរុបសម្រាប់ គយស ៣:** | **១៧,៤៨០,០០០** | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **គោលដៅយុទ្ធសាស្ត្រទី៤- ពង្រឹងសមត្ថភាពស្ថាប័ន និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ** | | | | | | | |
| **គយស ៤.១-** ធានាបានមន្ត្រីគ្រប់គ្រាន់ថ្នាក់ជាតិ និងក្រោមជាតិ ដែលមានទាំងសមត្ថភាព និងធនធានសមស្រប | ក)បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់តំបន់ចំនួនបីកន្លែងសម្រាប់បង្រៀនដល់មន្ត្រីតំបន់ការពារធម្មជាតិ និងសមត្ថកិច្ចមូលដ្ឋាន | GDANCP/GDLC | ០ | ៣ | ៣,៦០០,០០០[២៦] | ១០០% | ១០០% |
| | ខ)រៀបចំផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍នៅ GDANCP ដែលផ្តល់យោលប់បច្ចេកទេស និងការបណ្តុះបណ្តាល សម្រាប់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅលើការអភិរក្សជីវសាស្ត្រ | MOE and GDANCP | - | រួចរាល់ | ១,០០០,០០០[២៧] | - | - |
| | គ)ចំនួនកម្មវិធីបច្ចេកទេសបណ្តុះបណ្តាលចម្រុះបានបង្កើតឡើង និងចែកជូនដល់មន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត | GDANCP/GDLC | ០ | ១០ | ៧៥០,០០០[២៨] | ១៥ | ២០ |
| **គយស ៤.២-** បង្កើនកិច្ចសហប្រតិបត្តិការក្នុងការសិក្សាស្រាវជ្រាវ ការរៀបចំផែនការ និងគោលនយោបាយ | ក)យន្តការសម្របសម្រួលលើកម្រិតគោលនយោបាយ និងបច្ចេកទេស បានបង្កើត | MOE and NCSD | - | រួចរាល់ | - | - | - |
| | ខ)ក្រសួងបរិស្ថានមានមជ្ឈមណ្ឌលដែលប្រមូល រៀបចំ ចងក្រងបញ្ជីទិន្នន័យគោល អំពីការអភិរក្ស និងចែកចាយ | GDANCP and Biodiversity Department (GSSD) | - | រួចរាល់ | ៥០០,០០០[២៩] | - | - |
| | គ)ចំនួនតំបន់ការពារធម្មជាតិ ប្រើស្តង់ដាតាមដានវាយតម្លៃស្ថានភាពជីវចម្រុះ | GDANCP and Biodiversity Department (GSSD) | ៤ | ២០ | ៨០០,០០០[៣០] | ៥០% | ១០០% |
| | ឃ)ចំនួនតំបន់ការពារធម្មជាតិ បានបញ្ចប់ការវាយតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី (PES សាកល្បង) | GDANCP and Biodiversity Department (GSSD) | ០ | ៥ | ៦២៥,០០០[៣១] | ១០ | ២០ |
| | | | | **ទឹកប្រាក់សរុបសម្រាប់ គយស ៤:** | **៧,២៧៥,០០០** | | |
| **ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ** | | | | | | | |
| ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងវាយតម្លៃ | ក)ចំនួនតំបន់ការពារធម្មជាតិបានបញ្ចប់ការវាយតម្លៃរហ័សនៃប្រសិទ្ធភាពការគ្រប់គ្រង | GDANCP/GDLC NCSD | ០ | ៥ | ៣៧៥,០០០[៣២] | ២០ | ១០០% |
| | | | | **សរុបទឹកប្រាក់ទាំងអស់:** | ៤៨,៣០៥,០០០ | | |

**កំណត់ចំណាំថវិកា (រួមបញ្ចូលចំណាយប៉ាន់ស្មាន)៖**

១. ផែនទីGIS ការបោះនិងការដាក់ បង្គោល / ស្លាកសញ្ញា (ជាមធ្យម $ ៥០,០០០ / PA ) ជាមួយនឹងការចំណាយខ្ពស់ជាងមុនសម្រាប់តំបន់ដីសើម (ជាមធ្យម $ ៧៥,០០០)

២. ការវាយតម្លៃធនធានរហ័ស ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងការរៀបចំនៃទម្រង់ព័ត៌មានតំបន់ការពារធម្មជាតិ (ជាមធ្យម $ ៦០,០០០ / PA)

៣. ការវាយតម្លៃធនធានរហ័ស ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ គូសផែនទី GIS (ជាមធ្យម $ ៥០,០០០ / PA)

៤. ការប៉ាន់ប្រមាណរួមសម្រាប់ចំណាយលើការកំណត់តំបន់របៀងជីវៈចម្រុះ ៥០% (៧០០,០០០ ហិកតា)

៥. បង្កើតប្រព័ន្ធនិងការវាយតម្លៃធនធានគម្របព្រៃឈើតាមរយៈប្រព័ន្ធផ្កាយរណប (Forest Cover) និងការវាយតម្លៃធនធានព្រៃឈើ (Field inventory assessment) ជាមធ្យម $ ៧៥០,០០០ / លើក

៦. រួមបញ្ចូលទាំង រថយន្តដែលសមរម្យ, ឧបករណ៍ទីវាល និងឧបករណ៍ទាក់ទងចល័ត (ជាមធ្យម $ ១២៥,០០០ / PA)

៧. បានប៉ាន់ប្រមាណចំណាយលើការបណ្តុះបណ្តាល ១,៥០០ $ / មន្ត្រីម្នាក់ ដោយរួមទាំងការរៀបចំ និងផ្តល់កម្មវិធីបណ្តុះបណ្តាល ការធ្វើដំណើរ និងសម្ភារៈ
៨. ការរៀបចំនិងការចែកចាយកម្មវិធីយល់ដឹង ប៉ាន់ប្រមាណចំណាយជាមធ្យម $ ៥០,០០០ / PA
៩. ការរៀបចំ និងការអនុវត្តន៍ផែនការសកម្មភាពតាមតំបន់ការពារធម្មជាតិ ប៉ាន់ប្រមាណតម្លៃចំណាយ $ ៧៥,០០០ / ផែនការ
១០. ការរៀបចំនិងការអនុវត្តសកម្មភាពដាំស្តារព្រៃឈើ បានប៉ាន់ប្រមាណតម្លៃចំណាយ $ ២៥០,០០០ / ផែនការ
១១. ប៉ាន់ប្រមាណចំណាយលើការធ្វើដំណើរបន្ថែម $ ១០០,០០០ / ឆ្នាំ
១២. ការចូលរួមត្រួតពិនិត្យលើដីសម្បទានសេដ្ឋកិច្ចក្នុងតំបន់ការពារធម្មជាតិ ( ជាមធ្យម $ ៧៥,០០០ / ឆ្នាំ )
១៣. ការធ្វើផែនទី GIS និងប្រព័ន្ធអេកូឡូស៊ី ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ, ការធ្វើផែនការគ្រប់គ្រង ប៉ាន់ប្រមាណចំណាយ $ ៥០០,០០០ / ឆ្នាំជាង តម្រូវការលើសពី ៥ ឆ្នាំ
១៤. ការពិគ្រោះយោបល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ការវាយតម្លៃធនធាន, ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង, ការធ្វើផែនការគ្រប់គ្រង ( ជាមធ្យម ៣០០,០០០ / PA ថ្មី )
១៥. ការពិគ្រោះយោបល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ការវាយតម្លៃធនធាន, ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង, ការធ្វើផែនការគ្រប់គ្រង ( ជាមធ្យម ៣០០,០០០ / PA ថ្មី )
១៦. ការបណ្តុះបណ្តាលសម្រាប់បុគ្គលិកប្រមាណជា ២០០ នាក់ ប៉ាន់ប្រមាណ $ ៤,០០០ / បុគ្គលិកម្នាក់ រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាល មេរៀនចែកចាយ និងការធ្វើដំណើរ
១៧. រៀបចំយុទ្ធនាការលើកកំពស់ការយល់ដឹង ប៉ាន់ប្រមាណ $ ២៥០,០០០ / ឆ្នាំ
១៨. វាយតម្លៃតំបន់ការពារធម្មជាតិ ដោយពិនិត្យសក្តានុពលស្តារឡើងវិញ, ការរៀបចំថ្នាលបណ្តុះកូនឈើ, ការពិគ្រោះយោបល់ជាមួយអ្នកភូមិ ថ្លៃពលកម្មនិងសម្ភារៈ ( ជាមធ្យម $ ២៥០,០០០ / PA)
១៩. ការពិគ្រោះយោបល់ និងរៀបចំផែនការគ្រប់គ្រង ( ជាមធ្យម $ ៣៥,០០០ / CPA )
២០. ពិគ្រោះយោបល់ និងបន្តជួយគាំទ្រដល់សហគមន៍តំបន់ការពារធម្មជាតិ និងកសាងបណ្តាញសហគមន៍ ( ជាមធ្យម $ ១០,០០០ / ឆ្នាំ / CPA )
២១. ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ, ការកំណត់និងបែងចែកតំបន់, ការធ្វើផែនការការគ្រប់គ្រង និងការគាំទ្រប្រតិបត្តិនៅដំណាក់កាលដំបូង ( ជាមធ្យម $ ៥០,០០០ / CPA )
២២. ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ការបណ្តុះបណ្តាល និងការអភិវឌ្ឍកម្មវិធីនានា ( ជាមធ្យម $ ៧៥,០០០ / CPA )
២៣. ការអភិវឌ្ឍផែនការអាជីវកម្មនៅក្នុងកិច្ចសហការជាមួយដៃគូក្នុងវិស័យឯកជន ( ជាមធ្យម $ ៥០,០០០ / PA )
២៤. ការពិគ្រោះយោបល់និងការរៀបចំយុទ្ធសាស្ត្រ ប៉ាន់ប្រមាណ $ ៧៥,០០០; ការចំណាយនិងការរៀបចំបណ្តាញអេកូទេសចរណ៍ ប៉ាន់ប្រមាណ $ ៥០,០០០ / ឆ្នាំ តម្រូវការលើស ៥ ឆ្នាំ
២៥. ការរៀបចំផែនការអាជីវកម្ម និងការកំណត់អត្តសញ្ញាណផលិតផល, យុទ្ធសាស្ត្រទីផ្សារ, ហេដ្ឋារចនាសម្ព័ន្ធ, តម្រូវការវគ្គបណ្តុះបណ្តាល, និងការរៀបចំយន្តការចែករំលែកផលប្រយោជន៍ ( ជាមធ្យម $ ៧៥,០០០ / PA )
២៦. រួមបញ្ចូលទាំងការចំណាយជួសជុលទ្រព្យសម្បត្តិរដ្ឋដែលមានស្រាប់, ការចំណាយលើដំណើរការនិងការថែទាំលើសពី ៤ ឆ្នាំ ( អគារសន្មតថាត្រូវបានគេរៀបចំឡើងវិញនៅឆ្នាំ 2018 )
២៧. ទទួលបានបុគ្គលិកជួលសម្រាប់ពិគ្រោះយោបល់ចំនួន ១០ នាក់ នៅឆ្នាំ២០១៧ ហើយបន្ទាប់មកអាចធ្វើនិយ័តកម្មជាមន្ត្រីក្រសួងបរិស្ថាននៅឆ្នាំ២០២១ ដោយប៉ានចំណាយលើ ប្រាក់បៀវត្ស, សម្ភារៈនានា ការិយាល័យ និងការធ្វើដំណើរលើសពី ៥ ឆ្នាំ (២០១៧-២០២១ )
២៨. រួមបញ្ចូលការចំណាយលើការរៀបចំមេរៀន និងការផ្តល់វគ្គបណ្តុះបណ្តាល សម្រាប់បុគ្គលិកប្រមាណ ៥០ នាក់ ( ជាមធ្យម $ ៧៥,០០០ / ម៉ូឌុល )
២៩. រៀបចំមូលដ្ឋានទិន្នន័យដោយចងក្រងទិន្នន័យមានស្រាប់, បញ្ចូលទិន្នន័យ និងផែនទីចម្លង
៣០. រៀបចំវគ្គបណ្តុះបណ្តាល និងការប្រើពិធីការត្រួតពិនិត្យសាកល្បង ( ជាមធ្យម $ ៥០,០០០ / PA )
៣១. ពិគ្រោះយោបល់ទាំងថ្នាក់ជាតិនិងអន្តរជាតិ, សិក្សាវាយតម្លៃលើវគ្គណ្តុះបណ្តាលសម្រាប់មន្ត្រីស្នូលនៃ GDANCP ( ជាមធ្យម $ ១២៥,០០០ / PA )
៣២. រៀបចំវិធីសាស្ត្រសមស្របសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ លើការវាយតម្លៃឆាប់រហ័ស និងការរៀបចំរបាយការណ៍ត្រួតពិនិត្យវាយតម្លៃ ( ជាមធ្យម $ ៧៥,០០០ / PA )